ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- បញ្ហាក្នុងការបកប្រែភាសានៅតុលាការខ្មែរក្រហម
- និយមន័យឧក្រិដ្ឋកម្ម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១០២ ខែមិថុនា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ១០២ ខែមិថុនា ឆ្នាំ២០០៨

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រ ៖ បញ្ហាក្នុងការបកប្រែភាសានៅតុលាការខ្មែរក្រហម................១

**ផ្នែកឯកសារ**

◆ ស្មើរតែបាត់បង់ជីវិត................................................................៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម ..................................៦

◆ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតគេហទំព័រ ....................................១២

◆ របាយការណ៍ពីខេត្តព្រៃវែង.......................................................១៤

◆ ទង់ជាតិខ្មែរក្រហម ..................................................................១៩

◆ តួនាទីសិល្បៈក្នុងបដិវត្តន៍ខ្មែរក្រហម ..............................................២៣

◆ ការស្ទង់មតិជាសាធារណៈអំពីសាលាក្តីខ្មែរក្រហម .............................២៧

**ផ្នែកច្បាប់**

◆ និយមន័យឧក្រិដ្ឋកម្ម ................................................................២៨

◆ ភាពចាំបាច់សម្រាប់ស្ថាប័នការពារ................................................៣១

◆ របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង....................................៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍..................................៥១

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ យុវជនទទួលចំណេះដឹងពីរបបខ្មែរក្រហម .......................................៥៩







**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


***ស្នេរលេខនេះ*** ៖ *ដី ទេរិទ្ធិ, សារ៉ា ថូម៉ាស, ស៊ីប្រេហ្វដ អ៊ីម៉ាន់, គីម សុវណ្ណដានី, លី សុខឃាង, ប៉ែត វ៉ាន់ស្កាក់, រ៉ក់ហ្វត ហ៊ីន, ឌី ខាំបូលី, ឈាង បុប្ផា, ឡុង ដានី*
***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *គាត លក្ខិណា, សោម ប៊ុនថន* ***អ្នកបកប្រែ*** ៖ *ដួង ចំរើន, ជា ផល្លា* ***និពន្ធនាយកទូទៅ*** ៖ *ឆាំង យុ* ***ជំនួយការនិពន្ធនាយក*** ៖ *ទេព ម៉េងឃាន*
***ក្រាហ្វិកកុំព្យូទ័រ*** ៖ *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *ឆេង វើង* Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# បញ្ហាក្នុងការបកប្រែភាសានៅតុលាការខ្មែរក្រហម

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការចម្រុះរវាងភាគីជាតិនិងអន្តរជាតិ ដែលប្រើប្រាស់ច្បាប់អន្តរជាតិ និងច្បាប់ក្នុងស្រុកដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ នៅក្នុងតុលាការនេះ បុគ្គលិកត្រូវប្រើប្រាស់ភាសាចំនួនបីជាសំខាន់ គឺ ភាសាខ្មែរ អង់គ្លេស និងបារាំង ហើយបុគ្គលិកទាំងនេះមានប្រភពមកពីប្រទេសផ្សេងៗគ្នា ។ កត្តាបែបនេះគឺមានលក្ខណៈសមស្រប ទៅតាមគោលគំនិតនៃការកាត់ទោសអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រជាជនទាំងអស់នៅក្នុងពិភពលោកមានកាតព្វកិច្ចចូលរួមទប់ស្កាត់ និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ ជាក់ស្តែង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា គឺជាតុលាការដែលមានការចូលរួមពីអ្នកច្បាប់ដែលមានជាតិសាសន៍ខុសៗគ្នាជាច្រើននាក់ ។ ថ្វីដ្បិតតែតុលាការចម្រុះរវាងអន្តរជាតិ និងជាតិទាំងពីរនេះគោរពទៅតាមបទដ្ឋានអន្តរជាតិបានល្អក៏ដោយក៏នៅជួបប្រទះនឹងបញ្ហាជាច្រើន ក្នុងនោះមានបញ្ហាដ៏ធំមួយ គឺការបកប្រែឯកសារសរសេរជាអក្សរជាតិនៃប្រទេសរងគ្រោះឲ្យទៅជាភាសាអន្តរជាតិ ដូចជាភាសាអង់គ្លេស និងបារាំង ។ ការបកប្រែនេះគឺដើម្បីឲ្យបុគ្គលិករបស់តុលាការទាំងអស់បានយល់ច្បាស់លាស់អំពីឯកសារដើម និងដើម្បីរក្សាសមភាពរវាងភាគីដើមចោទ និងចុងចោទក្នុងការប្រើប្រាស់ឯកសារដើម ។ ប៉ុន្តែការធ្វើបែបនេះ គឺត្រូវចំណាយអស់ធនធានរបស់តុលាការយ៉ាងច្រើននិងប្រើប្រាស់ពេលវេលាយូរទៀត ។

នៅក្នុងតុលាការខ្មែរក្រហម គេសង្កេតឃើញមានឯកសារចំនួនប្រហែលជា១៦០០០សន្លឹក ដែលត្រូវបកប្រែជាបន្ទាន់ក្នុងរយៈពេលខ្លីពីភាសាខ្មែរទៅជាភាសាអង់គ្លេស និងបារាំង ។ នេះជាទំហំកិច្ចការដ៏ធំ ដែលទាមទារឲ្យមានធនធានមនុស្ស និងហិរញ្ញវត្ថុធំធេងដើម្បីដោះស្រាយ ។ តុលាការខ្មែរក្រហមបានព្យាយាមជ្រើសរើសបុគ្គលិកបកប្រែជាច្រើននាក់ ប៉ុន្តែនៅតែមិនទាន់ឃើញលេចចេញជាលទ្ធផលទាន់តាមពេលវេលា និងតាមការទាមទាររបស់ដំណើការសាលាក្តីឡើយ ។ ហេតុនេះ ក្រុមរៀបចំ និងគ្រប់គ្រងឯកសាររបស់តុលាការកំពុងព្យាយាមផ្ទេរកិច្ចការបកប្រែឯកសារចំនួនជាង២០០០ទំព័រ ទៅឲ្យស្ថាប័នឯកជនបំពេញជាបន្ទាន់ ។

ដើម្បីដោះស្រាយភាពរាំងស្ទះក្នុងការបកប្រែឯកសារ តុលាការខ្មែរក្រហមអាចព្យាយាមប្រើប្រាស់វិធីពីរយ៉ាង៖ ទី១) តុលាការអាចសម្រង់យកឯកសារណាដែលមានភាពចាំបាច់ និងត្រូវការយកទៅប្រើប្រាស់ជាបន្ទាន់មកបកប្រែឲ្យបានក្បោះក្បាយទាំងអត្ថន័យ បរិបទជុំវិញ និងអារម្មណ៍នៅក្នុងឯកសារដើម ។ ទី២) តុលាការអាចដោះស្រាយបញ្ហាតាមរយៈការប្រើប្រាស់មេធាវីជំនាញផ្នែកភាសា ដែលបុគ្គលរូបនេះមានតួនាទីជាជំនួយការរបស់ភាគីទាំងសងខាង ។ កិច្ចការចម្បងរបស់ភាគីភាសានេះ គឺពិនិត្យទៅលើឯកសារដើម និងជ្រើសរើសយកឯកសារណាដែលសំខាន់ និងទាក់ទងទៅនឹងរឿងក្តី រួចបញ្ជូនទៅឲ្យភាគីដែលខ្លួនបម្រើការ ។

កន្លងមកមជ្ឈមណ្ឌលឯកសារកម្ពុជាបានបកប្រែឯកសារដើមជាច្រើនសន្លឹក និងសៀវភៅជាច្រើនក្បាលពីភាសាខ្មែរទៅជាភាសាអង់គ្លេស និងពីភាសាអង់គ្លេសទៅជាភាសាខ្មែរ ។ ជាការពិតណាស់ ការបកប្រែមិនមែនជាភារកិច្ចមួយដែលងាយស្រួលនោះទេ ប៉ុន្តែអ្នកបកប្រែអាចកែប្រែល្បឿននៃការបកប្រែតាមរយៈការផ្លាស់ប្តូរគុណភាពឯកសារដែលបកប្រែហើយ ។ អ្នកបកប្រែអាចធ្វើបានយ៉ាងលឿន ដោយគ្រាន់តែបកសង្ខេបពីចំណុចគោលៗរបស់អត្ថបទដើម ។ វិធីសាស្ត្រទីពីរ តម្រូវឲ្យអ្នកបកប្រែពិនិត្យឲ្យបានច្បាស់លាស់ទៅលើឯកសារដើម ហើយប្រើប្រាស់ពាក្យពេចន៍ឲ្យចំទៅតាមកាលៈទេសៈដើម្បីរក្សាអត្ថន័យ និងអារម្មណ៍ដែលមានរៀបរាប់ក្នុងអត្ថបទចាស់ ។ ប៉ុន្តែការធ្វើបែបនេះ ត្រូវចំណាយពេលយូរ ហើយទាមទារឲ្យអ្នកបកប្រែមានចំណេះដឹងខ្ពស់ផ្នែកភាសាខ្មែរ អង់គ្លេស និងប្រធានបទទាក់ទងនឹងឯកសារដែលខ្លួនបកប្រែ ។ ប៉ុន្តែអ្នកបកប្រែដែលមានសមត្ថភាពបែបនេះ ពិបាកនឹង

ស្វែងរកឲ្យបានច្រើននាក់ដើម្បីបកប្រែឯកសារដែលមានបរិមាណច្រើនក្នុងរយៈពេលខ្លី ។ ដើម្បីរក្សាអត្ថន័យដើមសំខាន់ៗរបស់អត្ថបទមួយមិនមែនជាការពិបាកទេ ប៉ុន្តែអ្វីដែលសំខាន់គឺជាការរក្សាអារម្មណ៍ និងបរិបទជុំវិញឯកសារដើមនេះគឺជាការពិបាក ។ មូលហេតុដែលយើងមានបញ្ហាបែបនេះ គឺដោយសារវប្បធម៌ខ្មែរ និងវប្បធម៌លោកខាងលិច ដែលនិយាយភាសាអង់គ្លេសមានលក្ខណៈខុសគ្នាខ្លាំងពិសេសការបញ្ជាក់អត្ថន័យលើអារម្មណ៍ច្រើនតែមានភាពផ្សេងគ្នា ។ លើសពីនេះទៀតនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន យើងកម្រនឹងរកបានបុគ្គលណាដែលអាចយល់ដឹងពីវប្បធម៌លោកខាងលិចបានច្បាស់លាស់ណាស់ ។ ម៉្យាងវិញទៀតខ្មែរក្រហមផ្ទាល់ ទោះបីជានិយាយភាសាខ្មែរក៏ការប្រើប្រាស់ភាសាខ្មែរនោះមានលក្ខណៈខុសគ្នាបន្តិចពីភាសាខ្មែរបច្ចុប្បន្ន ។ ហេតុនេះ អ្នកបកប្រែឯកសារខ្មែរក្រហមត្រូវមានការយល់ដឹងឲ្យបានច្បាស់លាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ប៉ុន្តែបច្ចុប្បន្នអ្នកដែលយល់បានជ្រាលជ្រៅបែបនេះ ហើយចេះភាសាខ្មែរថែមទៀតមានចំនួនតិចតួចកម្រនឹងរកបានណាស់ ។

នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចាប់ផ្តើមការងារប្រមែប្រមូល ចងក្រង និងសិក្សាឯកសារទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម យើងបានជួបប្រទះនឹងភាពលំបាកក្នុងការបកប្រែដែរ ប៉ុន្តែមួយរយៈក្រោយមក បញ្ហានេះត្រូវបានដោះស្រាយជាបណ្តើរៗ ដោយសារយើងស្វែងយល់បន្តិចម្តងៗពីទស្សនៈមនោគមន៍វិជ្ជា សកម្មភាពនយោបាយ ផែនការសេដ្ឋកិច្ច និងការរៀបចំសង្គមរបស់ខ្មែរក្រហម ហើយយើងបានរកពាក្យក្នុងភាសាអង់គ្លេសដែលអាចបញ្ជាក់អត្ថន័យចំៗពីភាសាខ្មែរ ។ ជាលទ្ធផលយើងបានបង្កើតជាសទ្ទានុក្រមខ្មែរក្រហមមួយដែលកំពុងត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នផ្សេងៗ ។

**អេង កុកថាយ**



ឯកសារដែលបន្សល់ពីរបបខ្មែរក្រហម

# ស្ទើរតែបាត់បង់ជីវិត

មុនឆ្នាំ១៩៧៥ ខេត្តក្រចេះស្ថិតក្នុងតំបន់៥០៥ ភូមិភាគឦសាន្តដែលមានព្រំប្រទល់ខាងកើតជាប់នឹងប្រទេសវៀតណាម ។ នៅពេលនោះដោយពិបាកក្នុងការដឹកជញ្ជូនស្បៀងនិងគ្រឿងសព្វាវុធផ្តល់ទៅឲ្យកងទ័ពដែលបោះទីតាំងនៅតំបន់ឆ្ងាយៗ ព្រោះមានការស្ទាក់បាញ់ពីកងទ័ពវៀតណាមខាងត្បូងនិងកងទ័ពលន់ នល់ ខ្មែរក្រហមបានផ្តាច់ខេត្តក្រចេះទៅជាតំបន់ស្វយ័ត៥០៥ ។ ក្រោយមកប្រជាជនមួយចំនួនក្នុងខេត្តនេះក៏ត្រូវខ្មែរក្រហមចោទថា បានលួចយកស្បៀងទៅលាក់ទុកនិងផ្តល់ឲ្យកងទ័ពវៀតណាមដែលបន្កប់ខ្លួនធ្វើសកម្មភាពប្រឆាំងអង្គការ ។ ខណៈនោះ សឿន ដែលជាប្រធានកង ប្រធានអនុសេនាតូច ប្រធានមន្ទីរពិការ ប្រធានមន្ទីរស្រុកស្នួង និងជាប្រធានមន្ទីរតំបន់ក្រចេះក៏បានដឹងពីការចាប់ខ្លួនអ្នកជាប់ពាក់ព័ន្ធខ្សែរយៈខ្មាំងជាច្រើននាក់ យកទៅដាក់ឃុំឃាំង និងសម្លាប់ចោលដែរ ។ ទោះបីខ្មែរក្រហមជាមនុស្សឃោរឃៅសម្លាប់ប្រជាជនក៏ដោយ ក៏ សឿន ដែលជាអតីតកម្មាភិបាលខ្មែរក្រហមបានជួយប្រជាជនជាច្រើនគ្រួសារឲ្យរួចផុតពីការធ្វើទារុណកម្ម និងកាប់សម្លាប់ផងដែរ ។

## សិល្បៈបដិវត្តន៍

សឿន កើតនៅភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅឆ្នាំ១៩៦៨ សឿន រៀនបានថ្នាក់ទៃមីណាល់ (ថ្នាក់ទីបញ្ចប់) នៅវិទ្យាល័យសម្តេចឪ (បច្ចុប្បន្នវិទ្យាល័យសុខ អាន ស្វាគូ) ក្រោយមកក៏ឈប់រៀនដើម្បីជួយធ្វើស្រែចម្ការឪពុកម្តាយ ។ បន្ទាប់ពីរដ្ឋប្រហារខែមីនា ឆ្នាំ១៩៧០ ស្រុកត្រាំកក់ត្រូវបានខ្មែរក្រហមចូលមកគ្រប់គ្រងទាំងស្រុង ហើយបានឃោសនាឲ្យប្រជាជនចូលរួមតស៊ូរំដោះប្រទេសពីរបប លន់ នល់ និងចក្រពត្តិអាមេរិក ដើម្បីសុំសម្តេចសីហនុ យាងមកកាន់អំណាចវិញ ។ អ្នកភូមិជាច្រើនបានចាកចេញពីបងប្អូន ឪពុកម្តាយ លះបង់ទ្រព្យសម្បត្តិ និងផ្ទះសម្បែងមកចូលរួមជាមួយចលនានេះ ។ ដោយសារ សឿន មានអាកប្បកិរិយារួសរាយ និងកំប្លែង លោកគ្រូបង្រៀននៅវិទ្យាល័យសម្តេចឪបានចាត់តាំងឲ្យទៅចូលហាត់សិល្បៈនៅស្រុកអង្គរជ័យ ។ ប៉ុន្តែម្តាយរបស់ សឿន បានបដិសេធដោយសុំឲ្យ សឿន ធ្វើការនៅកងកុមារភូមិជំនួសវិញ ។ ទោះជាមានការតវ៉ាក៏ដោយក៏ សឿន នៅតែចាកចេញ ដោយមានជាប់ខ្លួនតែខោអាវមួយកំប្លេរនិងក្រមាមួយសម្រាប់ផ្លាស់ប្តូរប៉ុណ្ណោះ ។ ដំបូង សឿន ត្រូវទៅស្នាក់នៅផ្ទះឈើមួយខ្នង ដែលជាទីស្នាក់ការសិល្បៈស្រុកអង្គរជ័យ មានអ្នកគ្រូ សុម៉ាលី និងលោកគ្រូ ឈិន ឈាង ជាគ្រូបង្រៀនអាយ៉ៃនិងជាអនុប្រធានសិល្បៈស្រុកអង្គរជ័យ ។ រៀងរាល់ថ្ងៃ សឿន ត្រូវធ្វើកាយវិការគ្រាប់ច្រៀង រាំ ដើម្បីសម្តែងលើវេទិកានៅពេលមានពិធីបុណ្យផ្សេងៗនៅក្នុងភូមិ ។


សេង សឿន

នៅឆ្នាំ១៩៧២ សិល្បៈស្រុកអង្គរជ័យបានបញ្ចូល សឿន ក្នុងសិល្បៈតំបន់៣៥ ភូមិភាគនិរតី ស្ថិតក្រោមការគ្រប់គ្រងរបស់កង ចាប ជាគណៈតំបន់ ។ មួយរយៈក្រោយមក លោកគ្រូ ឈិន ឈាង និងអ្នកគ្រូ សុម៉ាលី បានចុះចូលជាមួយរដ្ឋាភិបាលលន់ នល់ ទៅរស់នៅភ្នំពេញដែលធ្វើឲ្យក្រុមសិល្បៈតំបន់ត្រូវបានរំសាយ ។ បន្ទាប់មក សឿន ក៏បានចូលហាត់ក្បួនយុទ្ធសាស្ត្រដូចជា ក្រាប លូន ហែលទឹក ដោះតាំភ្លើង និងហាត់បាញ់ស៊ីប នៅស្រុកត្រាំកក់វិញ ។ ក្រោយពីបញ្ចប់វគ្គ សឿន ត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានក្រុមដែលមានសមាជិក១២នាក់ ។ នៅឆ្នាំ១៩៧២ លន់ ណុន បានដឹកនាំកម្លាំងទ័ពជើងគោក និងទ័ពអាកាស (ប្រតិបត្តិការអគ្គីនេត្រ) បើកការវាយប្រហារលើភូមិថ្នល់បត់ ផ្សារអង្គតាសោម និងឃុំកាត់ភ្លុក តំបន់៣៥ បណ្តាលឲ្យប្រជាជនស្លាប់អស់ជាច្រើននាក់ ។

នៅឆ្នាំ១៩៧៥ សឿន បានឡើងឋានៈជាប្រធានអនុសេនាតូចគ្រប់គ្រងទ័ពចំនួន១២០នាក់ និងត្រូវដឹកនាំកម្លាំងទ័ពឡើងទៅត្រៀមនៅសមរភូមិស្រុកកោះអណ្តែត ស្រុកគិរីវង្ស ស្រុកអង្គរបុរី និងស្រុកត្រាំកក់ ។ ក្រោយមកមានការប៉ះទង្គិចរវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាមជាបន្តបន្ទាប់ ដោយសារតែខ្មែរក្រហមចោទថា វៀតណាមបានបំផ្លាញទង់ជាតិដែលខ្មែរក្រហម

ដាំសម្គាល់ លួចបង្កិតបង្គោលព្រំដែន និងបញ្ជូនអាណិកជនវៀតណាមឲ្យមករស់នៅនិងធ្វើស្រែក្នុងទឹកដីខ្មែរដោយមិនបានបង់ពន្ធ ។ នៅពេលនោះ សឿន បានទទួលបញ្ជាពីអង្គការឲ្យដឹកនាំកម្លាំងទ័ពជើងទឹកទៅវាយជាមួយកងទ័ពវៀតណាមក្នុងសមរភូមិទន្លេអន្លង់ចាន ខេត្តកណ្តាល រហូតទទួលរងគ្រោះថ្នាក់ពិការជើងម្ខាង ។

**មន្ទីរយុទ្ធជន**

ក្រោយពីជាសះស្បើយពីរបួស អង្គការបានបញ្ជូន សឿន ឲ្យទៅគ្រប់គ្រងនៅមន្ទីរពិការតំបន់១៣ នៅខេត្តតាកែវ ដែលមានយុទ្ធជនពិការចំនួន១០០នាក់ ។ ដើមឆ្នាំ១៩៧៧ អង្គការបានប្រមូលជនពិការពីតំបន់២៥ តំបន់៣៣ តំបន់១៣ និងតំបន់៣៥ ភូមិភាគនិរតីឲ្យមកស្នាក់នៅជុំគ្នាតាមបណ្តោយស្ពានព្រែកហូរផ្សារកំពង់សំណាញ់ មន្ទីរពេទ្យឆ្អត និងរោងចក្រកង់ឡាន (ស្រុកតាខ្មៅ) ។ សឿន ត្រូវបានជ្រើសរើសឲ្យធ្វើជាអនុប្រធានមន្ទីរពិការ ។ ៣ខែក្រោយពីប្រធានមន្ទីរត្រូវអង្គការចាប់ខ្លួនដោយចោទថាក្បត់ សឿន ក៏បានឡើងឋានៈជាប្រធានដែលមានទីស្នាក់ការនៅម្តុំវត្តព្រែកឫស្សី ។ មន្ទីរនេះមានយុទ្ធជនពិការទាំងអស់៤០០នាក់ ហើយបែងចែកជាកងជួសជុលកាំភ្លើង កងដាំដំណាំ និងកងដឹកជញ្ជូនផលដំណាំយកទៅចែកទៅតាមមន្ទីរ ។ សឿន ក៏មានតួនាទីប្រមូលយុទ្ធជនពិការឲ្យរៀបការជាមួយកម្មការិនីចម្ការម្រេចដែលអង្គការដឹកយកមកពីខេត្តកំពត និងជួយដោះស្រាយជម្លោះគ្រួសារដែលពិការដូចជារឿងប្តីសុំលែងលះប្រពន្ធជាដើម ។ សឿន មានសិទ្ធិពិន័យចំពោះកម្មាភិបាលពិការណាដែលធ្វើខុសដោយឲ្យឈរត្រាំទឹកជាច្រើនម៉ោងទើបដោះលែងឲ្យមានសេរីភាពវិញ ។

**ប្រធានមន្ទីរស្រុក**

នៅខែមិថុនា ឆ្នាំ១៩៧៧ ប្រាក់ ជាគណៈតំបន់២៥ និង សៀន អនុតំបន់បានស្នើសុំ តាម៉ុក ឲ្យដក សឿន មកធ្វើការជាប្រធានមន្ទីរស្រុកស្អាងគ្រប់គ្រងឃុំចំនួន១០ ។ នៅពេលនោះ សៀន បានរៀបចំឲ្យ សឿន រៀបការជាមួយក្មួយស្រីបង្កើតរបស់គាត់ ប៉ុន្តែ សឿន បានបដិសេធ ។ ក្រោយមកគ្រួសាររបស់ សៀន និងសាច់ញាតិត្រូវអង្គការចាប់ខ្លួនបញ្ជូនទៅដាក់គុកជ្រៃ-ហូញ្ញៅជាបន្តបន្ទាប់ដោយចោទថាក្បត់ រួចផ្លាស់ សោ ផុន ឲ្យឡើងគ្រប់គ្រងជំនួសវិញ ។ នៅខែកញ្ញា ឆ្នាំ១៩៧៧ អង្គការបានជម្លៀសប្រជាជនមកពីស្រុកប្រសូត្រ (បច្ចុប្បន្នស្រុកស្វាយទាប) ខេត្តស្វាយរៀងជាច្រើននាក់ឲ្យមករស់នៅស្រុកស្អាង ។ នៅទីនោះ ជៀម ប្រធានមន្ទីរសន្តិសុខកោះគរបានស្រង់ប្រវត្តិរូបអតីតរដ្ឋការក្នុងរបប លន់ នល់ អាណិកជនវៀតណាម និងចិន ដោយបញ្ជាឲ្យចាប់ខ្លួនសួរចម្លើយ និងសម្លាប់ចោល រួមមានសាច់ញាតិ និងអ្នកប្រឡុំប្រវត្តិរូបស្រីដែលអាយុពី១៧ទៅ១៨ឆ្នាំអស់ជាច្រើននាក់ទៀតផង ។ ក្រោយពីបានដឹងការសម្លាប់ សឿន ក៏ត្រួតពិនិត្យបញ្ជីឈ្មោះម្តងទៀត និងបញ្ជាឲ្យចាប់ខ្លួន ជៀម បញ្ជូនទៅដាក់គុកកោះធំ ដោយចោទថា សម្លាប់អ្នកទោសដែលគ្មានកំហុស ។ នៅមន្ទីរស្រុក សឿន ក៏បានជួយសង្គ្រោះអ្នកទោសបាន៤គ្រួសារ ដោះលែងឲ្យត្រឡប់មករស់នៅក្នុងភូមិកំណើតវិញ ។

**ប្រធានមន្ទីរតំបន់**

នៅឆ្នាំ១៩៧៨ សឿន ត្រូវអង្គការដកឲ្យទៅធ្វើការនៅតំបន់៥០៥ ខេត្តក្រចេះ (តំបន់ស្វយ័ត) មាន ប៉ក់ លេខាតំបន់ និង មឿន ប្រធានយោធាតំបន់ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គសេនាធិការ ។

ថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៨ ម៉េត ប្រធានកងពល៥០២ បានចុះមកចាត់តាំង សឿន ឲ្យធ្វើជាគណៈស្រុកព្រែកប្រសប់ ប៉ុន្តែ សឿន បដិសេធព្រោះគាត់គិតថា មិនមានសមត្ថភាពគ្រប់គ្រាន់ ។ ក្រោយមក ម៉េត ក៏ប្តូរ សឿន ឲ្យទៅគ្រប់គ្រងមន្ទីតំបន់ក្រចេះ ដែលមានទីស្នាក់ការនៅភូមិខ្សារ ឃុំដា ស្រុកក្រចេះ ។ សឿន គ្រប់គ្រងលើមន្ទីរចំនួន៩ក្នុងខេត្តក្រចេះ មានស្រុកឆ្លូង ស្រុកព្រែកប្រសប់ ស្រុកស្នួល ស្រុកសំបូរ និងស្រុកក្រចេះ ។ នៅទីនោះ សឿន បានហៅប្រធានមន្ទីរស្រុកមកប្រជុំជារៀងរាល់ខែ ដើម្បីរាយការណ៍ពីការងារ និងការខ្វះខាតសម្ភារៈនៅតាមមន្ទីរនីមួយៗដូចជា ថ្នាំពេទ្យ ប្រេង គ្រាប់កាំភ្លើង និងក្រណាត់ ។ សឿន ក៏បានធ្វើរបាយការណ៍ផ្ញើទៅសេនាធិការនិងចាត់តាំងកម្លាំងឲ្យទៅទទួលយកសម្ភារៈពីភ្នំពេញយកមកដាក់នៅក្នុងឃ្លាំងតំបន់ក្រចេះ (បច្ចុប្បន្នសណ្ឋាគារសន្តិភាព) ។ មួយរយៈក្រោយក៏ឃើញមានប្រជាជនជាច្រើនដែលអង្គការជម្លៀសមកពីភ្នំពេញ និងឃុំត្រមូង ស្រុកមេមត់ ខេត្តកំពង់ចាមត្រូវខ្មែរក្រហមចោទថាជាខ្សែរយៈរបស់ វន វ៉េត ។ ក្នុងចំណោមអ្នកជម្លៀសទាំងនេះ ភាគច្រើន

ឈើស្គមស្គាំង ខ្លះឈឺហើម ហើយអ្នកខ្លះស្លាប់ជាបន្តបន្ទាប់ ។ សឿន បានបែងចែកអ្នកជម្លៀសឲ្យទៅស្នាក់នៅសហករណ៍ជាមួយនឹងអ្នកមូលដ្ឋាន និងបែងចែករបបអង្ករ ថ្នាំពេទ្យ មុង និងភួយមួយចំនួនថែមទៀត ។ ក្រោយមក សឿន បាន បញ្ជូនអ្នកជម្លៀសទាំងអស់ឲ្យទៅចូលរួមលើកទំនប់១០៥ ទំនប់បុសលាវ និងធ្វើស្រែ ។ បន្ទាប់ពីប្រមូលផលស្រូវរួច សឿន បានឲ្យកងដឹកជញ្ជូនទៅដឹកស្រូវយកមកទុកនៅតាមសហករណ៍ឃុំសម្រាប់ផ្គត់ផ្គង់រោងបាយ ។ ប៉ុន្តែទោះជាសម្បូរស្រូវយ៉ាងណាក្តី ក៏ប្រជាជននៅតែជួបប្រទះការខ្វះខាតដដែល ។ ខណៈនោះ អង្គការក៏បានចាប់មនុស្សជាច្រើននាក់យកទៅដាក់មន្ទីរសន្តិសុខស្រុកក្រចេះ (បច្ចុប្បន្នវិទ្យាល័យកុសុមៈ) ដោយចោទថា យកអង្ករ លាក់ទុកដើម្បីផ្តល់ឲ្យកងទ័ពយួនដែលបង្កប់ខ្លួននៅក្នុងខេត្តក្រចេះ ។ បន្ទាប់ពីឃុំឃាំងនិងសួរចម្លើយរួចហើយ អ្នកទោសប្រមាណជា២០នាក់ត្រូវបានសម្លាប់នៅទីនោះ ។ ចំណែកប្រជាជនដែលរស់នៅក្នុងទីរួមខេត្តក្រចេះត្រូវអង្គការជម្លៀសឲ្យទៅរស់នៅភូមិរកាកណ្តាល ភូមិក្រគរ និងភូមិអូរឫស្សី ។ ចំណែកអតីតអ្នករដ្ឋការ ទាហាន ប៉ូលិស គ្រូបង្រៀនសម័យ លន់ នល់ ត្រូវបញ្ជូនទៅលត់ដំនៅសហករណ៍ខ្ទាន់ពីដែលជាកន្លែងគ្រុនចាញ់ខ្លាំង ។ ឪពុករបស់ សឿន ក៏ត្រូវប្រធានភូមិចោទប្រកាន់ថា លួចរបស់សមូហភាព ហើយត្រូវចាប់ខ្លួនដោយសារតែគាត់បានយកពងមាន់ទៅស្ងោរហូប ។ ប៉ុន្តែដោយ សឿន មានតួនាទីនៅក្នុងជួរកងទ័ពទើបអង្គការបញ្ជាឲ្យដោះលែងវិញ ។ នៅខែធ្នូ ១៩៧៨ មានការវាយប្រហារជាមួយនឹងកងទ័ពវៀតណាមនៅតាមបណ្តោយព្រំប្រទល់ស្រុកស្នួលបណ្តាលឲ្យកងទ័ពស្លាប់និងរបួសជាច្រើន ហើយខ្លះត្រូវបញ្ជូនទៅវះកាត់ជាបន្ទាន់នៅមន្ទីរពេទ្យវាលវង់ ខេត្តក្រចេះដែលមានបុគ្គលិកពេទ្យ៥០នាក់បម្រើការងារ ។ ចំពោះអ្នករបួសធ្ងន់ដែលគ្រូពេទ្យតំបន់មិនអាចធ្វើការវះកាត់បាន សឿន បានផ្ញើទូរលេខទៅប្រធានមន្ទីរពេទ្យដោយឲ្យយកអ្នកជំងឺដឹកតាមយន្តហោះទៅព្យាបាលនៅមន្ទីរពេទ្យ១៧ មេសា (មន្ទីរពេទ្យរុស្ស៊ីសព្វថ្ងៃ) ។ ជារៀងរាល់ខែ សឿន ត្រូវទៅចូលរួមប្រជុំនៅភ្នំពេញដើម្បីរាយការណ៍ពីការងារនិងសកម្មភាពខ្លាំង ។ ក្រោយមក មឿន ដែលជាប្រធានយោធាតំបន់ក្រចេះត្រូវអង្គការចាប់ខ្លួនដោយចោទថាជាខ្សែរយៈយួន ហើយអង្គការក៏ចាត់តាំងឲ្យ សឿន គ្រប់គ្រងកងទ័ពជំនួសវិញ ។ នៅចុងខែធ្នូ ឆ្នាំ១៩៧៨ មានការប្រយុទ្ធគ្នាកាន់តែខ្លាំងនៅសមរភូមិតាមបណ្តោយព្រំប្រទល់ស្រុកស្នួល ។ នៅពេលនោះមានកប៉ាល់ដឹកគ្រឿងសព្វាវុធ និងផ្ទះប្រជាជនជាច្រើនខ្នងនៅក្នុងស្រុកព្រែកប្រសប់ និងទីរួមខេត្តក្រចេះត្រូវកងទ័ពវៀតណាមបាញ់លិចនិងឆេះអស់ផ្ទះជាច្រើនខ្នង ។ ដោយឃើញសភាពការណ៍ មិនអាចទប់ទល់បាន សឿន បានបញ្ជាឲ្យដកទ័ពថយរួចរត់គេចខ្លួនទៅនៅស្រុកសណ្តាន់ និងស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ នៅទីនោះ សុន សេន និង កែ ពក បានត្រៀមរៀបចំទ័ពសាជាថ្មី ដោយបូកបញ្ចូលទ័ពភូមិភាគកណ្តាលជាមួយនឹងទ័ពតំបន់ក្រចេះរាប់ពាន់នាក់ទៀត ។

នៅខែមេសា ឆ្នាំ១៩៨០ ប៉ុល ពត បញ្ជាឲ្យដកទ័ព៧០០នាក់ក្នុងនោះមាននារី១០០នាក់ទៅបោះទីតាំងនៅខេត្តបាត់ដំបង ។ នៅទីនោះខ្មែរក្រហមបានបែងចែកជាច្រើនតំបន់ ដើម្បីប្រគល់ឲ្យកម្មាភិបាលបដិវត្តន៍គ្រប់គ្រង ។ ពេលនោះ សឿន បានឡើងទៅដាក់ទ័ពនៅលើភ្នំដងរែកក្រោមការគ្រប់គ្រងរបស់ កែ ពក ប្រធានកងពលនិងបែងចែកវរៈសេនាតូចគ្រប់គ្រងឃុំ ចំណែកវរៈសេនាធំ គ្រប់គ្រងស្រុកទាំងមូល ។ ក្រោយមក សឿន ទទួលបានការចាត់តាំងឲ្យមកគ្រប់គ្រងលើឃុំចំនួន៦ ក្នុងស្រុកព្រែកប្រសប់ និងឃុំចំនួន២ក្នុងស្រុកសំបូរ ដើម្បីចាំស្ទាក់បាញ់ប្រធានភូមិប្រធានឃុំដែលជាសមាជិកនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងកងទ័ពវៀតណាម ។

នៅឆ្នាំ១៩៨៩ រដ្ឋាភិបាលរដ្ឋកម្ពុជាចោទថា សឿន បានធ្វើសកម្មភាពប្រឆាំង ហើយចាប់ឃុំឃាំងអស់រយៈពេល១៨ខែ ។ បន្ទាប់ពីបោះឆ្នោតឆ្នាំ១៩៩៣ គាត់ក៏បានផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាល ហើយរស់នៅជុំបងប្អូននិងរៀបការប្រពន្ធ ។ សឿន បានបញ្ជាក់ថា តុលាការខ្មែរក្រហមគួរតែកាត់ទោសកម្មាភិបាលថ្នាក់ក្រោមដែលជាអ្នកគ្រប់គ្រងផ្ទាល់ និងចោទប្រកាន់ប្រទេសនានាដែលគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យដើម្បីបង្ហាញឲ្យឃើញមុខមាត់ពិតនៃអ្នកដែលសមគំនិតប្រព្រឹត្តអំពើឃោរឃៅនិងអ្នកកាប់សម្លាប់ប្រជាជនស្លូតត្រង់ ។ សឿន ក៏សំណូមពរឲ្យតុលាការកាត់ទោសឲ្យបានឆាប់ ព្រោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនបានស្លាប់បាត់បង់ជីវិត និងខ្លះទៀតកាន់តែមានវ័យចាស់ជរាណាស់ទៅហើយ ។

**សោម ប៊ុនថន**

# កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម

*នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ សហគមន៍អឺរ៉ុបជំរុញឲ្យអង្គការសហប្រជាជាតិកុំបោះបង់ការចរចាជាមួយកម្ពុជាស្តីពីការបង្កើតតុលាការកាត់ទោសខ្មែរក្រហម ។*

*សមាជិករដ្ឋសភា១៨រូបរបស់គណបក្ស សម រង្ស៊ី សុំឲ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមន្ត្រីរដ្ឋាភិបាលកំពូល២រូបទៀតបង្ហាញខ្លួននៅរដ្ឋសភាជាតិដើម្បីពន្យល់ពីមូលហេតុបរាជ័យក្នុងការចរចាជាមួយអង្គការសហប្រជាជាតិស្តីពីតុលាការកាត់ទោសខ្មែរក្រហម ។*

*នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០២ យោងតាមសេចក្តីប្រកាសរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិលេខ E/CN.4/ 2002/89 ចែងថាៈ*

*កថាខណ្ឌទី១៨ ៖ នឹងមានការស្នើទៅរដ្ឋាភិបាលកម្ពុជាដើម្បីធានាថា មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនឹងត្រូវយកមកកាត់ទោសចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជា ដើម្បីឲ្យស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងស្របទៅតាមនីតិវិធី ។ កិច្ចការនេះតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិសហការគ្នា ហើយអំពាវនាវដល់ភាគីទាំងពីរឲ្យធ្វើការពិភាក្សាឡើងវិញស្តីពីការបង្កើតតុលាការកាត់ទោសខ្មែរក្រហម និងអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យផ្តល់ជំនួយការក្នុងការដោះស្រាយបញ្ហានេះ ។*

*នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ លោក កូហ្វី អាណាន់ និយាយថា ប្រទេសកម្ពុជាត្រូវតែផ្លាស់ប្តូរជំហររបស់ខ្លួនប្រសិនបើចង់ឲ្យអង្គការសហប្រជាជាតិជួយបង្កើតតុលាការឧក្រិដ្ឋកម្មសង្គ្រាមដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ឯកអគ្គរដ្ឋទូតចំនួន១៧រូបបានមកជួបខ្ញុំនិយាយពីរឿងនេះ ហើយអ្នកទាំងនោះយល់ថាយើងគួរតែពិចារណាឡើងវិញ ។ ខ្ញុំបានណែនាំគេថា វានឹងមានប្រសិទ្ធភាពប្រសិនបើគេធ្វើសំណើទៅទីក្រុងភ្នំពេញ ហើយបញ្ចុះបញ្ចូលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឲ្យផ្លាស់ប្តូរជំហរ និងឥរិយាបថរបស់លោក ហើយផ្ញើសារជាក់លាក់មួយទៅគាត់ថា លោកនាយករដ្ឋមន្ត្រីចាប់អារម្មណ៍ទៅលើតុលាការដែលគួរឲ្យទុកចិត្តមួយ ស្របទៅតាមបទដ្ឋានអន្តរជាតិដែលនឹងត្រូវចាប់ផ្តើមនៅទីនោះ ។*

*នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ ក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាសាលាក្តីខ្មែរក្រហមថ្លែងថា សេចក្តីថ្លែងការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ ឆ្លុះបញ្ចាំងពីការយល់ច្រឡំជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ។ ច្បាប់ខ្មែរក្រហមដែលជាលទ្ធផលនៃការចរចាទាំងនោះ ផ្តល់ការត្រួតពិនិត្យ និងតុល្យភាពរវាងចំនួនសមាជិក និងអំណាចសម្រេចចិត្តរបស់ចៅក្រមកម្ពុជា និងបរទេស ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញា ហើយផ្តល់ការធានាសិទ្ធិស្របច្បាប់ឲ្យចុងចោទ ។ កម្ពុជាបានបង្ហាញឆន្ទៈដើម្បីរៀបចំឲ្យមានសិទ្ធិដែលចែងលម្អិតនៅក្នុងមាត្រានៃកិច្ចសហប្រតិបត្តិការ ។ អង្គការសហប្រជាជាតិមិនបានរកឃើញការរំលោភបំពានដល់បទដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិណាមួយឡើយនៅក្នុងច្បាប់ខ្មែរក្រហមរបស់កម្ពុជា ហើយក៏មិនបានឆ្លើយតបទៅនឹងលិខិតរបស់រាជរដ្ឋាភិបាលកម្ពុជាដែលផ្ញើនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ ដែលនៅក្នុងនោះការឆ្លើយតបលម្អិតមួយផ្តោតលើការលើកឡើងចំនួន១១ចំណុចរបស់ឯកឧត្តម ហាន់ កូរ៉ែល ។*

*នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០២ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា អង្គការសហប្រជាជាតិមានពេល៣ខែដើម្បីជជែកឡើងវិញជាមួយកម្ពុជាក្នុងការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ ។ លោកបានថ្លែងថា បើការជជែកនោះមិនលេចរូបរាងតាមពេលកំណត់ កម្ពុជានឹងពិចារណានូវជម្រើសផ្សេងទៀត ដែលអាចជាសាលាក្តីជួយដោយបរទេស*

ឬសាលាក្ដីខ្មែរទាំងស្រុង ដើម្បីនាំយកយុត្តិធម៌ជូនជនរងគ្រោះ ១លាន៧សែននាក់ ដែលបានស្លាប់ក្រោមអំពើដ៏សាហាវឃោរឃៅនៃអ្នកប្រកាន់លទ្ធិម៉ៅជ្រុលហួសហេតុ ។ ខ្ញុំចង់ប្រកាសម្ដងទៀតថា ទ្វារនៅតែបើកចំហរយៈពេល៣ខែទៀត ។ ភាពអត់ធ្មត់របស់យើងមានដែនកំណត់ ។ យើងមិនចង់ឲ្យនរណាម្នាក់ដើរចេញទេ យើងចង់ឲ្យគេចូលរួម ។

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០២ ទីក្រុងញូវយ៉កដែលល្មីសន្យាបន្តការគាំទ្រដល់សាលាក្ដីចម្រុះខ្មែរក្រហម បើអង្គការសហប្រជាជាតិដកខ្លួនចេញជាអចិន្ត្រៃយ៍ ។ ពេលធ្វើទស្សនកិច្ចនៅកម្ពុជា នាយករដ្ឋមន្ត្រីឥណ្ឌា អាតាល់ ប៊ីហារី វ៉ាជ៉ាយី បានសន្យាថា ឥណ្ឌានឹងបញ្ជូនចៅក្រមសម្រាប់សាលាក្ដី ប្រសិនបើអង្គការសហប្រជាជាតិនៅតែរក្សាការសម្រេចចិត្តដកខ្លួនចេញ ។

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០២ នាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ហាញឆន្ទៈសម្រុះសម្រួលដើម្បីចាប់ផ្ដើមការចរចាដែលជាប់គាំងនោះឡើងវិញ ។ លោកបានផ្ដល់ការធ្វើវិសោធនកម្មច្បាប់សាលាក្ដី ។

នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០២ បេសកជនផ្នែកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ភិទើ ឡឺប្រិច បង្ហាញក្ដីសង្ឃឹមថា សាលាក្ដីនឹងដំណើរការទៅមុខ ហើយនិយាយថា ប្រទេសជាមិត្តមួយចំនួនបន្តព្យាយាមឲ្យរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិរួមគ្នាពិភាក្សាពីសាលាក្ដីរួមមួយ ។ អង្គការសហប្រជាជាតិបដិសេធការស្នើសុំរបស់កម្ពុជាដើម្បីបង្កើតគម្រោងសម្រាប់សាលាក្ដីដែលជាប់គាំងនោះឡើងវិញ ដោយនិយាយថា ខ្ញុំចង់បានការធានាបន្ថែមថា កម្ពុជានឹងធ្វើការកាត់ទោសមេដឹកនាំវាលពិឃាតដោយយុត្តិធម៌ ។

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ លិខិតមួយច្បាប់ពីលោក កូហ្វី អាណាន់ ជូនសម្ដេច ហ៊ុន សែន មានខ្លឹមសារថា «ការសម្រេចចិត្តបញ្ចប់ការចរចានៅថ្ងៃទី៨ ខែកុម្ភៈ គឺដោយសារតែការិយាល័យដែលខ្ញុំបានផ្ដល់ជូនមិនទាន់ចេញជាលទ្ធផល» ហើយថា «ដើម្បីឲ្យខ្ញុំចូលរួមការចរចាទៀត ខ្ញុំត្រូវការការប្រគល់សិទ្ធិពីមហាសន្និបាតឬក្រុមប្រឹក្សាសន្តិសុខ ។ ប្រសិនការប្រគល់សិទ្ធិត្រូវបានផ្ដល់ឲ្យ ខ្ញុំនឹងរៀបចំខ្លួនចូលរួមការងដែកជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីបញ្ចប់កិច្ចការនេះ» ។

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០២ លិខិតមួយច្បាប់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ជូនលោក កូហ្វី អាណាន់ ថ្លែងថា យើងរង់ចាំការសន្និដ្ឋានបន្ទាន់មួយ ដោយសារលោកគិតថា វាចាំបាច់សម្រាប់អង្គការសហប្រជាជាតិដើម្បីវិលត្រឡប់ទៅតុពិភាក្សា ដូច្នេះយើងអាចសន្និដ្ឋានការចរចាជាមួយនឹងកិច្ចព្រមព្រៀងដែលបំពេញចិត្តភាគីទាំងពីរ ហើយបន្ទាប់មកបន្តការពិភាក្សាអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០២ លោក អាណាន់ ប្រាប់កម្ពុជាថា លោកនឹងធ្វើការងដែកឡើងវិញស្ដីពីការកាត់ទោសអំពើប្រល័យពូជសាសន៍ ប្រសិនបើរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចង់ឲ្យលោកធ្វើ ។ លោកបានសរសេរទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា ដើម្បីឲ្យគាត់ចូលរួមការចរចា គាត់ត្រូវការការប្រគល់សិទ្ធិច្បាស់លាស់ពីមហាសន្និបាត ឬក្រុមប្រឹក្សាសន្តិសុខ ។

នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០២ កិច្ចប្រជុំនៅទីក្រុងញូវយ៉ក រៀបចំដោយជប៉ុនដែលប្រារព្ធនៅទីស្នាក់ការគណៈកម្មាធិការជប៉ុនដោយមានការចូលរួមពីប្រទេសចាប់អារម្មណ៍ រួមមាន បារាំង ចក្រភពអង់គ្លេស កាណាដា អូស្ត្រាលី សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប កូរ៉េខាងត្បូង ជប៉ុន និងប្រទេសអាស៊ាន ហ្វីលីពីន សិង្ហបុរី ថៃ ឥណ្ឌូនេស៊ី និងកម្ពុជា ។ ជាការប្រជុំលើកដំបូងដើម្បីផ្លាស់ប្ដូរយោបល់អំពីអ្វីដែលសហគមន៍អន្តរជាតិអាចធ្វើដើម្បីចរចាឡើងវិញ ។

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០២ មហាសន្និបាតរបស់អង្គការសហប្រជាជាតិអនុម័តនូវដំណោះស្រាយដែលស្នើឲ្យអគ្គលេខាធិការធ្វើការចរចាឡើងវិញដោយគ្មានការពន្យារពេល ដើម្បីសម្រេចកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជាផ្អែកលើការចរចាពីមុន និងដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញស្របតាមវិធាននៃដំណោះស្រាយបច្ចុប្បន្ន ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្ដើមធ្វើការបានឆាប់រហ័ស ។ ដំណោះស្រាយត្រូវបានអនុម័តដោយមានសំឡេងចំនួន៣៩អនុបវាទ ។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០២ លោក ខៀវ សំផន និយាយថា មេដឹកនាំខ្មែរក្រហមថ្នាក់លើដទៃទៀតត្រៀមខ្លួនផ្ដល់ភស្តុតាងស្ដីពីការងារផ្ទៃក្នុងនៃរបបម៉ៅជ្រុលនិយមដ៏អាថ៌កំបាំង

នេះដែលដឹកនាំដោយបងធំទី១ ប៉ុល ពត ប្រសិនបើគណៈកម្មាធិការស្វែករកការពិតបែបអាហ្វ្រិកខាងត្បូងត្រូវបានបង្កើតឡើង ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០២ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា រដ្ឋាភិបាលរបស់លោកកំពុងរង់ចាំការអនុម័តដំណោះស្រាយនៅសប្តាហ៍ខាងមុខ ។ អ្វីដែលយើងព្រួយបារម្ភគឺការរស់រានរបស់ប្រជាជនកម្ពុជាដែលរួចផុតពីកណ្តាប់ដៃរបស់ ប៉ុល ពត ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២ អង្គការសហប្រជាជាតិអនុម័តការប្រគល់សិទ្ធិដែលតម្រូវឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ត្រឡប់ទៅតុចរចាពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជាវិញ ។ ដំណោះស្រាយតម្រូវឲ្យលោក អាណាន់ ជជែកសាជាថ្មី ដោយគ្មានការពន្យារពេលដែលអនុម័តដោយការបោះឆ្នោតដែលមានសំឡេងចំនួន១៥០យល់ព្រមនិង៣០អនុបវាទ ។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០២ បែនសុន សម័យ មេធាវីរបស់ តាម៉ុក ស្នើឲ្យដោះលែងកូនក្តីគាត់ជាបណ្តោះអាសន្ន ដោយសំអាងលើបញ្ហាសុខភាព និងមនុស្សធម៌ ។

នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២ សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ មានព្រះបន្ទូលថា រដ្ឋាភិបាលត្រូវតែធ្វើសម្បទានដល់អង្គការសហប្រជាជាតិ ប្រសិនបើចង់ឲ្យការជជែកពីសាលាក្តីខ្មែរក្រហមដំណើរការទៅមុខ ។ ទាំងអង្គការសហប្រជាជាតិ និងកម្ពុជាបានដឹងពីជំហររបស់គ្នារួចហើយ ។ បើយើងត្រឡប់ទៅជជែកពីទិដ្ឋភាពដដែល ដែលជាជំហរនាំឲ្យយើងជាប់គាំងដូចពីមុន យើងអាចនឹងគ្មានការចរចា ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០០៣ ជាការឆ្លើយតបនឹងការអញ្ជើញរបស់អគ្គលេខាធិការ គណប្រតិភូមួយក្រុមរបស់កម្ពុជាដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រី សុខ អាន បានទៅដល់ក្រុងញូវយ៉ក និងរៀបចំធ្វើកិច្ចប្រជុំចំនួន៧លើក ទីមួយៈ ជួបជាមួយលោកអគ្គលេខាធិការនិងចំនួន៦លើកទៀត ជួបជាមួយតំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិដែលដឹកនាំដោយ លោក ហាន់ កូរ៉ែល ដើម្បីរៀបចំការចរចាឡើងវិញសម្រាប់ការកាត់ទោសខ្មែរក្រហមស្របតាមដំណោះស្រាយរបស់មហាសន្និបាតលេខ ៥៧/២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ២០០២ ។

នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងកម្ពុជាសម្រេចកិច្ចព្រមព្រៀង ដើម្បីបង្កើតតុលាការប្រល័យពូជសាសន៍ពិសេសមួយសម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ ក្រុមអ្នកច្បាប់របស់អង្គការសហប្រជាជាតិ និងកម្ពុជាបានយល់ព្រម និងគាំទ្រមាត្រានៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងទទួលបានការយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងរដ្ឋសភាជាតិកម្ពុជាមុនពេលការងារអាចបន្តធ្វើដើម្បីបង្កើតតុលាការមួយ ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៣ ស្ថានទូតចក្រភពអង់គ្លេសនៅទីក្រុងភ្នំពេញបានចេញសេចក្តីប្រកាសព័ត៌មានមួយស្វាគមន៍ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងសម្តែងការប្តេជ្ញាចិត្តបន្តគាំទ្រតុលាការដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិ ។ ជាការផ្តល់មតិលើកិច្ចព្រមព្រៀង រដ្ឋមន្ត្រីក្រសួងការបរទេស ម៉ៃអូប្រៀន មានសុទិដ្ឋិនិយមថា នៅទីបំផុតសាលាក្តីនឹងលាតត្រដាងសម័យកាលសោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជានៅពេលថ្មីៗ និងនាំយកអ្នកដែលទទួលខុសត្រូវសំខាន់ជាងគេដែលប្រព្រឹត្តអំពើព្រៃផ្សៃក្រោមរបបខ្មែរក្រហមមកឲ្យតុលាការជំនុំជម្រះ ។ វានឹងផ្តល់ឱកាសមួយដល់ប្រជាជនកម្ពុជាអស់ចិត្តនឹងរឿងអតីតកាល ហើយដើរទៅរកការផ្សះផ្សាជាតិឡើងវិញ ។

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៣ អង្គការលើកលែងទោសអន្តរជាតិនិយាយថា មានការព្រួយបារម្ភយ៉ាងខ្លាំងពីបទបញ្ញត្តិនៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង “ដែលឆ្លុះបញ្ចាំងពីភាពផុយគ្នារវាងច្បាប់និងបទដ្ឋានអន្តរជាតិនាពេលបច្ចុប្បន្ន” ។ មានការអះអាងថា កិច្ចព្រមព្រៀងមានភាពខ្វះចន្លោះច្រើនដែលរារាំងមិនឲ្យអង្គការសហប្រជាជាតិចុះហត្ថលេខាលើកិច្ចព្រមព្រៀងនោះ ដរាបណាមានការត្រួតពិនិត្យឡើងវិញយ៉ាងត្រឹមត្រូវ ។ ទោះជាយ៉ាងនេះក្តី សេចក្តីព្រាងបទបញ្ញត្តិដែលអង្គការលើកលែងទោសអន្តរជាតិស្វាគមន៍នឹងមិនរាប់បញ្ចូលការលើកលែងទោស ឬអនុគ្រោះទោសនរណាម្នាក់ដែលត្រូវធ្វើការស៊ើបអង្កេតឬចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលមានក្នុងកិច្ចព្រមព្រៀងឡើយ ។ ខ-មួយដែលបាន អនុវត្តចំពោះអ្នកដែលត្រូវផ្តល់ការលើកលែងទោសដោយអាជ្ញា

ធរកម្ពុជា (សេចក្តីព្រាងច្បាប់មាត្រា១១) បទបញ្ញត្តិដែលបណ្តឹងទាំងអស់ត្រូវធ្វើឡើងជាសាធារណៈ (សេចក្តីព្រាងមាត្រា១២.២) និងការមិនរួមបញ្ចូលទោសប្រហារជីវិត (មាត្រា១០) ដែលស្របតាមច្បាប់អន្តរជាតិដទៃទៀត ។

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៣ គណៈរដ្ឋមន្ត្រីកម្ពុជាយល់ព្រមចំពោះសេចក្តីព្រាងនៃកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិស្តីពីការបង្កើតតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ អគ្គលេខាធិការអង្គការសហប្រជាជាតិចេញរបាយការណ៍មួយលេខ (A/57/769) នៅឯមហាសន្និបាត ដោយធ្វើការរិះគន់ទៅលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ ។ លោកបានប៉ាន់ប្រមាណថា អង្គជំនុំជម្រះវិសាមញ្ញអាចនឹងចំណាយជាង១៩លានដុល្លារ ដូច្នេះលោកបានស្នើមូលនិធិរួមរបស់អង្គការសហប្រជាជាតិឲ្យផ្តល់វិភាគទានកំណត់ដែលមិនមែនជាការស្ម័គ្រចិត្ត ។

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៣ គណៈកម្មាធិការទីបីនៃមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តលើដំណោះស្រាយដោយយល់ស្របចំពោះកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ស្តីពីការកាត់ទោសឧក្រិដ្ឋកម្មក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក្រោមច្បាប់របស់កម្ពុជា ។

នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៣ គណៈកម្មាធិការទីបីអនុម័តដំណោះស្រាយ ដោយយល់ស្របនឹងសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ហើយថ្លែងថា អង្គការសហប្រជាជាតិគួរតែផ្តល់មូលនិធិទៅអង្គជំនុំជម្រះវិសាមញ្ញដោយវិភាគទានស្ម័គ្រចិត្ត ។

នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ កិច្ចប្រជុំពេញអង្គលើកទី៨៥ នៃមហាសន្និបាតលើកទី៥៧ អនុម័តដំណោះស្រាយលេខ 57/228B ដោយយល់ព្រមចំពោះសេចក្តីព្រាងនៃកិច្ចព្រមព្រៀង និងវិភាគទានស្ម័គ្រចិត្ត ។

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចុះហត្ថលេខានៅឯសាលមហោស្រពចតុមុខក្រុងភ្នំពេញ ។

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាដាក់ជូនកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់ទោសឧក្រិដ្ឋកម្មក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យក្រោមច្បាប់របស់កម្ពុជាទៅរដ្ឋសភាជាតិ ។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ ប្រទេសអូស្ត្រាលី សន្យាផ្តល់ប្រាក់១លាន ៥សែនដុល្លារអូស្ត្រាលី សម្រាប់អង្គជំនុំជម្រះវិសាមញ្ញបន្ថែមលើទឹកប្រាក់២៦៦.០០០ដុល្លារអូស្ត្រាលី ដែលបានផ្តល់ក្នុងទម្រង់ជាជំនួយបច្ចេកទេសទាក់ទងនឹងការកាត់ទោសខ្មែរក្រហម ។

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣ លោកស្រី ខៀវ ប៉ុណ្ណារី ប្រពន្ធទីមួយរបស់អតីតមេដឹកនាំខ្មែរក្រហម ប៉ុល ពត ស្លាប់ក្នុងអាយុ៨៣ឆ្នាំ នៅទីក្រុងប៉ៃលិន ។

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៣ ឯកសាររាប់ពាន់សន្លឹកអះអាងពីអំពើឃោរឃៅដែលធ្វើឡើងដោយខ្មែរក្រហមត្រូវបានបញ្ជូនទៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសបារាំង បន្ទាប់ពីមានការគំរាមកំហែងផ្នែកសន្តិសុខជាបន្តបន្ទាប់ ។ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាលោក ឆាំង យុ និយាយថា ភស្តុតាងប្រមាណ៧០ភាគរយត្រូវបានរក្សាយ៉ាងមានសុវត្ថិភាពនៅប្រទេសទាំងនោះ ។

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៣ បន្ទាប់ពីសិក្សាគម្រោងរយៈពេល៣ឆ្នាំសម្រាប់សាលាក្តី អង្គការសហប្រជាជាតិយល់ព្រមថា ការចំណាយគួរតែអស់៤០លានដុល្លារ ។ លោក ឱម យិនទៀង ទីប្រឹក្សានាយករដ្ឋមន្ត្រី ហ៊ុន សែន និង ជាសមាជិកក្រុមការងារសាលាក្តីបាននិយាយថា អង្គការសហប្រជាជាតិស្នើលុយចំនួន ២០លានដុល្លារ ចំណែកកម្ពុជាចំណាយ ២០លានដុល្លារ ។

នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៣ សភាសហរដ្ឋអាមេរិកអនុម័តដំណោះស្រាយមួយលេខ (H. CON. RES. 83) ដោយគោរពដល់ជនរងគ្រោះនៃសម័យខ្មែរក្រហម ។ ដំណោះស្រាយបញ្ជាក់ថាសហរដ្ឋអាមេរិកប្តេជ្ញាបន្តស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ សមាជិកសភាសហរដ្ឋអាមេរិក លោក ដាណា រ៉ូរ៉ាបាឆឺ និយាយថា ដំណោះស្រាយនេះជាសញ្ញានៃការទទួលស្គាល់នូវតួនាទីរបស់អាមេរិកក្នុងជម្លោះនៅឥណ្ឌូចិនពេលដែលរបបខ្មែរក្រហមបានឡើងកាន់អំណាច ។

នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៣ លោក ខាស្តែន ហ៊ែរែល ប្រធានក្រុមរៀបចំសាលាក្តីដែលមានសមាជិក៥នាក់និយាយថា ទាំងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាកំពុងចាប់ផ្តើមធ្វើការសន្មតថា អង្គជំនុំជម្រះវិសាមញ្ញនឹងចាប់ប្រតិបត្តិការងារនៅឆ្នាំ២០០៤ ។

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ លោក កូហ្វី អាណាន់ និយាយថា ដំណើរការនៃការបង្កើតសាលាក្តីនឹងចាប់ផ្តើមបានលុះត្រាតែការសន្យាសម្រាប់រយៈពេល៣ឆ្នាំដំបូងនៃប្រតិបត្តិការរបស់តុលាការត្រូវបានទទួលស្គាល់ ហើយទឹកប្រាក់សម្រាប់ប្រតិបត្តិការឆ្នាំដំបូងត្រូវបានតម្កល់គ្រប់គ្រាន់នៅក្នុងមូលនិធិរួម ។

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៣ នាយកគម្រោងអ្នកការពារក្តីកម្ពុជាមានប្រសាសន៍ថា លោក ខៀវ សំផន គណៈប្រធានរដ្ឋសម័យខ្មែរក្រហមបានមកការិយាល័យរបស់គាត់ដើម្បីស្វែងរកជំនួយផ្នែកច្បាប់នៃគម្រោងសាលាក្តីកាលពីដើមឆ្នាំនេះ ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៣ ប្រទេសអូស្ត្រាលីចេញសេចក្តីថ្លែងការណ៍ថា នឹងផ្តល់ប្រាក់ ២លាន ១សែនដុល្លារ សម្រាប់តុលាការចម្រុះកម្ពុជា និងអន្តរជាតិ ។

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៣ ស្របតាមការអំពាវនាវសុំជំនួយផ្នែកច្បាប់របស់លោក ខៀវ សំផន អ្នកជិតដិតរបស់គាត់ដែលជាអ្នកបដិវត្តន៍ដូចគ្នា លោក នួន ជា និយាយថា គាត់នឹងតំណាងឲ្យខ្លួនគាត់ ប្រសិនបើគាត់ត្រូវកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍វិញ ។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៣ នៅក្នុងលិខិតចំហមួយច្បាប់ លោក ខៀវ សំផន បដិសេធការរួមចំណែកក្នុងការសម្លាប់ប្រជាជនខ្មែរជាង១លាននាក់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែគាត់សារភាពថារបបនេះបានធ្វើការសម្លាប់ជាប្រព័ន្ធ ។

នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៤ ក្រុមអ្នកច្បាប់របស់អង្គការសហប្រជាជាតិមកដល់ប្រទេសកម្ពុជា ដើម្បីរៀបចំគម្រោងសម្រាប់សាលាក្តីមុនពេលប្រគល់សំណើសុំថវិកាទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៤ សម្តេចនរោត្តម សីហនុ មានព្រះទ័យទិតៀនចំពោះការបោះពុម្ពផ្សាយចម្លើយកសិណសាក្សីរបស់អតីតមេដឹកនាំខ្មែរក្រហមដែលក្នុងនោះបានអះអាងថាពួកគេគ្មានទោសពីបទប្រព្រឹត្តអំពើឃោរឃៅនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ ។ ដោយហៅឧក្រិដ្ឋកម្មនោះថា "អាក្រក់ណាស់" សម្តេចនរោត្តម សីហនុ បានអះអាងថា បើមេដឹកនាំខ្មែរក្រហមត្រូវបានប្រកាសជាសាធារណៈថាគ្មានទោសកំហុស មេដឹកនាំទាំងនេះក៏មិនចាំបាច់មានការលើកលែងទោសចំពោះបទឧក្រិដ្ឋនោះដែរ ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៤ លោក ខាស្តែន ហ៊ែរែល ប្រធាននៃគណៈប្រតិភូអង្គការសហប្រជាជាតិនិយាយថា ក្នុងអំឡុងបេសកកម្មលើកទីពីរមកទីក្រុងភ្នំពេញ ដើម្បីរៀបចំការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលសាលាក្តីនឹងចំណាយអស់ថវិកាយ៉ាងច្រើនគឺ៥០លានដុល្លារ ។ ហ៊ែរែល បានបដិសេធមិនផ្តល់នូវតួលេខថវិកាច្បាស់លាស់ដោយនិយាយថា ធាតុពិតនៃការចំណាយខ្លះមិនត្រូវបានដឹងទាំងស្រុងនោះទេ ។

នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៤ កិច្ចប្រជុំសភាអាមេរិកលើកទី១០៨(2nd Session-H.CON.RES.399) ដោយមានការដោះស្រាយពីតំណាងរដ្ឋសភានៅក្នុងកិច្ចប្រជុំនេះគឺ ទីមួយៈ ជំរុញឲ្យប្រធានាធិបតីលើកទឹកចិត្តសភាជាតិកម្ពុជាឲ្យផ្តល់សច្ចាប័នចំពោះកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតសាលាក្តីមួយដែលជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលកើតឡើងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនិងកាត់ទោសមេដឹកនាំនៅមានជីវិតក្នុងរបបខ្មែរក្រហមដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ និងទីពីរៈ ជំរុញឲ្យប្រធានាធិបតីផ្តល់ការគាំទ្រក្នុងការបង្កើត និងការផ្តល់ថវិកាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញស្របតាមច្បាប់យុត្តិធម៌ដើម្បីប្រឆាំងនឹងអំពើប្រល័យពូជសាសន៍កម្ពុជា ។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៤ នៅទីក្រុងឡុងប៊ិច អ្នកច្បាប់កាលីហ្វូនីញ៉ាទទូចដល់ប្រជាធិបតី ប៊ូស ឲ្យជួយផ្តល់មូលនិធិសម្រាប់សាលាក្តីដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅមានជីវិត ។ សមាជិកសភា ដូនីតា មីលែនដឺ ម៉ាកដូណាល់ និង

ដាណា រ៉ូរ៉ាប៉ាឆឺ អ្នកទាំងពីរតំណាងឲ្យសហគមន៍មួយក្នុងចំណោមសហគមន៍កម្ពុជាធំជាងគេបាននិយាយថា យុត្តិធម៌សម្រាប់អ្នកនៅរស់រានពីសម័យខ្មែរក្រហមហួសពេលកំណត់ហើយ ។

នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨ អ្នកដឹកនាំពលរដ្ឋ១៧នាក់ និងសមាជិកសភាចុះហត្ថលេខាលើញត្តិមួយសុំឲ្យព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ចេញដីកាចាប់ខ្លួនមេដឹកនាំខ្មែរក្រហមកំពូលដែលនៅរស់៣នាក់ ។

នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៨ រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ខុលីន ដូវែល និយាយថា ចៅក្រមអន្តរជាតិអាចនឹងផ្តល់ការជឿទុកចិត្តចំពោះសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ លោក ដូវែល កំពុងធ្វើជាសាក្សីនៅក្នុងសវនាការនៅកិច្ចប្រជុំសភា ដែលក្នុងនោះសមាជិកសភាម្នាក់បានសួរថា ហេតុអ្វីបានជាសហរដ្ឋអាមេរិកគាំទ្រសាលាក្តីខ្មែរក្រហមដែលខ្វះចន្លោះហើយផ្អែកលើប្រព័ន្ធច្បាប់ដ៏ទន់ខ្សោយ ។ ខ្ញុំមានការព្រួយបារម្ភដូចដែលអ្នកមាន អំពីអត្តិភាពនៃយុត្តិធម៌ ទោះបីជាប្រជាជនខ្មែរអាចនឹងមិនចង់បានយុត្តិធម៌ដូចដែលយើងចង់បានក៏ដោយ ។ ប៉ុន្តែយើងនឹងមានចៅក្រមអន្តរជាតិក្នុងតុលាការ ឬយ៉ាងហោចណាស់កូនក្តីចាស់ៗទាំងនោះនឹងត្រូវបាននាំខ្លួនទៅកាន់សាលាក្តី ។

នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៨ អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍សុំឲ្យព្រះរាជអាជ្ញាខេត្តបាត់ដំបង ខេត្តបន្ទាយ-មានជ័យ និងខេត្តសៀមរាប នាំពាក្យបណ្តឹងប្រឆាំងលោក ខៀវ សំផន និង នួន ជា ហើយសុំឲ្យអង្គចៅក្រមចេញដីកាស្របតាមច្បាប់សវនាការ ។ ចំពោះលោក អៀង សារី ចាំបាច់ត្រូវត្រួតពិនិត្យព្រះរាជក្រឹត្យលើកលែងទោស ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ សម្តេចនរោត្តម សីហនុ កត់សម្គាល់ក្នុងខួបលើកទី២៩ ដែលក្រុងភ្នំពេញធ្លាក់ក្នុងដៃខ្មែរក្រហមដោយអំពាវនាវឲ្យមានការកប់អដ្ឋិធាតុជនរងគ្រោះនៃវាលពិឃាដ និងបោះបង់ចោលសាលាក្តីគាំទ្រដោយអង្គការសហប្រជាជាតិដែលត្រូវបានស្នើឡើង ។ ព្រះអង្គទ្រង់លិខិតជាភាសាខ្មែរថា «យើងជាពុទ្ធសាសនិកជនដែលមានជំនឿ និងប្រពៃណីកប់សាកសព ហើយនាំយកផ្នែកនៅសល់ទៅដាក់ក្នុងចេតិយនៅវត្តតាំងពីបុរាណមក ។ ព្រះអង្គក៏បានតិទៀនដែរថា «សាលាក្តីខ្មែរក្រហមគ្រាន់តែជាការតិះដៀលដល់ជនរងគ្រោះដែលបានស្លាប់ទៅប៉ុណ្ណោះ» ។ ព្រះអង្គបញ្ជាក់ថា «សហគមន៍អន្តរជាតិនិងអង្គការសហប្រជាជាតិ ផ្តល់មូលនិធិជាច្រើនសម្រាប់ដំណើរការសាលាក្តីនេះ ។ ខ្ញុំរំពឹងថា នេះគ្រាន់តែជារឿងកំប្លែងនិងជាការតិះដៀលដល់ព្រលឹងជនរងគ្រោះប៉ុណ្ណោះ» ។

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៨ ក្នុងសារមួយក្នុងគេហទំព័ររបស់ព្រះអង្គ សម្តេចនរោត្តម សីហនុ មានព្រះបន្ទូលថា សាលាក្តីខ្មែរក្រហមមិនអាចធ្វើការបានត្រឹមត្រូវ ប្រសិនបើសាលាក្តីនេះមិនធ្វើនៅទីក្រុងឡាអេ ដោយសារប្រព័ន្ធច្បាប់អសមត្ថភាព ។ ពិភពលោកទាំងមូលរួមទាំងសារព័ត៌មានដែលខ្ញុំបានអានជាទៀងទាត់វាយតម្លៃថា អង្គចៅក្រមពុករលួយនិងគ្មានសមត្ថភាព ។

នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៨ លោក ខៀវ សំផន ចេញលិខិតចំហមួយសំដែងពីមតិសាធារណៈចំពោះរូបព្រះអង្គនិងថ្លែងថា ព្រះអង្គទទួលការចាប់អារម្មណ៍ពីប្រជាជនខ្មែរជាច្រើន ។ ជនរួមជាតិកាន់តែច្រើនរួមទាំងព្រះសង្ឃផងបានសំដែងការអាណិតចំពោះខ្ញុំ ហើយខ្ញុំមិនចាំបាច់និយាយអ្វីគ្រប់យ៉ាងដែលអ្នកដទៃបានប្រាប់ខ្ញុំតាមផ្លូវដោយស្នាមញញឹមថាពួកគាត់បានអានសៀវភៅរបស់ខ្ញុំ ។

នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៨ សម្តេចនរោត្តម សីហនុ ចេញព្រះរាជសារមួយច្បាប់ក្នុងគេហទំព័ររបស់ព្រះអង្គ ថា ព្រះអង្គចង់ធ្វើជាសាក្សីនៅឯសាលាក្តីខ្មែរក្រហម ។ ខ្ញុំធ្វើជាសាក្សីនៅមុខតុលាការមិនត្រឹមតែម្តងនោះទេ តែគ្រប់ពេលដែលតុលាការបើកសវនាការសួរចម្លើយអ្នកនេះ និងអ្នកនោះរាល់ថ្ងៃ រាល់សប្តាហ៍ រាល់ខែ រាល់ឆ្នាំដែលខ្ញុំនៅមានជីវិត ។

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៨ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់កម្ពុជា លោក គាត ឈន់ មានប្រសាសន៍ថា គាត់ស្ម័គ្រចិត្តបង្ហាញមុខធ្វើជាសាក្សីនៅឯសាលាក្តីគាំទ្រដោយអង្គការសហប្រជាជាតិដែលត្រូវបានធ្វើឡើង ។ គាត់ថ្លែងថា គាត់នឹងធ្វើជាសាក្សីដើម្បីការពារឈ្មោះគាត់ ប្រសិនបើសាលាក្តីសម្រេចចោទគាត់ពីបទចូលរួមជាមួយខ្មែរក្រហម ។ រដ្ឋមន្ត្រីដែលទទួលការអប់រំនៅប្រទេសបារាំងដើម្បីបម្រើជាអ្នកបកប្រែឲ្យលោក ប៉ុល ពត ដែលបានដឹកនាំចលនាតស៊ូក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ។ **គាត លក្ខិណា**

# មជ្ឈមណ្ឌលឯកសារកម្ពុជាសហការបង្កើតគេហទំព័រឃ្លាំមើល ការវិវត្តតុលាការខ្មែរក្រហម

*កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨នេះគេហទំព័រមួយដែលបង្កើតឡើងដើម្បីឃ្លាំមើលការវិវត្តរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម (www.cambodiatribunal.org) បានចុះផ្សាយលើគេហទំព័ររបស់ខ្លួននូវបទសម្ភាសន៍រវាងលោក បៀល ឃីតធីស (អ្នកយកព័ត៌មានទូរទស្សន៍ អ្នកផលិតកម្មវិធី និងជាអតីតអ្នកអានព័ត៌មានរបស់ទូរទស្សន៍CBS) ជាមួយមនុស្សបីរូបដែលនៅសល់ជីវិតចុងក្រោយបង្អស់ និងដែលធ្លាប់ធ្វើជាព្រះរាជអាជ្ញានៅតុលាការនូរ៉េមប៊ឺកកាត់ទោសថ្នាក់ដឹកនាំរបស់របបណាហ្ស៊ីអ៊ីត្លែរអាល្លឺម៉ង់ ។ បទសម្ភាសន៍នេះគឺចង់បានការយល់ឃើញរបស់អ្នកច្បាប់ទាំងនេះចំពោះដំណើរការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនៅប្រទេសកម្ពុជា នេះបើយោងទៅតាមសេចក្តីជូនដំណឹងជាសាធារណៈមួយនៅលើគេហទំព័រឃ្លាំមើលការវិវត្តតុលាការខ្មែរក្រហម ។*

*សព្វថ្ងៃ អតីតមេដឹកនាំខ្មែរក្រហមចំនួនប្រាំរូបត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដោយតុលាការចម្រុះមួយបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនៅទីក្រុងភ្នំពេញ ។ មេដឹកនាំខ្មែរក្រហមទាំងប្រាំរូបរួមមានៈ កាំង ហ្គេកអ៊ាវ (អតីតប្រធានគុកទួលស្លែងឬស-២១) នួន ជា (អតីតប្រធានរដ្ឋសភា) អៀង សារី (អតីតរដ្ឋមន្ត្រីក្រសួងការបរទេស) អៀង ធីរិទ្ធ (អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងសុខាភិបាល) និង ខៀវ សំផន (អតីតប្រមុខរដ្ឋរបបកម្ពុជាប្រជាធិបតេយ្យ) ។*

*យោងតាមសេចក្តីជូនដំណឹងជាសាធារណៈនោះបានឲ្យដឹងថា លោក ឃីតធីស បានជួបសម្ភាសព្រះរាជអាជ្ញា បេន ហ្វៀរិនស៍, ហេនរី ឃីង, និង វីតនី ហ៊ែរីស ដើម្បីស្វែងរកការយល់ឃើញរបស់អ្នកទាំងនេះអំពីសារៈសំខាន់របស់តុលាការនូរ៉េមប៊ឺកមកលើច្បាប់អន្តរជាតិ អំពីមេរៀនអ្វីខ្លះដែលទទួលបានពីតុលាការនេះ និងថាតើអ្នកទាំងនេះយល់ឃើញបែបណាចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលកំពុងតែមានដំណើរការនៅប្រទេសកម្ពុជា ។*

*នៅពេលសួរថាតើវាមានសារៈសំខាន់ដែរឬទេក្នុងការបង្កើតតុលាការជំនុំជម្រះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងកាលពីសាមសិបឆ្នាំមុននោះ? ព្រះរាជអាជ្ញា បេន ហ្វៀរិនស៍ បានមានប្រសាសន៍ថា «ជាការពិតណាស់ វាមានសារសំខាន់ ព្រោះការជំនុំជម្រះនេះបានប្រាប់ដល់ប្រជាជនកម្ពុជាថា យើងមិនបានបំភ្លេចប្រវត្តិសាស្ត្រដ៏ជូរចត់នោះទេ ។ យើងកំពុងតែព្យាយាមតាមលទ្ធភាពរបស់យើងដើម្បីទទួលស្គាល់ថា អ្វីដែលបានកើតឡើងចំពោះអ្នកទាំងនោះនិងមនុស្សជាទីស្រលាញ់ គឺជាបទឧក្រិដ្ឋកម្ម ហើយយើងនឹងមិនលើកលែងចំពោះសកម្មភាពដែលមិនអាចទទួលយកបាននេះទេ» ។*

*ឆ្លើយតបទៅនឹងសំណួរដូចគ្នានេះ ព្រះរាជអាជ្ញា ហេនរី ឃីង មានយោបល់ថា «សូមមើលឲ្យវែងឆ្ងាយ! តស៊ូកុំរាថយ! យើងមិនដែលបោះបង់ចោលទេនៅនូរ៉េមប៊ឺក...យើងត្រូវគិតពីមនុស្សជំនាន់ក្រោយ....ដោយសារតែអាវុធសម្រាប់បំផ្លិចបំផ្លាញកាន់*



តែសាហាវ រហូតដល់កម្រិតដែលយើងអាចនឹងបំផ្លាញខ្លួនឯង ប្រសិនបើយើងមិនមាននីតិរដ្ឋនៅក្នុងពិភពលោកយើងនេះ» ។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះកិច្ចព្រមព្រៀងសហការជាមួយសារមន្ទីរនិងមជ្ឈមណ្ឌលអប់រំ អ៊ីលីន័រហូឡូខូស *(Illinois Holocaust Museum and Education Center)* នៅខែកញ្ញា ឆ្នាំ ២០០៧ ដែលទទួលជំនួយពីមូលនិធិក្រុមគ្រួសារជេ.ប៊ី និងអ៊ឹម.ខេ ព្រីសគ័រ *(J.B. and M.K. Pritzker Family Foundation)* តាមរយៈមហាវិទ្យាល័យន័រវេសស៊្ទើន *(Northwestern University School of Law's Center for International Human Right)* ហើយគម្រោងនេះមានរយៈពេល២ឆ្នាំ ។ គម្រោងនៃគេហទំព័រតាមឃ្លាំមើលការវិវត្តរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម *(Cambodia Tribunal Monitor)* បានបង្កើតឡើងដើម្បីប្រមូលចងក្រងទុកនូវរាល់ឯកសារដែលទាក់ទងនឹងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងឯកសារទាំងឡាយណាដែលទាក់ទងនឹងរបបខ្មែរក្រហម ដើម្បីងាយស្រួលដល់អ្នកស្រាវជ្រាវ ឬសិស្សនិស្សិតក្នុងការស្វែងរកឯកសារទាំងឡាយក្រោយពីការកាត់ទោសនោះបានបញ្ចប់ ។ ម្យ៉ាងទៀតគេហទំព័រនេះ គឺសម្រាប់ឲ្យមានការពិភាក្សាគ្នាជាសាធារណៈជុំវិញដំណើរការកាត់ទោសរបស់តុលាការចំពោះមេដឹកនាំខ្មែរក្រហម ។ ដើម្បីជួយសម្រួលដល់អ្នកដែលមានចំណាប់អារម្មណ៍ចំពោះដំណើរការតុលាការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហមគេហទំព័រមានចុះផ្សាយជាបីភាសា ៖ ភាសាខ្មែរ អង់គ្លេស និង ភាសាបារាំង ។

ក្នុងរយៈពេលជាង៦ខែមកនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចូលរួមក្នុងដំណើរការនៃការសុំនៅក្រៅឃុំរបស់មេដឹកនាំកំពូលទាំងបី ដែលមាន កាំង ហ្គេកអ៊ាវ ហៅ ឌុច នួន ជា និង ខៀវ សំផន ដើម្បីថតចម្លងនូវគ្រប់ទិដ្ឋភាពទាំងស្រុងរបស់សវនាការយកទៅចាក់ផ្សាយនៅក្នុងគេហទំព័រតាមឃ្លាំមើលការវិវត្តរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក្នុងនោះដែរ មជ្ឈមណ្ឌលក៏បានចុះទៅធ្វើការនៅក្នុងខេត្តមួយចំនួនដូចជា ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ធំ និងខេត្តពោធិ៍សាត់ ដើម្បីផ្សព្វផ្សាយពីដំណើរវិវត្តរបស់តុលាការ និងថតជាវីដេអូអំពីចំណាប់អារម្មណ៍របស់ប្រជាជនជុំវិញការចាប់ខ្លួន និងដំណើរការកាត់សេចក្តីឲ្យនៅក្រៅឃុំ ឬជាប់ឃុំរបស់មេដឹកនាំខ្មែរក្រហម ។

ក្រៅពីគេហទំព័រឃ្លាំមើលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (*www.dccam.org*) សាធារណជនអាចមើលព័ត៌មានថ្មីដែលទាក់ទងនឹងដំណើរការតុលាការខ្មែរក្រហម បទសម្ភាសន៍ជាវីដេអូ ភាពយន្តឯកសារ និងអត្ថបទវិភាគផ្សេងៗនៅលើគេហទំព័រតាមឃ្លាំមើលការវិវត្តរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ **គីម សុវណ្ណដានី**



# របាយការណ៍ពីខេត្តព្រៃវែងៈ គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹង នៅសាលាក្តីខ្មែរក្រហមផ្តោតលើការបោសសម្អាតនៅភូមិភាគបូព៌ា

*តាំងពីខែតុលា ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជា បានដំណើរការគម្រោងជួយជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហមដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដើម្បីប្រាប់អ្នកដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យអំពីសិទ្ធិរបស់ពួកគាត់ក្នុងការចូលរួមក្នុងដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនៃរបបខ្មែរក្រហម ហើយប្រសិនបើពួកគាត់មានបំណងចូលរួម គម្រោងនឹងជួយពួកគាត់ដើម្បីចុះឈ្មោះក្នុងអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាពិសេស សមាជិកក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងដើម្បីបំពេញទម្រង់បែបបទព័ត៌មានជនរងគ្រោះ និងប្រគល់ទៅឲ្យអង្គភាពជនរងគ្រោះដែលរៀបចំដោយអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងប្រតិបត្តិការមិនដល់៦ខែផង គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងបានជួបអ្នកនៅរស់រាប់ពាន់នាក់ ហើយគិតត្រឹមថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៨ បានប្រគល់ទម្រង់បែបបទចំនួន៨៦៨ ទៅអង្គភាពជនរងគ្រោះ ។*

*មិនមែនមានតែគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងតែមួយនោះទេដែលជួយអ្នកនៅរស់ឲ្យចូលរួមក្នុងដំណើរការសាលាក្តី អង្គការក្រៅរដ្ឋាភិបាលរបស់កម្ពុជាមួយចំនួនទៀតបានបង្កើតគំនិតផ្តួចផ្តើមក្នុងការជួយដល់អ្នកដែលនៅរស់ថែមទៀត ដោយអង្គការនីមួយៗបានជួបនឹងសាក្សីសំខាន់ៗ អ្នកដាក់ញត្តិ និងដើមបណ្តឹងរដ្ឋប្បវេណីតាមរបៀបផ្សេងគ្នា ។ ការប្រឹងប្រែងទាំងនេះទទួលបានការយល់ព្រម និងការកោតសរសើរជាច្រើនពីអ្នកដែលនៅរស់និងពីតុលាការ ។*

***ការណែនាំអំពីការដាក់ពាក្យបណ្តឹងនៅភូមិដូនដោក***

*ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៨ គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងបានចុះបំពេញការងារនៅអតីតភូមិភាគបូព៌ា ។ ភូមិភាគបូព៌ាជាភូមិភាគមួយក្នុងចំណោមភូមិភាគធំៗទាំង៦ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខេត្តស្វាយរៀង ព្រៃវែង ប៉ែកខាងកើតខេត្តកំពង់ចាម និងស្រុកឆ្លូង ខេត្តក្រចេះ បង្កើតបានជាភូមិភាគនេះដែលស្ថិតនៅចន្លោះប្រទេសវៀតណាមនៅទិសខាងកើត និងទន្លេមេគង្គនៅទិសខាងលិច ។ ខ្មែរក្រហមបានបែងចែកភូមិភាគនេះជា២០ទៅ២៤តំបន់ ។ យោងតាម ប៊ែន យៀរនិន នៅក្នុងការស្រាវជ្រាវរបស់គាត់នៅភូមិភាគបូព៌ា ប្រជាជននៅពាក់កណ្តាលឆ្នាំ១៩៧៦ មាន១.៧លាននាក់ ដោយគិតទាំងប្រជាជនថ្មីចំនួន៣០០.០០០នាក់ដែលជម្លៀសទៅពីទីក្រុងផង ។*

*ដោយឡែក ក្រុមការងារបានផ្តោតសកម្មភាពនៅតំបន់ព្រំដែនខេត្តកំពង់ចាម និងព្រៃវែងដោយសារកន្លែងនោះមានប្រវត្តិជាមូលដ្ឋានយោធានៃអតីតលេខាបក្សភូមិភាគបូព៌ា សោ ភឹម ។*


ប្រជាជនកំពុងស្តាប់ការពន្យល់របស់ក្រុមជួយជនរងគ្រោះដាក់ពាក្យបណ្តឹងក្នុងខេត្តព្រៃវែង

តាមផ្លូវទៅកាន់តំបន់នេះ យើងបានឆ្លងកាត់កន្លែងហ្វូងព្រះស្តេចកន ដែលមានប្រាសាទមួយដាក់ឈ្មោះតាមស្តេចកននៅខេត្តកំពង់ចាម ។ ចេញពីទីនោះ ក៏បន្តដំណើរទៅភូមិសំរោង ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ដែលជាអតីតមូលដ្ឋានទ័ពរបស់ សោ ភឹម ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងជាភូមិកំណើតរបស់គាត់ ដែលមានផ្ទះពីរខ្នងមួយខ្នងសម្រាប់ខ្លួនគាត់ និងមួយខ្នងទៀតសម្រាប់ភ្ញៀវ ។ ក្រុមការងារបានទៅទស្សនាផ្ទះទាំងពីរខ្នងនេះដែលនៅសល់តែគ្រឹះ និងអណ្តូងទឹកមួយកសាងនៅឆ្នាំ១៩៧៦ ប៉ុណ្ណោះ ។

ចេញពីភូមិសំរោង ក្រុមការងារបានឆ្លងចូលទៅកាន់ខេត្តព្រៃវែង ។ ឆ្លើយតបនឹងសំណូមពររបស់អ្នកភូមិដែលគួរឲ្យចាប់អារម្មណ៍ម្នាក់ យើងក៏បន្តដំណើរទៅទស្សនាភូមិដូនដោក ឃុំជាច ស្រុកកំចាយមារ ។ នៅថ្ងៃទី៨ ខែមេសា ក្រុមការងារបានមកដល់ភូមិដូនដោក ហើយប្រាប់អ្នកភូមិអំពីសិទ្ធិរបស់គាត់ក្នុងការចូលរួមក្នុងសាលាក្តីខ្មែរក្រហម ។ ក្រុមអ្នកភូមិ និងជាពិសេសប្រធានឃុំបានទទួលស្វាគមន៍យ៉ាងកក់ក្តៅ ។ នៅពេលព្រលប់ អ្នកភូមិបានបង្ហាញពីទីតាំងនៅជុំវិញភូមិដែលជាប់ពាក់ព័ន្ធនឹងវិហារដែល សោ ភឹម លេខាភូមិភាគបូព៌ាបានសង់រោងជាងសិប្បកម្មពីលើ និងវាលស្រែដ៏ធំល្វឹងល្វើយរបស់ប្រពន្ធគាត់ឈ្មោះការ៉ូ ។


អណ្តូងដែលកសាងឡើងដោយ សោ ភឹម ក្នុងឆ្នាំ១៩៧៦

**ជីវភាពប្រជាជនភូមិភាគបូព៌ានៅដើមរបបកម្ពុជាប្រជាធិបតេយ្យ**

យោងតាមការស្រាវជ្រាវរបស់ ឃៀវនិន ឆ្នាំ១៩៧៥-១៩៧៦ បានបង្ហាញថា ប្រជាជននៅភូមិភាគបូព៌ារស់នៅយ៉ាងសុខសាន្ត ។ ក្នុងរបាយការណ៍របស់គាត់ពេលខ្មែរក្រហមទទួលបានជោគជ័យ ប្រជាជនភូមិភាគបូព៌ាដែលកាន់របបកុម្មុយនីស្តរួចទៅហើយនោះបានរៀបចំជា "ក្រុមប្រវាស់ដៃ" ដែល "កសិករនាំគ្នាចងក្រងជាក្រុមតូចៗមានសមាជិកពី១០-១២គ្រួសារ" ។ គាត់រៀបរាប់ថា ការរៀបចំឲ្យមានក្រុមប្រវាស់ដៃនាំមកនូវភាពរីកចម្រើនពិតប្រាកដ ព្រោះកសិករមានសិទ្ធិកាន់កាប់លើដីធ្លី សត្វពាហនៈ និង សម្ភារៈប្រើប្រាស់ទាំងអស់ ហើយការចងការប្រាក់ និងបង់ប្រាក់ជួលមានលក្ខណៈធូរស្រាលជាងមុន ប៉ុន្តែការរស់នៅជាឯកជនបែរជាមានលក្ខណៈតឹងរ៉ឹងជាងមុនទៅវិញ ។

ចាប់ពីឆ្នាំ១៩៧៥ ក្រុមប្រវាស់ដៃទាំងនេះបានរួមគ្នាបង្កើតជាសហករណ៍កម្រិតទាបដែលមានប្រជាជនរាប់រយនាក់ ។ គាត់សរសេរថា សហករណ៍ទាំងនេះមិនសូវមានប្រជាប្រិយទេ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការរស់នៅជាគ្រួសារ និងការប្រណិប័តន៍សាសនានៅតែអនុញ្ញាតឲ្យមានដូចកាលពីដើម ។ នៅចុងឆ្នាំ១៩៧៦ ឬ ១៩៧៧ សហករណ៍កម្រិតទាបទាំងនេះបានប្រមូលផ្តុំបង្កើតជាសហករណ៍កម្រិតខ្ពស់ដែលមានរាប់ពាន់គ្រួសារ ។ គាត់បន្ថែមថា នៅខណៈពេលដែលប្រជាជនហូបបាយរួម ការរស់នៅជាគ្រួសារ ការប្រណិប័តន៍សាសនាស្ថិតនៅក្រោមការរឹតបន្តឹង ហើយពិធីរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងជាសមូហភាព ក្រោយមកសាសនាត្រូវបានហាមឃាត់ទាំងស្រុង ។

គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងបានរកឃើញតាមរយៈរបាយការណ៍អ្នកភូមិដូនដោកដែលបានអះអាងបញ្ជាក់ពីការរៀបរាប់របស់ ឃៀវនិន ពីជីវភាពប្រជាជនភូមិភាគបូព៌ានៅដើមរបបកម្ពុជាប្រជាធិបតេយ្យថា រវាងពីឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៧ ជីវភាពរបស់ពួកគេល្អប្រសើរច្រើនជាងប្រជាជនដែលរស់នៅតំបន់ដទៃទៀត ។ ពីឆ្នាំ១៩៧៥-១៩៧៦ ប្រជាជនបាន

និយាយពីរបៀបរស់នៅជាក្រុម ការកាន់កាប់ផ្ទះផ្ទាល់ខ្លួន ខណៈពេលដីស្រែ និងកសិផលត្រូវប្រមូលដាក់ជារបស់រួម ។ នៅឆ្នាំ១៩៧៦ សហករណ៍បានចាប់ផ្តើមបង្កើត ដែលជាសញ្ញាបញ្ចប់នូវកម្មសិទ្ធិឯកជន និងចាប់ផ្តើមហូបបាយរួម ។ ទោះជាយ៉ាងនេះក្តី អ្នកភូមិបានទទួលស្គាល់ថា ជីវភាពរបស់ពួកគាត់មិនលំបាកដូចប្រជាជននៅភូមិភាគដទៃទេ ពួកគាត់ទទួលបានអាហារពីរពេលក្នុងមួយថ្ងៃ និងមានបាយនៅពេលល្ងាចទៀត ។

## ការបោសសម្អាតនៅភូមិភាគបូព៌ា

ទោះជាយ៉ាងនេះក្តី ជីវភាពរបស់ប្រជាជនភូមិភាគបូព៌ាចាប់ផ្តើមចុះអន់ថយនៅពេលមជ្ឈិមបក្សលែងទុកចិត្តកងទ័ពរបស់ភូមិភាគនេះ ។ ស្របពេលនោះរដ្ឋបាលថ្មីក៏បានបង្កើតឡើងដែរ ។ ក្នុងរបាយការណ៍របស់ យៀវនិន ការលែងទុកចិត្តនេះស្តែងឡើងនៅខែសីហា ឆ្នាំ១៩៧៦ នៅពេលកម្មាភិបាលភូមិភាគបូព៌ាមួយចំនួនតូចត្រូវបានចាប់ខ្លួនដោយកងសន្តិបាល និងបញ្ជូនទៅសម្លាប់នៅគុកនយោបាយទួលស្លែងក្នុងទីក្រុងភ្នំពេញ ។ គាត់អះអាងថា អ្នកដែលត្រូវចាប់ខ្លួននៅខែសីហា ឆ្នាំ១៩៧៦ ទាំងនោះរួមមាន ឈូក លេខាធិការបក្សកុម្មុយនីស្តតំបន់២៤ និង ចាន់ ចក្រី អនុសេនាធិការរងនៃកងទ័ពបដិវត្តន៍កម្ពុជា ។ អ្នកទាំងនោះត្រូវបានបង្ខំឲ្យប្រាប់ឈ្មោះកម្មាភិបាលជិតស្និទ្ធរបស់ពួកគេដែលត្រូវបានបោសសំអាតជាបន្តបន្ទាប់ ។

យោងតាម យៀវនិន បក្សមិនបានចាត់ទុកថា កងទ័ព និងរដ្ឋបាលភូមិភាគបូព៌ាត្រៀមខ្លួនប្រឆាំងនឹងវៀតណាមខ្លាំងក្លានៅឡើយទេ ។ ដើម្បីគាំទ្រគំនិតនេះ គាត់ពន្យល់ថា តើមជ្ឈិមបក្សពណ៌នាអំពីអ្នកស្រុកដែលមានក្បាលយួនខ្លួនខ្មែរយ៉ាងដូចម្តេច ។ នៅឆ្នាំ១៩៧៦-១៩៧៧ បក្សបានបញ្ជូនកងទ័ពបន្ថែមទៀតដើម្បីធ្វើការលុកលុយចូលទឹកដីវៀតណាម ។ បន្ទាប់មក បក្សបានសម្រេចចិត្តថា កងទ័ពនិងការគ្រប់គ្រងផ្នែករដ្ឋបាលភូមិភាគបូព៌ាដែលមិនគួរឲ្យទុកចិត្តគួរតែកម្ទេចចោល និងចាប់ផ្តើមគ្រប់គ្រងលើភូមិភាគនេះជាថ្មី ដែលគេស្គាល់ថា រដ្ឋប្រហារកម្ទេចក្បាលម៉ាស៊ីនដឹកនាំភូមិភាគបូព៌ា ។ ភូមិភាគបូព៌ាបានប្រឆាំងនឹងការគ្រប់គ្រងនេះ ដោយបង្កឲ្យមានការសម្លាប់រង្គាលក្នុងចំណោមប្រជាជនភូមិភាគបូព៌ានៅពាក់ទីពីរ (ខែកញ្ញា) ឆ្នាំ១៩៧៨ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ ទាហានដែលស្មោះត្រង់នឹង ប៉ុល ពត មកពីភូមិភាគពាយ័ព្យដែលនិយាយរដឹន (ជាមួយសំឡេងខ្លាំងៗ) បានចូលមកឈ្លានពានភូមិភាគបូព៌ា ។ យោងតាមអ្នកអត្ថាធិប្បាយ ទាហានទាំងនេះបានបោសសំអាតដោយមិនរើសមុខជាច្រើនដែលធ្វើឲ្យប៉ះពាល់គ្រប់សមាជិកសង្គមរួមទាំងអ្នកភូមិផងដែរ ។ អ្នកស្រុកនៅភូមិភាគនេះត្រូវបានសម្លាប់ ។ យោងតាមកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយគម្រោងជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌល ទាហានបានជម្លៀសអ្នកដែលនៅរស់ឲ្យទៅទិសខាងលិច រួមមានខេត្តកំពង់ធំ ពោធិសាត់ និងខេត្តបាត់ដំបង ដោយខ្លាចអ្នកស្រុកទាំងនោះគេចខ្លួនទៅប្រទេសវៀតណាម ។ ពេលមកដល់កន្លែងស្នាក់ភាគច្រើនត្រូវបានបាញ់សម្លាប់ ឬបង្អត់អាហារឲ្យស្លាប់ ។ នៅខែមីនា ឆ្នាំ២០០៨ ប្រធានឃុំជាចបានធ្វើស្ថិតិរាប់ចំនួនអ្នកស្លាប់ក្រៅផ្លូវការក្នុងរបបនោះ ហើយណែនាំប្រធានភូមិឲ្យសាកសួររកអ្នកស្លាប់នៅតាមផ្ទះទៀត ។ គាត់បានរកឃើញថា ចំនួនអ្នកស្លាប់ សរុបក្នុងឃុំរបស់គាត់រវាងពីឆ្នាំ១៩៧៥-១៩៧៨ មាន៨៣០នាក់ ។

## អត្តឃាតរបស់ សោ ភឹម និងការបន្តបោសសម្អាត

ការបោសសម្អាតរបស់មជ្ឈិមបក្សបានរីករាលដាលរហូតដល់ កម្មាភិបាលធំៗរបស់បក្សដែលទីបំផុតក៏ធ្លាក់ដល់ សោ ភឹម ជាលេខាភូមិភាគបូព៌ាថែមទៀត ។ តាមសម្តីរបស់ យៀវនិន ការចាប់ខ្លួនកម្មាភិបាល ភូមិភាគបូព៌ាដំបូងគឺធ្វើឡើងនៅខែសីហា ឆ្នាំ១៩៧៦ ដោយធ្វើការបោសសម្អាតជាទ្រង់ទ្រាយធំរួមមាន សោ ភឹម ផង ។ គេគិតថា ប្រធានកងពលដែលត្រូវចាប់ខ្លួននៅភូមិភាគបូព៌ា និងបញ្ជូនទៅគុកទួលស្លែងនៅឆ្នាំ១៩៧៦ បានផ្តល់ព័ត៌មានថា សោ ភឹម មានផែនការក្បត់ ។ នៅខណៈនោះ ប៉ុល ពត ជឿជាក់ថាពិតជាមានសកម្មភាពក្បត់នៅភូមិភាគបូព៌ាមែនតែគាត់មិនបានសម្រេចចិត្តប្រឆាំងនឹង សោ ភឹម ភ្លាមៗទេ ។ នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ ប៉ុល ពត បានចាប់ផ្តើមប្រើយុទ្ធសាស្ត្រថ្មីដោយបញ្ជូន សោ ភឹម ទៅប្រទេសចិន បន្ទាប់មកទើបបោសសំអាតកម្មាភិបាលនៅក្រោមបញ្ជារបស់គាត់ ។ ពេលគាត់ត្រឡប់មកពីប្រទេសចិនវិញ សោ ភឹម បានយល់យ៉ាងច្បាស់ពីបំណងរបស់ ប៉ុល ពត ដែលចង់កម្ចាត់រូបគាត់ ។ ជាក់ស្តែង សោ

ភីម បានភៀសខ្លួនទៅប្រទេសវៀតណាមមួយរយៈ ។ ក្រោយមកគាត់បានសម្រេចចិត្តត្រឡប់មកប្រទេសកម្ពុជាវិញព្រោះជឿជាក់ថា ប៉ុល ពត ពិតជាមិនសង្ស័យលើភាពស្មោះត្រង់របស់គាត់ ហើយសង្ឃឹមថានឹងបានជួបជាមួយ ប៉ុល ពត និយាយឲ្យដឹងខុសត្រូវម្តង គាត់ក៏ធ្វើដំណើរទៅខេត្តកំពង់ចាម ។ នៅខេត្តកំពង់ចាម សោ ភីម បាន បញ្ជូននិរសារម្នាក់ទៅជួប ប៉ុល ពត ដើម្បីបង្ហាញពីបំណងរបស់គាត់ ។ ជាការឆ្លើយតបនឹងសំណូមពររបស់គាត់នៅខែមិថុនា ឆ្នាំ ១៩៧៨ ប៉ុល ពត បានបញ្ជូនទាហានមួយក្រុមទៅកាន់ខេត្តកំពង់ចាម ។ យោងតាមកិច្ចសម្ភាសន៍របស់កម្មវិធីជំរុញឲ្យមានការទទួលខុសត្រូវ ទាហានទាំងនោះបានធ្វើការឡោមព័ទ្ធចាប់ សោ ភីម ។ ដោយដឹងថាទាហានទាំងនោះមកសម្លាប់ គាត់ក៏បានបាញ់សម្លាប់ខ្លួនឯងជាមួយអង្គរក្សស្មោះត្រង់ពីរបីនាក់ទៀតរបស់គាត់ ។

ការធ្វើអត្តឃាតរបស់ សោ ភីម បានធ្វើឲ្យការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ាមានសភាពកាន់តែខ្លាំង ។ ខណៈនោះមនុស្សជាច្រើនបានរត់គេចខ្លួន ប៉ុន្តែក៏មានមួយចំនួនមិនរត់គេចដែរ ។ ឧទាហរណ៍ ស្ត្រីម្នាក់នៅភូមិដូនដោកបាននិយាយពីការបាត់ខ្លួនរបស់បងប្រុសថ្លៃគាត់ឈ្មោះ ម៉ក់ ម៉ុក ជាអនុលេខាតំបន់២០ ។ ដោយសារគាត់ជាកម្មាភិបាលថ្នាក់ខ្ពស់ ក្រុមរបស់យើងបានស្រាវជ្រាវតាមប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌល ហើយបានរកឃើញថា ម៉ុក ត្រូវបានសម្លាប់នៅទួលស្លែង ។ យោងតាមប្រព័ន្ធទិន្នន័យនេះដែរ គាត់ត្រូវបានចាប់ខ្លួននៅភូមិភាគបូព៌ានៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៧៨ (មួយខែមុនពេលការជម្លៀសអ្នកភូមិចេញ) ។ តាមចម្លើយសារភាពរបស់គាត់នៅថ្ងៃទី៩ ខែកក្កដា បានឲ្យដឹងថា ម៉ុក បានឆ្លើយថា ក្រុមរបស់គាត់បានអនុញ្ញាតឲ្យជនជាតិវៀតណាមចូលបំផ្លាញទ្រព្យសម្បត្តិ ហើយគាត់ក៏បានលាក់ភ្នាក់ងារសម្ងាត់វៀតណាមជាច្រើនដែលជាការបំពានគោលនយោបាយរបស់បក្ស ។ គាត់បានប្រាប់ឈ្មោះជនក្បត់ចំនួន២៥ នាក់ដទៃទៀត ។

## ការជម្លៀសអ្នកភូមិដូនដោក

គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងបានទៅទស្សនាភូមិដូនដោក ដែលបានផ្តល់ជាឧទាហរណ៍នៃការប្រឆាំងទៅនឹងការបង្ខំឲ្យទទួលយកអំណាចរបស់មជ្ឈិមបក្ស ។ នៅក្នុងតំបន់២០ ភូមិនេះមានប្រវត្តិគួរឲ្យចាប់អារម្មណ៍ និងភាពចលាចលក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីក្រោយមកមានភាពស្ងប់ស្ងាត់ក៏ដោយ ។ បន្ទាប់ពីការធ្វើអត្តឃាតរបស់ សោ ភីម ក្រុមដែលមានសំឡេងរងើន បានចាប់ផ្តើមជម្លៀសអ្នកភូមិទូទាំងខេត្តព្រៃវែងទៅតំបន់ផ្សេងៗ ឬទៅភាគខាងលិច ជាពិសេសខេត្តពោធិសាត់ និងបាត់ដំបង ។ នៅភូមិដូនដោក ឃុំជាច ជាកន្លែងចុងក្រោយដែលត្រូវអនុវត្តការជម្លៀសប្រជាជនចេញ ។ ប្រជាជនគិតថា ក្រុមរងើនជម្លៀសអ្នកភូមិដូនដោកនេះ ព្រោះពួកគេរំពឹងថានឹងមានការប្រឆាំងតវ៉ាពីអ្នកភូមិដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយ សោ ភីម និងប្រពន្ធរបស់គាត់ ។

យោងតាមអ្នកភូមិបានឲ្យដឹងថា ប្រជាជនជាច្រើនដែលស្មោះត្រង់នឹង សោ ភីម បានរត់គេចខ្លួន និងលាក់ខ្លួនក្នុងព្រៃ ។ មុនពេលក្រុមរងើនចូលមកដល់ អ្នកស្មោះត្រង់ទាំងនោះបានត្រឡប់មកភូមិដូនដោកវិញ រួចហើយណែនាំអ្នកភូមិឲ្យប្រឆាំងតបតដោយប្រើអាវុធ និងជំរុញពួកគាត់ឲ្យសម្លាប់ក្រុមរងើនទាំងអស់ ។ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៨ ពេលដែលក្រុមរងើន ឡោមព័ទ្ធភូមិ អ្នកស្រុកបានធ្វើការប្រឆាំងតបតនឹងទាហានទាំងនោះដោយប្រើពូថៅ និងកាំបិតដងខ្លី ។ ប្រតិកម្មរបស់អ្នកស្រុក បានធ្វើឲ្យក្រុមរងើនបាញ់សម្លាប់ពួកគាត់ និងផ្លោងគ្រាប់កាំភ្លើងពីរគ្រាប់ចូលភូមិបណ្តាលឲ្យស្លាប់មនុស្សជាច្រើន ។ ទាហានបានកម្ចាត់ការប្តេជ្ញាចិត្តរបស់អ្នកស្រុក ហើយបានជម្លៀសពួកគាត់ដោយជោគជ័យ និងប្រាប់ថា ពួកគាត់នឹងបានទៅកាន់កន្លែងដីខ្លាញ់ ។

របាយការណ៍ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងអំឡុងពេលជម្លៀស ជាពិសេសការប្រើគ្រាប់កាំភ្លើងធំប្រឆាំងនឹងជនស៊ីវិលដោយមិនរើសមុខ បានចង្អុលបង្ហាញយ៉ាងច្បាស់នៅក្នុងញត្តិរបស់អ្នកភូមិផ្ញើទៅតុលាការ ។ ឧទាហរណ៍ ស្ត្រីម្នាក់អាយុ៤៥ឆ្នាំមកពីភូមិដូនដោក បាននិយាយប្រាប់យើងថា គាត់ឃើញដោយផ្ទាល់ភ្នែកនូវការស្លាប់ឪពុករបស់គាត់ដ៏គួរឲ្យរន្ធត់នៅពេលគេជម្លៀសចេញ ។ គាត់បានឃើញក្រុមរងើនបាញ់ឪពុកគាត់ចំត្រង់ពោះនៅក្នុងរោងបាយ ធ្វើឲ្យធ្លាយពោះវៀនចេញមកក្រៅ ។ នៅពេលគាត់និងបុរសម្នាក់ព្យាយាមទៅជួយឪពុកទាហានក៏បាញ់សម្លាប់បុរសម្នាក់នោះទៀត ។ គាត់បានអង្វរកុំឲ្យទាហាននោះបាញ់ឪពុកគាត់

ដោយសន្យាថា នឹងទៅជាមួយពួកគេ ។ ទាហានបានបង្ខំឲ្យគាត់ឲ្យចាកចេញ ។ នៅខណៈពេលត្រូវអូសចេញទៅ គាត់បានឮសំឡេងទាហានបញ្ជាឲ្យបាញ់សម្លាប់បុរសពីរនាក់ផ្សេងទៀត ។

**លទ្ធផលការងារនៅភូមិដូនដោក**

ដោយសារភាពឃោរឃៅក្នុងការជម្លៀសប្រជាជនរបស់ក្រុមវៀន អ្នកភូមិដូនដោកបានទទួលរងការប៉ះពាល់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរពីព្រឹត្តិការណ៍ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៨នេះ ។ ជាតឹកតាងនៃព្រឹត្តិការណ៍នេះ ប្រធានភូមិបានរកឃើញក្នុងការស្រាវជ្រាវថ្មីៗពីឆ្នាំ១៩៧៥-១៩៧៨ មានប្រជាជនចំនួន៦២នាក់ត្រូវបានសម្លាប់ ។ ដូច្នេះ អ្នកភូមិស្ទើរតែគ្រប់គ្រួសារដែលក្រុមការងារបានជួបសុទ្ធតែមានបាត់បង់សមាជិកម្នាក់ ។ ដោយសារភាពឈឺចាប់នៅអំឡុងឆ្នាំចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ អ្នកភូមិបានស្វាគមន៍គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្ដឹងយ៉ាងកក់ក្ដៅ និងសាទរចំពោះការខិតខំប្រឹងប្រែងដើម្បីផ្ដល់ព័ត៌មានស្ដីពីតុលាការកាត់ទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅភូមិភាគបូព៌ា ។ អ្នកភូមិជាច្រើនបានរៀបម្ហូប និងអាហារថ្ងៃត្រង់ទទួលក្រុមការងាររបស់យើងមួយពេលដោយរាក់ទាក់បំផុត ។

នៅថ្ងៃទី៩ ខែមេសា ក្រុមការងារបានប្រមូលទម្រង់បែបបទព័ត៌មានជនរងគ្រោះពីអ្នកដាក់បណ្ដឹងចំនួន៣០នាក់នៅក្នុងភូមិដូនដោក ។ ក្រុមការងារសង្កេតឃើញថា អ្នកភូមិជាច្រើនចង់ដាក់ពាក្យបណ្ដឹង ។ បន្ថែមពីលើនេះ ក្រុមការងារបានជួយអ្នកភូមិពីរនាក់ដែលមានបងប្អូនស្លាប់នៅគុកទួលស្លែងដោយស្រាវជ្រាវរកឈ្មោះពួកគេនៅក្នុងប្រព័ន្ធទិន្នន័យកុំព្យូទ័រ ។ ជាលទ្ធផលនៃការស្រាវជ្រាវ ក្រុមការងារបានផ្ដល់ព័ត៌មានថា ម៉ក់ ម៉ុក បានស្លាប់នៅគុកទួលស្លែង ។ ជាមួយគ្នានោះ អ្នកភូមិក៏បានសម្ដែងការដឹងគុណចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមការងារយើង ។ ស្ត្រីម្នាក់បានប្រាប់យើងថា គាត់ជឿជាក់ចំពោះការដាក់ពាក្យបណ្ដឹងដែលជាមធ្យោបាយដ៏សំខាន់ដើម្បីរំឭកដល់ជនរងគ្រោះ និងក្មេងជំនាន់ក្រោយដែលមិនបានដឹងពីរបបកម្ពុជាប្រជាធិបតេយ្យ ។

**ឌី ឆេរិទ្ធិ និង សារ៉ា ថូម៉ាស**



អ្នកភូមិដូនដោក ក្នុងខេត្តព្រៃវែង




## សេចក្តីផ្តើម

សង្គ្រាមត្រជាក់បានកើតឡើងនៅប្រទេសចិន សហភាពសូវៀត និងសហរដ្ឋអាមេរិក ប្រទេសទាំងនេះបានប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីដណ្តើមអំណាចគ្រប់គ្រងលើតំបន់ឥណ្ឌូចិនទាំងមូល និងបានបង្កើតកម្លាំងតស៊ូជាមួយនឹងប្រទេសដែលមានឥទ្ធិពលមួយចំនួនផងដែរ ។ ទោះបីជាគេដឹងពីលទ្ធផលនៃសង្គ្រាមត្រជាក់នេះក៏ដោយ ក៏គេនៅតែបន្តធ្វើឲ្យសង្គ្រាមនេះរីករាលដាលដដែល ។

សម្រាប់ប្រជាជនដែលរស់នៅលើពិភពលោកបានស្គាល់យ៉ាងច្បាស់ថា ប្រទេសមួយដែលដំបូងជាប្រទេសកម្ពុជាត្រូវបានកែប្រែឈ្មោះទៅជាកម្ពុជាប្រជាធិបតេយ្យ ។ រយៈពេលជិត៤ឆ្នាំនៃរបបនេះ មានព័ត៌មាននៅក្នុងប្រទេសបន្តិចបន្តួចប៉ុណ្ណោះត្រូវបានផ្សព្វផ្សាយចេញទៅក្រៅ ។ ភាពត្រចះត្រចង់នៅប្រទេសកម្ពុជាបានផុតរលត់ ។

នៅពេលដែលភាពត្រចះត្រចង់នេះភ្លឺឡើងវិញ ប្រជាជននៅក្នុងប្រទេសនេះជាង១.៨លាននាក់ត្រូវបានសម្លាប់ នេះជាកំហុសរបស់អង្គការ ។ រចនាសម្ព័ន្ធគ្រប់គ្រងប្រៀបបានទៅនឹងរបបផ្តាច់ការនៅសម័យយុគថ្ម ដែលខ្មែរក្រហមចង់ធ្វើឲ្យល្អជាងលទ្ធិម៉ៅនិយមទៅទៀតដោយផ្លាស់ប្តូរប្រទេស និងប្រជាជនរបស់ខ្លួនទៅជាសង្គមកសិកម្មមួយក្នុងរយៈដ៏ខ្លី ដែលទាំងមិនបានយកចិត្តទុកដាក់លើជីវិតមនុស្សទៀតផង ។

បុរសដែលនៅពីក្រោយផែនការឃោរឃៅនេះមានឈ្មោះថា សាឡុត ស ដែលត្រូវស្គាល់ថាជា ប៉ុល ពត ឬក៏បងធំទី១ ។ ប៉ុល ពត និងរបបរបស់គាត់មិនត្រឹមតែធ្វើឲ្យប្រជាជនភ័យខ្លាច បំផ្លិចបំផ្លាញប្រទេសនៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានអនុញ្ញាតឲ្យធ្វើនយោបាយនៅក្នុងសម័យសង្គ្រាមត្រជាក់អស់រយៈពេលជាច្រើនឆ្នាំថែមទៀត ។

ប៉ុល ពត មិនបានប្រឈមមុខនឹងតុលាការទេ (ស្លាប់យ៉ាងស្ងៀមស្ងាត់នៅក្នុងឆ្នាំ១៩៩៨) ប៉ុន្តែសមាជិកផ្សេងទៀតនៅក្នុងរបបរបស់គាត់បច្ចុប្បន្ននេះកំពុងរង់ចាំសាលាក្តីកាត់ទោសនៅភ្នំពេញ ។ បន្ទាប់ពីមានការពន្យារពេលជាច្រើនឆ្នាំ អង្គការសហប្រជាជាតិបានបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយនៅទីបំផុតតុលាការនេះបានចាប់ផ្តើមការងាររបស់ខ្លួននៅឆ្នាំ២០០៧ ជាមួយនឹងដំណើរការកាត់ទោសនៅឆ្នាំ២០០៨ ដោយធានាថា នឹងទទួលបានមូលនិធិបន្ថែមដើម្បីបន្តដំណើរការ៣ទៅ៤ឆ្នាំខាងមុខទៀត ។

មានចុងចោទមួយចំនួនជាអ្នករួមគំនិតជាមួយ ប៉ុល ពត គឺ ខៀវ សំផន (អតីតគណៈប្រធានរដ្ឋ) នួន ជា (បងធំទី២ ) និង អៀង សារី (អតីតរដ្ឋមន្ត្រីក្រសួងការបរទេស) អៀង ធីរិទ្ធ ប្រពន្ធរបស់ អៀង សារី (អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច) និង កាំង ហ្គេកអ៊ាវ ហៅ ឌុច (អតីតប្រធានគុកទួលស្លែង ឬ គុកស-២១) ។ អ្នកទាំងនេះត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ប្រជាជនកម្ពុជាទាំងអស់សង្ឃឹមថាតុលាការនេះនឹងចេញសេចក្តីសម្រេចមុនពេលដែលជនជាប់ចោទត្រូវស្លាប់ដោយសារជំងឺ ឬវ័យចាស់ជរា ។

អំពើឃោរឃៅភាគច្រើនក្នុងរបបខ្មែរក្រហមត្រូវបានបង្ហាញឲ្យឃើញអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ អ្នកប្រវត្តិសាស្ត្របានវិភាគពីប្រព័ន្ធនយោបាយ អ្នកមានតួនាទីសំខាន់ និងហេតុផលរបស់គេ ។ ជនរងគ្រោះខ្លះបានរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួននៅក្នុងសៀវភៅ ហើយជនរងគ្រោះខ្លះទៀតនឹងមានឱកាសធ្វើដូច្នេះនៅក្នុងតុលាការដែលបានគ្រោងទុក ។ រឿង “វាលពិឃាត” បានរៀបរាប់ពីសកម្មភាពដែលខ្មែរក្រហមចូលមកដល់ភ្នំពេញ ការគ្រប់គ្រងប្រទេស និងប្រជាជនទាំងមូល ។

ទោះបីជាមានព័ត៌មានគ្រប់គ្រាន់ត្រូវបានផ្សព្វផ្សាយ ប៉ុន្តែមានព័ត៌មានតិចតួចណាស់ដែលនិយាយអំពីទង់ជាតិតំណាងប្រទេសនៅក្នុងរបបដ៏ឃោរឃៅនេះ ។ នៅពេលនេះយើងនឹងត្រឡប់ទៅ

កាន់អតីតកាលវិញ ។

## របបកម្ពុជាប្រជាធិបតេយ្យ និងទង់ជាតិ

នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ប្រាំបួនខែបន្ទាប់ពីខ្មែរក្រហមដណ្តើមបានប្រទេសទាំងមូល រដ្ឋាភិបាលរបបកម្ពុជាប្រជាធិបតេយ្យបានអនុម័តរដ្ឋធម្មនុញ្ញថ្មីនិងប្រកាសឲ្យប្រើជាសាធារណៈនៅក្នុងជំពូក១១ថា៖

### អំពីទង់ជាតិ

### មាត្រា១៦

នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានចែងអំពីរូបភាពនិងខ្លឹមសារដូចតទៅ៖ ផ្ទៃពណ៌ក្រហមមានរូបប្រាសាទកំពូលបីពណ៌លឿងនៅចំកណ្តាល ។ ផ្ទៃក្រហមជានិមិត្តរូបនៃចលនាបដិវត្តន៍ ការប្រយុទ្ធមោះមុតអង់អាចក្លាហាន ក្នុងការរំដោះជាតិការពារជាតិ និងកសាងជាតិកម្ពុជារបស់ប្រជាជនកម្ពុជា ។ ប្រាសាទពណ៌លឿង ជានិមិត្តរូបនៃប្រពៃណីជាតិនិងប្រជាជនកម្ពុជាដែលជាអ្នកការពារប្រទេស ជាអ្នកស្ថាបនាប្រទេសឲ្យបានថ្កុំថ្កើងនិងរុងរឿង ។

យោងតាមការប្រកាសរបស់អង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៦ មិនបានទទួលស្គាល់ការប្តូរឈ្មោះប្រទេសឡើយ ។ ដំបូងជាប្រទេសកម្ពុជាគឺ (ពីឆ្នាំ១៩៥៥-១៩៧០) ជារបបសាធារណរដ្ឋខ្មែរ (ពីឆ្នាំ១៩៧០-១៩៧៥) និងមានការប្តូរឈ្មោះប្រទេសកម្ពុជាម្តងទៀតគឺ (ពីឆ្នាំ១៩៧៥-១៩៧៦) ទៅជាកម្ពុជាប្រជាធិបតេយ្យ ។



នៅឆ្នាំដដែលអ្នកប្រវត្តិសាស្ត្រ ដេវីដ ឆេនដល័រ បានរៀបរាប់នៅក្នុងអត្ថបទរបស់គាត់អំពីរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យថា៖ អត្ថន័យនៃការផ្លាស់ប្តូរបដិវត្តន៍ដែលមាន "ទង់ជាតិថ្មីស្រដៀងទៅនឹងទង់ជាតិចលនាខ្មែរវៀតមិញនៅដើមទសវត្សរ៍ឆ្នាំ១៩៥០" ។ ទោះបីជាការកែប្រែរដ្ឋធម្មនុញ្ញដែលមិនបានលុបចោលពាក្យ "ប្រាសាទ" ក៏ដោយ ប៉ុន្តែមានការអធិប្បាយថាមានការកែប្រែភាសាបារាំង នៅក្នុងរដ្ឋធម្មនុញ្ញថ្មីដែលធ្វើឡើងដោយរដ្ឋាភិបាល ប៉ុល ពត គឺផ្លាស់ប្តូរពាក្យ "ប្រាសាទ" ទៅជាពាក្យ "វិមាន" ប៉ុន្តែឯកសារចម្លងដែលគាំទ្រសេចក្តីអធិប្បាយនេះមិនទាន់បានរកឃើញនៅឡើយទេ ។

បន្ទាប់ពីរបប ប៉ុល ពត ដួលរលំនៅឆ្នាំ១៩៧៩ ប្រទេសកម្ពុជាជួបប្រទះនឹងការជ្រួលច្របល់ខាងនយោបាយ ព្រោះមានគណបក្សនយោបាយជាច្រើនផ្សេងៗគ្នានិងមានរដ្ឋាភិបាលចម្រុះ ហើយបរទេសបានព្យាយាមដណ្តើមអំណាចគ្រប់គ្រងលើប្រទេសកម្ពុជា នៅពេលនោះក៏មានការផ្លាស់ប្តូរទង់ជាតិមួយចំនួនដែរ ។ ប៉ុន្តែទង់ជាតិទាំងនោះមិនដែលត្រូវបានបញ្ជូនទៅអង្គការសហប្រជាជាតិឡើយ ហើយរដ្ឋាភិបាលស្តីទីមានតែនាមតែមិនមានអំណាចដែលតែងតាំងដោយវៀតណាមក៏មិនបានស្នើទង់ជាតិថ្មីទៅឲ្យអង្គការសហប្រជាជាតិដែរ ។ ដោយរដ្ឋាភិបាលដែលរៀបចំដោយវៀតណាមនេះមិនមានការគាំទ្រពីប្រទេសមួយចំនួនហើយក៏មិនមានការព្រួយបារម្ភថារបបកាប់សម្លាប់និងកើតឡើងម្តងទៀតដែរ ។ មានមតិថា "អ្នកប្រហែលជាសម្លាប់ប្រជាជនខ្លួនឯងរាប់លាននាក់ដូចដែលខ្មែរក្រហមធ្លាប់បានប្រព្រឹត្តិ ប៉ុន្តែចំពោះការទម្លាក់រដ្ឋាភិបាលដោយប្រទេសជិតខាងគឺជាឥរិយាបថអាក្រក់ ហើយក៏ជាការមិនគោរពបូរណភាពដែនដីរបស់ប្រទេសនោះដែរ" ។

នៅអង្គការសហប្រជាជាតិនាទីក្រុងញូវយ៉ក ទង់ជាតិរបស់កម្ពុជាប្រជាធិបតេយ្យនៅតែបក់រវិចដដែល ទោះបីជារដ្ឋាភិបាលថ្មីរបស់កម្ពុជាត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិកាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៩០ និងការប្រកាសជាសាធារណៈរបស់សម្តេចនរោត្តមសីហនុក៏ដោយ ។

## សេចក្តីប្រកាសរបស់សម្តេច នរោត្តមសីហនុ ប្រធានាធិបតីរបស់កម្ពុជា

*នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៩០*

*ចាប់ពីថ្ងៃនេះទៅ កម្ពុជាប្រជាធិបតេយ្យក្លាយជាសមាជិកពេញសិទ្ធិរបស់អង្គការសហប្រជាជាតិមានឈ្មោះជាភាសាខ្មែរថា "កម្ពុជា" ជាភាសាបារាំងថា "កាំបូត្ស" និង ជាភាសាអង់គ្លេសហៅថា "ខេមបូឌា" មិនមែនជា "កម្ពុជាប្រជាធិបតេយ្យ" ទេ ។*

*ទង់ជាតិរបស់ប្រទេសមិនមានពណ៌ក្រហមដូចរបបខ្មែរក្រហមរបស់ ប៉ុល ពត ទៀតឡើយ បច្ចុប្បន្នគឺជាទង់ជាតិចាស់ដែលមានប្រវត្តិរាប់រយឆ្នាំមកហើយ ។ ទង់ជាតិនេះមានរូបប្រាសាទអង្គរវត្តដែលមានកំពូល៣លេចត្រដែត (រូបប្រាសាទនេះមានពណ៌ស មិនមែនពណ៌លឿងទេ) ។*

*ចាប់ពីពេលនេះតទៅ ភ្លេងជាតិរបស់កម្ពុជា គឺជាទំនុកភ្លេងចាស់ដែលមានចំណងជើងថា "នគររាជ" ទំនុកច្រៀងមាន៣កថាខណ្ឌ) ។*

*ឋានៈជាផ្លូវការរបស់ខ្ញុំព្រះករុណាក្នុងនាមជាព្រះប្រមុខរដ្ឋរបស់កម្ពុជាត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិថា "ប្រធានាធិបតីនៃប្រទេសកម្ពុជា" ។*

*រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យចាប់ពីពេលនេះតទៅប្រែក្លាយទៅជា "រដ្ឋាភិបាលជាតិនៃប្រទេសកម្ពុជា" ។*

*របបនៃប្រទេសកម្ពុជាមានសភាពដូចគ្នានឹងរបបសាធារណរដ្ឋបារាំងទី៥ ដែរគឺមាននយោបាយ សេដ្ឋកិច្ច សង្គមនិងសារព័ត៌មាន ។*

មិនថាអង្គការសហប្រជាជាតិឬក៏អ្នករចនាទង់ជាតិសុទ្ធតែមិនអាចអធិប្បាយពីមូលហេតុដែលទង់ជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យនៅតែត្រូវបានប្រើប្រាស់នៅអង្គការសហប្រជាជាតិឯទីក្រុងញូវយ៉កបានឡើយ ។

ប៉ុន្តែនៅក្នុងអត្ថបទឆ្នាំ១៩៩៩ របស់អ្នកប្រវត្តិសាស្ត្រ ប៊ែន ឃៀរនិន ដែលមានចំណងជើងថា "ដំណើរទៅកាន់យុត្តិធម៌របស់កម្ពុជា" បានសរសេរថាពីឆ្នាំ១៩៧៩-១៩៨២ ខ្មែរក្រហមនៅតែបន្តកាន់កាប់អាសនៈរបស់កម្ពុជាដោយមានឈ្មោះថា "កម្ពុជាប្រជាធិបតេយ្យ" ។ បន្ទាប់មកគណបក្សមិនមែនកុម្មុយនិស្តតូចពីរបានចូលរួមជាមួយគ្នាដោយបង្កើតជា "រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ ទោះជាមានការរួបរួមគ្នាក៏ដោយ ប៉ុន្តែរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬកម្ពុជា និងទង់ជាតិរបស់ខ្មែរក្រហមនៅតែបក់រវិចនៅទីស្នាក់ការអង្គការសហប្រជាជាតិក្រុងញូវយ៉ករហូតដល់ឆ្នាំ១៩៩២» ។

## ការស្រាវជ្រាវអំពីទង់ជាតិ

នៅអំឡុងពេលទស្សនាសារមន្ទីរសង្គ្រាមនៅឯសៀមរាប អ្នករៀបចំសារមន្ទីរបានដាក់តាំងទង់ជាតិតូចៗខ្លះមានពណ៌លឿងនិងក្រហមដោយមានរូបភាពប្រាសាទអង្គរវត្តនៅកណ្តាលធ្វើឲ្យគាត់នឹកទៅដល់របបខ្មែរក្រហម ។ មគ្គុទ្ទេសក៍សារមន្ទីរបានរៀបរាប់ថាគាត់យល់ច្បាស់អំពីរបបនេះ ប៉ុន្តែគាត់មិនបានប្រាប់ព័ត៌មានអ្វីបន្ថែមទៀតទាល់តែសោះ ។

ការស្រាវជ្រាវយ៉ាងរហ័សទៅក្នុងអ៊ីនធឺណេត បង្ហាញឲ្យឃើញពីទង់ជាតិជាច្រើនផ្សេងៗគ្នា ប៉ុន្តែមិនមានទង់ជាតិដើមរបស់កម្ពុជាប្រជាធិបតេយ្យឡើយ ។

នៅក្នុងអ៊ីនធឺណេតទង់ជាតិខ្លះមាន "ប្រាសាទកំពូលបីពណ៌លឿងនៅលើផ្ទៃពណ៌ក្រហម" ដោយមានរូបអង្គរវត្តតែមិនដូចគ្នាឬក៏ស្រដៀងគ្នាបន្តិចបន្តួច ហើយទង់ជាតិខ្លះទៀតមានផ្ទៃក្រហម-ខ្មៅ ឬក្រហម-ខៀវ និងមានរូបសញ្ញាជើងក្អែកពណ៌ស ទង់ជាតិចុងក្រោយនេះជារបស់ចលនារំដោះជាតិដែលជាបក្សនយោបាយតូចនិងមិនមានទម្រង់ច្បាស់លាស់ ហើយបក្សនេះស្វាគមន៍យ៉ាងពេញចិត្តចំពោះការមកដល់ភ្នំពេញរបស់ខ្មែរក្រហម ប៉ុន្តែក្រុមនេះត្រូវបានកម្ចាត់ចោលជាបន្តបន្ទាប់ ។

ដោយសារតែទង់ជាតិនៅក្នុងអ៊ីនធឺណេតដែលមានប្រាសាទពណ៌លឿងត្រូវបានបង្កើតដោយការស្រាវជ្រាវមិនមែនមកពីឯកសារ ដូច្នេះគម្រោងស្រាវជ្រាវភាគច្រើនបានធ្វើឡើងដើម្បីស្វែងរកទង់ជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យពិតប្រាកដ ។





មានអ្នកសារព័ត៌មានបរទេសមួយចំនួនត្រូវបានខ្មែរក្រហមអញ្ជើញឲ្យទៅជួប ដូច្នេះមានរូបថតជាច្រើនត្រូវបានបាត់បង់នៅពេលនោះ ។ រូបភាពរាប់ពាន់ដែលមានគឺត្រូវបានថតនៅមន្ទីរឃុំឃាំងស-២១ ។

រូបថតដែលមានពណ៌សខ្មៅអាចបំផុសទង់ជាតិឲ្យមានពណ៌ក្រហម ប៉ុន្តែដោយរូបភាពមានគុណភាពអន់វាមិនអាចបង្ហាញឲ្យឃើញថា តើមានរូបអង្គរវត្តនៅក្នុងនោះឬមិនមាន ហើយក៏មិនដឹងថារូបភាពនៅពីក្នុងនោះមានរូបរាងជាញញួរ កណ្តៀវ ឬមានតែទង់ជាតិព័ណ៌ក្រហមក៏ទេដែរ ។

ការរកឃើញដំបូងផ្តើមចេញមកពីតែមប្រៃសណីយ៍ ។ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៨៩ ផ្នែករដ្ឋបាលរបស់អង្គការសហប្រជាជាតិបានចេញសេចក្តីសម្រេចយកតែមដែលមានទង់ជាតិរបបកម្ពុជាប្រជាធិបតេយ្យមកប្រើនៅប្រទេស? (ហុងឌូរ៉ាស ហ្គីណេ-ប៊ីសូ និង ស៊ីព្រូស) ។




តែមរបស់អង្គការសហប្រជាជាតិបង្ហាញពីទង់ជាតិដែលមានរូបអង្គរវត្តកំពូលបី ហើយយោងទៅតាមប្រភពរបស់អង្គការសហប្រជាជាតិបានឲ្យដឹងថា មានទង់ជាតិដូចគ្នាធ្លាប់មានវត្តមាននៅទីក្រុងញូវយ៉ក ។

កំណែទម្រង់ទង់ជាតិផ្សេងទៀតមានវត្តមាននៅលើគម្របសៀវភៅដែលមានចំណងជើងថា "បដិវត្តន៍ដ៏ឃោរឃៅ" និពន្ធដោយ ម៉ាទីន ស្តាតហ្វក និង អ៊ុង ប៊ុនហៀង ។

នៅទីបំផុត ការអះអាងបន្ថែមអំពីការគាក់តែងរូបអង្គរវត្តពិតរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានរកឃើញនៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និពន្ធ ដោយ ឌី ខាំបូលី (មជ្ឈមណ្ឌលឯកសារកម្ពុជា ២០០៧) ។

**សេចក្តីសន្និដ្ឋាន**

តាមរយៈការបកស្រាយខាងលើធ្វើឲ្យយើងដឹងពីរូបរាងពិតប្រាកដនៃទង់ជាតិរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែយើងមិនដឹងច្បាស់ថាទង់ជាតិទាំងនោះត្រូវបានបង្កើតឡើងដំបូងដោយរដ្ឋសង្គមនិយមជាមិត្ត ឬនៅក្នុងសាមីប្រទេសទេ ។ យើងអាចធ្វើការសន្មតថា ទង់ជាតិទាំងនេះត្រូវបានបង្កើតឡើងនៅក្នុងស្រុក រីឯពណ៌ប្រហែលជាមានច្រើនអាស្រ័យទៅតាមទឹកថ្នាំជ្រលក់ពណ៌នៅពេលនោះ ពណ៌ប្រហែលជាស្លេក ហើយព័ណ៌ក៏មានការប្រែប្រួលខ្លះដែរ ។ ដូច្នេះយើងមិនអាចសិក្សាថា មានទង់ជាតិប៉ុន្មានត្រូវបានបង្កើតឡើងនៅពេលនោះ ។ យើងប្រាកដថា ខ្មែរក្រហមមិនមានភាពចុះញ៉ូមហើយប្រើប្រាស់ការពណ៌នាដោយមិនមានភាពសាំញ៉ាំដើម្បីប្រឆាំងនឹងគំនិតគហបតី ។ យើងអាចដឹងដោយការឆ្លុះបញ្ចាំងការរចនានិមិត្តសញ្ញាតំណាងប្រទេសនិងរូបិយវត្ថុ ។ ដោយខ្មែរក្រហមមិនដែលបានបង្ហាញ ពីមោទនភាពរបស់ខ្លួនចំពោះទង់ជាតិ ដូច្នេះគេប្រហែលជាប្រើប្រាស់ទង់ជាតិធម្មតាមួយដែលមានតែពណ៌ក្រហមគ្រប់ពេលវេលា ។

គោលគំនិតចម្បងក្នុងការស្រាវជ្រាវគឺធ្វើឡើងដើម្បីសិក្សាអំពីប្រវត្តិរបស់ទង់ជាតិនៅក្នុងសារមន្ទីរនៅសៀមរាប ហើយនៅក្នុងដំណើរការនេះធ្វើឲ្យយើងរកឃើញទង់ជាតិពិតប្រាកដរបស់កម្ពុជាប្រជាធិបតេយ្យ ។

ប៉ុន្តែទីបញ្ចប់នៅតែមានចម្ងល់ថា តើទង់ជាតិនៅក្នុងសារមន្ទីរសង្គ្រាមនៅខេត្តសៀមរាបមកពីណា? ទង់ជាតិដែលមានកំពូលច្រើននិងមានបីថ្នាក់អាចត្រូវបានយកមកប្រើមុនឆ្នាំ១៩៧៥ ឬពីឆ្នាំ១៩៧៥-១៩៧៩ ឬក៏ក្រោយឆ្នាំ១៩៧៩ដោយខ្មែរក្រហមដែលនៅសេសសល់ ។

អ្នកប្រវត្តិសាស្ត្រ ស៊ីវ ហេដឌ័រ ប្រហែលជាអាចមានការបកស្រាយល្អបំផុតដោយនិយាយថា «ភាពខុសប្លែកគ្នាគឺអាស្រ័យទៅលើបច្ចេកទេសនិងការយល់ឃើញរបស់ជាងដេរប្រុសឬជាងដេរស្រី» ។ ហើយនេះក៏ប្រហែលជាការភ័ន្តច្រឡំដែរ ។

**ស៊ីហ្វ្រេដ អ៊ីម៉ាន់**



# គួនាទីសិល្បៈនៅក្នុងបដិវត្តន៍ខ្មែរក្រហម

វត្តកោះរំដួលមានទីតាំងស្ថិតនៅចំណុចកណ្តាលភូមិថ្កោលធំ ក្នុងខេត្តពោធិ៍សាត់ ។ ដោយពិនិត្យ ឃើញអំពីសារសំខាន់ខាងផ្នែកភូមិសាស្ត្រនេះហើយ ទើបក្រុមថតខ្សែភាពយន្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើសយកទីតាំងនេះសម្រាប់ធ្វើជាកន្លែងបញ្ចាំងខ្សែភាពយន្តឲ្យអ្នកភូមិជិត៣០០នាក់ទស្សនា ។ ដោយឃើញមនុស្សចាស់ៗមានចំនួនច្រើនក្នុងចំណោមអ្នកមកទស្សនាទាំងនោះក្រុមថតខ្សែភាពយន្តបានថ្លែងអំណរគុណដល់អ្នកមកទស្សនាទាំងអស់ដែលបានអញ្ជើញមកចូលរួមប្រជុំ ទោះបីគាត់ជាប់រវល់ជាមួយនឹងការងារដកស្ទូងក៏ដោយ ។ ក្រុមថតខ្សែភាពយន្តបានគូសបញ្ជាក់ពីសារសំខាន់នៃកិច្ចប្រជុំនេះ ដោយលើកឡើងថា អ្នកចូលរួមមានឱកាសទស្សនាខ្សែភាពយន្តឯកសារ ពិភាក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ស្តាប់ព័ត៌មានថ្មីៗស្តីអំពីការងាររបស់តុលាការខ្មែរក្រហម និងដឹងអំពីការមកដល់នាពេលឆាប់ៗនៃក្រុមចុះជួយជនរងគ្រោះដាក់ពាក្យបណ្តឹងរបស់មជ្ឈមណ្ឌលឯកសារដែលនឹងជួយបំពេញពាក្យបណ្តឹងផ្ញើទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។


នារីសិល្បៈខ្មែរក្រហម

បន្ទាប់ពីបានស្តាប់កម្មវិធីរបស់ក្រុមថតខ្សែភាពយន្ត អ្នកភូមិជាច្រើនបានចាត់ទុកការបញ្ចាំងខ្សែភាពយន្តនេះថា ជាវិធីកម្សាន្តប្រកបដោយប្រសិទ្ធភាពដើម្បីទទួលបានព័ត៌មានថ្មីៗ ។ មានអ្នកភូមិខ្លះទៀតបានឆ្លៀតចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនអំពីការសម្តែងសិល្បៈនៅក្នុងភូមិនៅមុន និងក្នុងអំឡុងពេលសម័យខ្មែរក្រហម ។ អាស្រ័យហេតុនេះហើយ អត្ថបទនេះនឹងផ្តោតការយកចិត្តទុកដាក់ជាសំខាន់ថា តើរបបខ្មែរក្រហមបានប្រើប្រាស់សិល្បៈដើម្បីបណ្តុះមនោគមន៍វិជ្ជាប្រជាជនឲ្យគាំទ្របុព្វហេតុបដិវត្តន៍ និងកសាងបដិវត្តន៍របស់ខ្លួនដោយរបៀបណា ។ ទស្សនៈយោបល់របស់អ្នកផ្តល់បទសម្ភាសន៍ស្តីអំពីខ្សែភាពយន្តឯកសារដែលបានបញ្ចាំងនឹងលើកយកមកពិភាក្សាដែរ ។

### តួនាទីសិល្បៈក្នុងការសាបព្រោះមនោគមន៍វិជ្ជាបដិវត្តន៍

នៅខែមីនា ឆ្នាំ១៩៧០ ប្រជាជនកម្ពុជាឈានចូលទៅក្នុងព្រឹត្តិការណ៍ប្រកបដោយភាពច្របូកច្របល់ខាងផ្នែកសង្គមនយោបាយបន្ទាប់ពីឧត្តមសេនីយ៍ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះបាទ នរោត្តម សីហនុប្រកបដោយជោគជ័យ ហើយបានបង្កើតរបបសាធារណរដ្ឋខ្មែរ ។ ចាប់ពីពេលនោះមក ចលនាខ្មែរក្រហមមានឥទ្ធិពលកាន់តែខ្លាំងនៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា ហើយស្ទើរតែពេញប្រទេសផ្ទៃប្រទេសត្រូវបានរំខានដោយការប្រយុទ្ធគ្នាជាប់ជាប្រចាំ ។

តូច ស្រីរុន បាននិយាយថា នៅពេលនោះដោយសារតែភាពអសន្តិសុខ មនុស្សចំនួនដប់ក្រុមដែលមានយុវជនប្រមាណ

១០០នាក់ ត្រូវបានបង្កើតឡើងនៅក្នុងភូមិថ្កោលធំ ដើម្បីទប់ស្កាត់ការវាយប្រហារពីចលនាខ្មែរក្រហម ។ យោងទៅតាម ឡេង លី វិធានការការពារនេះបង្ហាញឲ្យឃើញពីការគ្មានប្រសិទ្ធិភាពក្នុងការការពារភូមិ ។ ខ្មែរក្រហមបានបោសសម្អាតអ្នកជាប់ពាក់ព័ន្ធរបប លន់ នល់ ក្នុងតំបន់នោះនៅចុងឆ្នាំ១៩៧០ ដោយបានជម្លៀសអ្នកភូមិចូលទៅក្នុងព្រៃជាញឹកញាប់ ។

ចាប់ផ្តើមគ្រប់គ្រងភូមិដំបូង ខ្មែរក្រហមបានបង្កើតក្រុមសិល្បៈតូចៗជាច្រើនក្រុមដែលមានយុវនារីនៅក្នុងភូមិចូលរួមយ៉ាងកុះករ ។ យុវជនត្រូវបានបង្ខំឲ្យចូលរួមជាមួយនឹងខ្មែរក្រហម ហើយការសម្តែងសិល្បៈត្រូវបានប្រើជាឧបករណ៍សម្រាប់បំពាក់បំប៉ននិងប្រមែប្រមូលយុវជនឲ្យបានកាន់តែច្រើន ដើម្បីប្រយុទ្ធប្រឆាំងនឹង «ចក្រពត្តិអាមេរិក និងបនបរិវាររបស់វា គឺរបប លន់ នល់» ។

រឿងរ៉ាវរបស់ តូច បានឆ្លុះបញ្ចាំងតាមរយៈខ្លឹមសារចម្រៀងបដិវត្តន៍ដែលបានចាក់ផ្សាយតាមវិទ្យុវណសិរ្សរួបរួមជាតិកម្ពុជា ។ ដោយមានការយល់ព្រមពីគណៈកម្មាធិការវប្បធម៌ សង្គមកិច្ចភូមិភាគបូព៌ានៃរបបកម្ពុជាប្រជាធិបតេយ្យ ឃ្លាទី៩និង១០ក្នុងបទចម្រៀងក្រោមចំណងជើងថា «យើងវាយបំបាក់សគ្រ្កាមអាកាសរបស់ចក្រពត្តិអាមេរិក» មានខ្លឹមសារដូចតទៅៈ

«ប្រជាជននិងកងទ័ពបដិវត្ត កម្ពុជាមោះមុតលះបង់អស្ចារ្យលះបង់កូនចៅលះបង់ជីវ៉ា ឈាមក្រហមស្រស់ថ្វាហូរជោកប្រឹថពីចក្រពត្តិអាមេរិកមេខ្លោងក្នុងលោក ក្បាលរឹងបំផុតសាហាវព្រៃផ្សៃ១៥ សីហាត្រូវយើងប្រល័យ ឲ្យវាបរាជ័យយ៉ាងអាម៉ាស់បំផុត» ។

ឡេង លី សង្កេតឃើញថា ជាមួយនឹងការអំពាវនាវរបស់សម្តេចសីហនុទៅកាន់ប្រជាជនកម្ពុជាឲ្យចូលព្រៃដើម្បីប្រយុទ្ធប្រឆាំងនឹងរបប លន់ នល់ ចម្រៀងប្រឆាំងចក្រពត្តិបានដើរតួនាទីដ៏សំខាន់ក្នុងការកសាងកម្លាំងបដិវត្តន៍ខ្មែរក្រហមពង្រឹងទស្សនៈនយោបាយ និងសាបព្រោះមនោគមន៍វិជ្ជាកុម្មុយនីស្ត ។ ខណៈដែលមនុស្សជាច្រើនគាំទ្រចលនាខ្មែរក្រហម គ្រួសាររបស់ ឡេង លី បានសម្រេចចិត្តចាកចេញពីភូមិថ្កោលធំឆ្ពោះទៅកាន់ភូមិឆ្នុកទ្រូខេត្តកំពង់ឆ្នាំង ។ តែទោះជាយ៉ាងណាក៏ដោយ សេចក្តីសង្ឃឹមរបស់គ្រួសារលីក្នុងការស្វែងរកកន្លែងមានសុវត្ថិភាពនៅក្នុងខេត្តកំពង់ឆ្នាំងត្រូវបានបញ្ចប់ដោយសារតែជ័យជម្នះទាំងស្រុងរបស់ចលនាខ្មែរក្រហមទៅលើរបប លន់ នល់ ក្នុងខែមេសា ឆ្នាំ១៩៧៥ ។

## ប្រើប្រាស់ការសម្តែងសិល្បៈជំរុញឲ្យប្រជាជនខំកសាងបដិវត្តន៍

គោលនយោបាយជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងនិងទីប្រជុំជននានាទៅកាន់តំបន់ជនបទត្រូវបានធ្វើឡើងភ្លាមៗបន្ទាប់ពីខ្មែរក្រហមបានវាយឲ្យរបប លន់ នល់ ទទួលបរាជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ឈួន លាវ អាយុ៦០ឆ្នាំ រស់នៅភូមិថ្កោលធំ បាននិយាយរំឭកឡើងវិញនូវថ្ងៃដែលគាត់ត្រូវបានបង្ខំឲ្យបោះបង់ចោលផ្ទះសម្បែងៈ

«ខ្ញុំមិនបានយកអង្ករបស់របរអ្វីទៅជាមួយទេ ដោយសារតែខ្មែរក្រហមប្រកាសថា ការជម្លៀសនេះមានរយៈពេលតែបីថ្ងៃប៉ុណ្ណោះ ។ នៅខែឧសភា ឈ្លបខ្មែរក្រហមបានបញ្ជាឲ្យខ្ញុំទៅរស់នៅតាមកន្លែងខុសៗគ្នាជាច្រើនដែលគ្មានស្បៀងអាហារ ។ កូនប្រុសរបស់ខ្ញុំម្នាក់បានស្លាប់នៅអាយុ៩ខែដោយសារកង្វះអាហាររូបត្ថម្ភ» ។

មេដឹកនាំខ្មែរក្រហមបានអនុវត្តគោលនយោបាយប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជាសង្គមកសិកម្ម ដែលប្រជាជនគ្រប់រូបមានឋានៈសង្គមដូចគ្នា «វណ្ណៈពលករ-កសិករ» ។ ទស្សនៈវិស័យរបស់មេដឹកនាំខ្មែរក្រហមគឺ ចង់កសាងប្រទេសតាមរបៀប «មហាអស្ចារ្យមហាលោតផ្លោះ» ។ ដូច្នេះហើយ ទើបមេដឹកនាំទាំងនេះមិនបានយកចិត្តទុកដាក់ចំពោះបញ្ហាទុរ្ភិក្ស ជំងឺតម្កាត់ ការបាត់បង់ជីវិត និងធ្វើការងាររហូសកម្លាំងឡើយដែលនៅទីបញ្ចប់បានឆក់យកជីវិតប្រជាជនប្រមាណ១លាន៧សែននាក់ចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ ។

ដោយមិនចាត់វិធានការជាក់ស្តែងដើម្បីជួយឧបត្ថម្ភដល់មនុស្សដែលកំពុងប៉ះទង្គិចផ្លូវចិត្ត និងហេវហត់អស់កម្លាំង អង្គការខ្មែរក្រហមបែរជាយកការសម្តែងសិល្បៈមកកម្សាន្តទៅវិញ ។

ប្រាក់ លៀង អាយុ៥៥ឆ្នាំ រស់នៅភូមិថ្កោលធំបាននិយាយថា នៅពេលសម្រាក បន្ទាប់ពីធ្វើការងារតាំងពីព្រលឹមរហូតដល់ព្រលប់ប្រជាជននៅក្នុងសហករណ៍ត្រូវបានខ្មែរក្រហមណែនាំឲ្យហ្វឹកហាត់សិល្បៈថែមទៀត ។ យោងទៅតាមសម្តី ឡេង លី បានឲ្យដឹងថា បើទោះបីជាកងបុរស-ស្ត្រី និងកុមារធ្វើការដាច់ដោយឡែកៗពីគ្នាក៏ដោយក៏កងនីមួយៗ ត្រូវបានខ្មែរក្រហមតម្រូវឲ្យរាំនិងច្រៀងចម្រៀងផងដែរ ។ ឡេង លី បាននិយាយថា នៅក្នុងសហករណ៍របស់គាត់ រឿង ប្រធានកងនារីជាអ្នកទទួលបន្ទុកបង្ហាត់

បង្រៀនប្រជាជននៅតាមការដ្ឋានលើកទំនប់ ។

ដើម្បីផ្តល់ការកម្សាន្តដល់មនុស្សនៅក្នុងសហករណ៍ រៀងតែងតែជ្រើសរើស តូច ឲ្យច្រៀង និងរាំពេលសម្រាកពីការងារ ។ ទោះជាយ៉ាងណាក៏ដោយ តូច និយាយទាំងលាក់លៀមថា គាត់ត្រូវបានបង្ខំឲ្យសម្តែងសិល្បៈ បើទោះជាការសម្តែងនេះត្រូវបានបង្កើតឡើងគ្រាន់តែដើម្បីផ្តល់ការសប្បាយ ដល់ខ្លួនគាត់និងសមាជិកទាំងអស់នៅក្នុងសហករណ៍ និងធ្វើឲ្យអ្នកទាំងនោះញញឹមជំនួសការស្រេកឃ្លានរបស់ពួកគេក៏ដោយ ។

តូច បាននិយាយរំឭកឡើងវិញថា នៅឆ្នាំ១៩៧៧ ខ្លួនគាត់និងស្ត្រី១០០នាក់នៅក្នុងសហករណ៍របស់គាត់ត្រូវបានប្រាប់ឲ្យធ្វើដំណើរដោយថ្មើរជើងទៅកាន់ទីរួមខេត្តកំពង់ឆ្នាំង ដើម្បីទស្សនាការសម្តែងសិល្បៈ ។ បន្ទាប់ពីសួរសំណួរទាក់ទងនឹងការសម្តែងនោះមានលក្ខណៈបែបណា តូច បាននិយាយថា ការសម្តែងនោះរៀបរាប់អំពីសង្គ្រាមប្រកបដោយជោគជ័យរបស់ខ្មែរក្រហមទៅលើរបប លន់ នល់ និងការប្រមូលផលស្រូវ ។ តូច បានរំឭកឡើងវិញពីខ្លឹមសារបទចម្រៀងដែលមានចំណងជើងថា «ជយោ! ថ្ងៃ១៧ មេសា យើងរំដោះភ្នំពេញ»: «គ្រប់មុខព្រួញខ្លួលខ្មាញ់បាញ់សម្រុកចំៗសំបុកបនអានល់... កងយើងទៅមុខវាយខ្ទេចខ្ទុកខ្ទែ្ក ចក្រពត្តិទាំងរបបទាំងបុគ្គល មហាក្បត់ វាំឲ្យវារលត់ផុតរលាយជាអវសាន្ត ១៧ខែមេសា ឆ្នាំ៧៥ កងយើងឧត្តមបានរំដោះ ក្រុងភ្នំពេញគ្រប់មុខព្រួញចូលចាប់.....» ។

ចម្រៀងមួយបទទៀតក្រោមចំណងជើងថា «នារីក្រុមសាមគ្គីបង្កបង្កើនផល» ថ្លែងអំពីការងារដ៏លំបាកលំបិនដោយក្រុមស្ត្រី: «អឹងអឺយ យើងខ្ញុំនារី ក្នុងក្រុមសាមគ្គី បង្កើនផលល្អសប្បាយរីករាយគ្រប់គ្នា រួមធ្វើការងារ យ៉ាងមមាញឹក ។ អឹងអឺយទៅដល់ស្រែភ្លាម យើងខ្ញុំចាប់ផ្តើម ធ្វើការសស្រាញ់ ខ្លះភ្ជួរខ្លះរាស់រលេញ អ្នកស្ទូងចុះពេញ ស្ទូងស្មើដៃគ្នា» ។

តូច មានចម្ងល់ថាតើការសម្តែងសិល្បៈទាំងនេះរំពឹងថា នឹង



ធ្វើឲ្យគាត់សប្បាយចិត្តយ៉ាងម៉េចកើត បើនៅពេលនោះគាត់ឃ្លានផងនុយដេក និងហេវហត់អស់កម្លាំងយ៉ាងនេះ ។ តូច បានពន្យល់ថា បន្ទាប់ពីធ្វើការធ្ងន់ធ្ងរច្រើនម៉ោង សមាជិកសហករណ៍របស់គាត់ត្រូវបានបង្ខំឲ្យទស្សនាការសម្តែងបែបនេះរហូតដល់ជិតភ្លឺ ។ ជួនកាលសម្រាកបានតែមួយឬពីរម៉ោងប៉ុណ្ណោះ អ្នកទាំងអស់ត្រូវត្រឡប់ទៅធ្វើការងារវិញ ។ ជាការកត់សម្គាល់ ឡេង លី បាននិយាយថា សមាជិកនៅក្នុងសហករណ៍ចំនួនជាង៧០នាក់ ក្នុងចំណោម១៨០នាក់បានស្លាប់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ទស្សនៈទូទៅស្តីអំពីខ្សែភាពយន្តឯកសារខ្មែរក្រហម

ដោយសារតែភាពលំបាកច្រើនរាប់មិនអស់ដែលអ្នកភូមិបានជួបប្រទះ និងការបាត់បង់អ្នកដែលជាទីស្រឡាញ់របស់ខ្លួន អ្នករស់រានមានជីវិតមិនអាចបំភ្លេចសម័យខ្មែរក្រហមបានទេ ចាប់តាំងពីរបបនេះដួលរលំនៅឆ្នាំ១៩៧៩ ។ អ្នកទាំងអស់បានជ្រើសរើសយកវិធីជាច្រើនដើម្បីថែរក្សាការចងចាំ ដោយរាប់ចាប់តាំងពីការនិយាយរឿងមិនមានលក្ខណៈផ្លូវការ រហូតដល់មានការអំពាវនាវឲ្យគ្រៀនសិស្សសាលាបច្ចុប្បន្នអំពីសម័យខ្មែរក្រហម ។ ការធ្វើដំណើររបស់ក្រុមថតខ្សែភាពយន្តមកដល់ភូមិថ្កោលធំ ដែលត្រូវបានរៀបចំឡើងដើម្បីពិភាក្សាបញ្ហាទាំងអស់នេះ ។ បន្ទាប់ពីបានព្ព័ត៌មានថ្មីៗអំពីដំណើរការជំនុំជម្រះក្តីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមប្រាំនាក់ដែលកំពុងជាប់ឃុំខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អ្នកភូមិបានទស្សនាខ្សែភាពយន្តឯកសារចំនួនពីររឿង «គ្រៀមខ្លួនដើម្បីរកយុត្តិធម៌» និង «នៅកៀនជញ្ជាំងស-២១ ប្រវត្តិសាស្ត្រផ្ទាល់មាត់ពីគុកទួលស្លែង» ។

តូច គិតថា តាមរយៈមធ្យោបាយសិល្បៈ ដូចជាការបញ្ចាំងកុននេះអ្នកភូមិអាចកាន់តែមានលទ្ធភាពប្រសើរឡើងក្នុងការយល់ដឹងពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម និងជួយក្មេងៗឲ្យដឹងពីប្រវត្តិខ្មែរក្រហម ។ តែទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីបានរស់នៅឆ្លងកាត់រយៈពេលដ៏ជូរចត់ក្នុងជំនាន់ខ្មែរក្រហម ឡេង លី យល់ឃើញថា ប្រវត្តិសាស្ត្រនេះមានលក្ខណៈពិបាក និងធ្វើឲ្យក្រៀមក្រំចិត្តនៅពេលរំឭកអំពីការចងចាំនូវសម័យកាលនោះ ។

ឡេង លី បានព្រមានកុំឲ្យមានអ្នកខ្លះយល់ថា ខ្មែរក្រហមធ្វើល្អសម្រាប់ប្រទេសកម្ពុជា ហើយនិយាយអំពីការឈឺចាប់ដែលមិនអាចរៀបរាប់អស់ដែលរបបនោះបានធ្វើមកលើប្រជាជនកម្ពុជាទាំងមូល ។

ឡេង លី ក៏យល់ថាការបញ្ចាំងខ្សែភាពយន្តជាវិធីមួយដ៏មានសារសំខាន់ដែលអាចផ្តល់ជាព័ត៌មានទៅឲ្យអ្នកភូមិអំពីប្រវត្តិសាស្ត្រនិងសាលាក្តីខ្មែរក្រហម ។ ទោះបីជា ឡេង លី បានដឹងតាមការផ្សព្វផ្សាយតាមវិទ្យុថា មានការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមក៏ដោយ ក៏មុនពេលក្រុមថតខ្សែភាពយន្តមកដល់ គាត់មិនបានដឹងឈ្មោះមេដឹកនាំខ្មែរក្រហមដែលត្រូវចោទប្រកាន់នោះទេ គឺដឹងតែព័ត៌មាននានាស្តីអំពីដំណើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍សម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ននៅចំពោះមុខអង្គបុរេជំនុំជម្រះវិសាមញ្ញនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប៉ុណ្ណោះ ។

## សេចក្តីសន្និដ្ឋាន

អ្នកភូមិថ្កោលធំមានចំណាប់អារម្មណ៍ខ្លាំងក្នុងការរៀនប្រវត្តិសាស្ត្រខ្មែរក្រហម និងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ ចំណែកអ្នកភូមិខ្លះសុខចិត្តចំណាយពេលវេលាដ៏មមាញឹកមកឲ្យសមាជិកក្រុមថតខ្សែភាពយន្តរបស់យើងធ្វើការសម្ភាសន៍អស់រយៈពេលជាច្រើនម៉ោងអំពីប្រវត្តិជីវិតផ្ទាល់ខ្លួននៅក្នុងសម័យខ្មែរក្រហម ។ អ្នកភូមិជាច្រើនទៀតបានរំឭកឡើងវិញថា ពីមុនខ្មែរក្រហមបានយកសិល្បៈមកប្រើដើម្បីដុតបញ្ឆេះអារម្មណ៍ឲ្យប្រឆាំង របប លន់ នល់ និងចក្រពត្តិអាមេរិកាំង និងកែនអ្នកភូមិឲ្យគាំទ្របុព្វហេតុបដិវត្តន៍របស់ខ្លួន ។ ក្នុងអំឡុងពេលនៃការគ្រប់គ្រងអំណាចចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ ការសម្តែងសិល្បៈគឺជាឧបករណ៍ លើកទឹកចិត្តប្រជាជនដែលហេវហត់អស់កម្លាំងឲ្យប្រឹងប្រែងធ្វើការងារខ្លាំងថែមទៀតដើម្បីបដិវត្តន៍ បើទោះជាមានចំនួនមនុស្សស្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់ក៏ដោយ ។ ផ្ទុយទៅវិញ សព្វថ្ងៃនេះ ក្រុមថតខ្សែភាពយន្តកំពុងប្រើប្រាស់សិល្បៈនេះដើម្បីបង្កើតការពិភាក្សាអំពីការជំនុំជម្រះសេចក្តីអ្នកដែលទទួលខុសត្រូវចំពោះការស្លាប់ប្រជាជន ព្រមទាំងលើកទឹកចិត្តឲ្យអ្នករស់រានមានជីវិតស្វែងរកនូវការផ្សះផ្សាក្នុងសង្គមជាមួយនឹងអតីតកាលប្រកបដោយភាពសោកសង្រេងនេះ ។

**លី សុខឃាង**

# ការស្ទង់មតិជាសាធារណៈអំពីសាលាក្តីខ្មែរក្រហម

របាយការណ៍ចេញផ្សាយដោយវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិទាក់ទងនឹងសាលាក្តីខ្មែរក្រហម បានធ្វើឡើងចាប់ពីថ្ងៃទី២៧ ខែមករា ដល់ថ្ងៃទី២៦ ខែកុម្ភ ឆ្នាំ២០០៨ ដោយមជ្ឈមណ្ឌលអប់រំជាន់ខ្ពស់ដែលមានទីតាំងនៅភ្នំពេញប្រទេសកម្ពុជា ។ ការស្ទង់មតិនេះធ្វើឡើងនៅ២២ខេត្ត-ក្រុង លើកលែងតែខេត្តចំនួនពីរគឺ ខេត្តមណ្ឌលគិរី និងក្រុងកែប ដែលមានប្រជាជនសរុបចំនួន២០០០នាក់ តំណាងឲ្យប្រជាជនទូទាំងប្រទេស មានអាយុចាប់ពី១៨ឆ្នាំឡើងទៅ និងមានទីលំនៅច្បាស់លាស់ ។

មជ្ឈមណ្ឌលអប់រំជាន់ខ្ពស់បានចងក្រងជាកម្រងសំណួរចំនួនបីដើម្បីស្ទង់មតិប្រជាជនៈ

**១) តើអ្នកបានដឹងឮពីសាលាក្តីខ្មែរក្រហមដែលនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ដែរឬទេ?**

ចម្លើយដែលប្រមូលបាន គឺប្រជាជនចំនួន៧១ភាគរយបានដឹងឮពីសាលាក្តីខ្មែរក្រហមដែលនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស និង២៩ភាគរយមិនបានដឹងឮ ។

**២) តើអ្នកបានដឹងឮពីសាលាក្តីខ្មែរក្រហមដែលនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ឬទេ? នៅក្នុងសំណួរនេះ យើងស្រង់យកចម្លើយតាមរយៈប្រភពព័ត៌មានពីរគឺៈ**

ប្រភពព័ត៌មានដើមៈ តាមរយៈការស្តាប់វិទ្យុ មានចំនួន៨១ភាគរយដែលបានដឹង និង ១៩ភាគរយមិនដឹង ។ តាមរយៈមើលទូរទស្សន៍ មានចំនួន៦៧ភាគរយបានដឹង និង ៣៣ភាគរយមិនដឹង ។ តាមរយៈការនិយាយតៗគ្នា មានចំនួន៤២បានដឹង និង ៥៨ភាគរយមិនដឹង ។

នៅក្នុងចម្លើយយើងពិនិត្យឃើញថា ប្រជាជនកម្ពុជាភាគច្រើនបានដឹងឮតាមរយៈវិទ្យុ អំពីសាលាក្តីខ្មែរក្រហមដែលនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ។

ប្រភពអាយុៈ អាយុចាប់ពី១៨-២៤ឆ្នាំ មាន៦៦ភាគរយដឹង និង ៣៤ភាគរយមិនដឹង ។ អាយុចាប់ពី២៥-២៩ឆ្នាំ មាន៦៦ដឹង និង ៣៤ភាគរយមិនដឹង ។ អាយុចាប់ពី៣០-៣៩ មាន៦៧ភាគរយដឹង និង ៣៣ភាគរយមិនដឹង ។ អាយុចាប់ពី៤០-៤៩ឆ្នាំ មាន៧២ភាគរយដឹង និង ២៨ភាគមិនដឹង ។ អាយុចាប់ពី៥០-៥៩ឆ្នាំ មាន៧៩ភាគរយដឹង និង ២១មិនភាគរយដឹង ។ អាយុចាប់ពី៦០ឡើងទៅ មាន៧៩ដឹង និង ២១មិនដឹង ។

លទ្ធផលដែលទទួលបាន គឺប្រជាជនដែលមានអាយុចាប់ពី៦០ឡើងទៅ បានដឹងឮច្រើនអំពី តុលាការកាត់ទោសមេដឹកនាំខ្មែរជាន់ខ្ពស់ខ្មែរក្រហម ពីព្រោះប្រជាជនដែលធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមទាំងអស់គ្មាននរណាម្នាក់គេចផុតពីការបង្ខំឲ្យធ្វើការងារជាទម្ងន់ បង្អត់អាហារ ទារុណកម្ម និងការស្លាប់បាត់បង់បងប្អូនឡើយ ។ ទោះបី ជារបបនេះកន្លងផុតទៅអស់រយៈ៣០ឆ្នាំហើយក៏ដោយ ក៏បទពិសោធន៍ និងការឈឺចាប់ដែលគាត់ធ្លាប់បានទទួល នៅតែដក់ជាប់ក្នុងចិត្តរបស់គាត់ជានិច្ច ។

**៣) តើអ្នកគាំទ្រ ឬមិនគាំទ្រ ចំពោះការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម?**

ក្នុងក្រាហ៊ិកបង្ហាញថា មាន៦៩ភាគរយ គាំទ្រខ្លាំង ។ មាន១៧ភាគរយ គាំទ្រតិចតួច និង ៦ភាគរយ គ្មានយោបល់ ។ ៣ភាគរយ មិនគាំទ្រ ហើយ ៣ភាគរយទៀត មិនដឹង ។

តាមរយៈការស្ទង់មតិនេះបង្ហាញថា នៅតែមានប្រជាជនខ្លះមិនទាន់ដឹងឮព័ត៌មានអំពីសាលាក្តីខ្មែរក្រហមនៅឡើយ ទោះបីជាមានអង្គការនិងស្ថាប័នជាច្រើនដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម អង្គការអាដហុក និងអង្គជំនុំជម្រះវិសាមញ្ញផ្ទាល់ បានធ្វើការចុះផ្សព្វផ្សាយច្រើនអំពីសាលាក្តីនេះក៏ដោយ ។

កន្លងមកមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងជាច្រើនដើម្បីធ្វើការផ្សព្វផ្សាយអំពីសាលាក្តីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមានដូចជា គម្រោងជំរុញឲ្យមានការទទួលខុសត្រូវៈ បានចុះទៅសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហមចំនួនជាង១ម៉ឺននាក់នៅស្ទើរគ្រប់ខេត្តក្រុងទូទាំងប្រទេស ។ គម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងៈ មានជនរងគ្រោះប្រមាណ

១០០០នាក់ បានដាក់ពាក្យបណ្តឹងទៅអង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការិយាល័យព័ត៌មានសាធារណៈ បានអញ្ជើញមេឃុំ មេភូមិ និងប្រជាជនប្រមាណ១០៩០នាក់ នៅទូទាំងប្រទេសមកទស្សនាវាលពិឃាតជើងឯក សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ទីតាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចូលរួមស្តាប់ការពន្យល់របស់មន្ត្រីតុលាការ និងអានទស្សនាវដ្តីស្វែងរកការពិត ដែលបានសរសេររឿងរ៉ាវទាក់ទងសម័យខ្មែរក្រហម និងសាលាក្តីខ្មែរក្រហម ហើយធ្វើការចែកចាយទៅគ្រប់បណ្តាខេត្តក្រុងទូទាំងប្រទេសដោយមិនរាប់បញ្ចូលនូវទូរលេខដែលអង្គការមួយចំនួនចូលរួមធ្វើកិច្ចការនេះផងទេ ។

ចាប់តាំងពីសាលាក្តីខ្មែរក្រហមត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ យើងសង្កេតឃើញថា ការផ្សារផ្សព្វផ្សាយព័ត៌មានសាធារណៈទៅកាន់មជ្ឈដ្ឋានប្រជាជនមានលក្ខណៈទូលំទូលាយ ។ ថ្មីៗនេះតាមរបាយការណ៍របស់វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិរកឃើញថា ប្រជាជន៧១ភាគរយបានដឹងឮអំពីសាលាក្តីខ្មែរក្រហម និង ២៩ភាគរយមិនដឹង ប៉ុន្តែ ទោះជាយ៉ាងនេះក្តីតាមរយៈការផ្សារដែលបានធ្វើកន្លងមក យើងនៅតែមានសុទិដ្ឋិនិយមថាប្រជាជនស្ទើរទូទាំងប្រទេសបានដឹងឮអំពីសាលាក្តីខ្មែរក្រហម ។

**សោម ប៊ុនថន**

# និយមន័យឧក្រិដ្ឋកម្ម

ឧក្រិដ្ឋកម្មអន្តរជាតិនីមួយៗច្រើនគ្របដណ្តប់ទៅលើបណ្តុំនៃឧក្រិដ្ឋកម្មជាបុគ្គល ។ ឧក្រិដ្ឋកម្មសំខាន់ទាំងនេះមានភាពស្រដៀងនឹងច្បាប់របស់ប្រទេសដែលហាមឃាត់ឧក្រិដ្ឋកម្មផ្សេងៗ ដូចជាបទល្មើស ភាពចលាចល និងឃាតកម្ម ទោះបីជាឧក្រិដ្ឋកម្មសង្គ្រាមជាច្រើនមិនសូវមានក្នុងច្បាប់មនុស្សធម៌អន្តរជាតិក៏ដោយ ។ ឧក្រិដ្ឋកម្មសំខាន់ទាំងនេះត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មអន្តរជាតិនៅពេលដែលករណីនេះជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មស្រដៀងគ្នាដែលកើតមានរួចហើយ ។ ការប្រឈមដ៏ធំដើម្បីការលូតលាស់ និងការបកស្រាយផ្នែកច្បាប់ប្រឆាំងឧក្រិដ្ឋកម្មអន្តរជាតិ គឺការកំណត់ករណីដែលកើតឡើងទាំងនេះដើម្បីបែងចែកឧក្រិដ្ឋកម្មអន្តរជាតិឲ្យដាច់ចេញពីឧក្រិដ្ឋកម្មក្នុងប្រទេស ។ ឧទាហរណ៍ តើលក្ខណៈអ្វីខ្លះដែលកំណត់សកម្មភាពឃាតកម្ម ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឬទង្វើប្រល័យពូជសាសន៍? ការកំណត់និយមន័យឧក្រិដ្ឋកម្មអន្តរជាតិបានប្រើប្រាស់នូវវិធីសាស្ត្រជាច្រើនដូចបានរៀបរាប់ខាងក្រោម ។

ការពន្យល់ដ៏ងាយស្រួលសម្រាប់បង្ហាញភាពខុសគ្នារវាងឧក្រិដ្ឋកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មក្នុងប្រទេស គឺឧក្រិដ្ឋកម្មអន្តរជាតិជាឧក្រិដ្ឋកម្មទាំងឡាយណាដែលត្រូវបានកាត់ក្តីនៅមុខតុលាការអន្តរជាតិ ។ ទោះជាយ៉ាងនេះក្តី ការពន្យល់នេះលើកជាបញ្ហាថាតើមាន់និងពងមាន់មួយណាកើតមុន គឺថាឧក្រិដ្ឋកម្មអន្តរជាតិចាត់ទុកជាអន្តរជាតិដោយសារវាត្រូវបានកាត់ទោសនៅមុខសាលាក្តីអន្តរជាតិ ឬក៏ឧក្រិដ្ឋកម្មទាំងនេះត្រូវបានកាត់ទោសនៅមុខសាលាក្តីអន្តរជាតិដោយសារវាជាឧក្រិដ្ឋកម្មអន្តរជាតិ?

តាមរយៈដើមកំណើតនៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិមានការផ្សារភ្ជាប់ទៅនឹងស្ថានភាពនៃសង្គ្រាមត្រូវបានចាត់ទុកថា ជាការចាំបាច់ដើម្បីធ្វើអន្តរូបនីយកម្មនូវអ្វីដែលមិនចាត់ទុកជាឧក្រិដ្ឋកម្មធម្មតា ។ នៅពេលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានកម្រិតស្មើនឹងការដាក់បន្ទុកប្រឆាំងនឹងចុងចោទណាហ្សី តុលាការនូរីមប៊ឺកបានកំណត់យុត្តាធិការរបស់ខ្លួនតាមរបៀបដែលតម្រូវឲ្យមានការបង្ហាញថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពិតជាមានទំនាក់ទំនងនឹងគោលនយោបាយធ្វើសង្គ្រាមឈ្លានពានរបស់ណាហ្ស៊ី ឬបេសកកម្មនៃឧក្រិដ្ឋកម្មសង្គ្រាមណាហ្ស៊ី ។ តាមការយល់ឃើញបែបនេះ តុលាការមិនមានការសង្ស័យទៅនឹងអត្ថន័យបដិវត្តន៍នៃការកាត់ទោសមន្ត្រីរដ្ឋការ និងបុគ្គលឯកជនសម្រាប់ទង្វើដែលប្រព្រឹត្តប្រឆាំងនឹងជនរួមជាតិរបស់ពួកគេ ។ តុលាការក៏មានការព្រួយបារម្ភជាមួយនឹងការជំរុញឲ្យមានច្បាប់កាត់ទោសនៅមុនពេលឧក្រិដ្ឋកម្ម

ប្រឆាំងមនុស្សជាតិមិនមែនជាខ្លឹមសារដែលចែងនៅក្នុងសន្និសញ្ញាពហុភាគីនៅពេលនោះ និងមិនត្រូវបានកាត់ក្តីនៅមុខតុលាការអន្តរជាតិ ឬនៅប្រទេសណាមួយឡើយ ។ ទោះបីជាវាមិនច្បាស់លាស់ថា ករណីនេះបានកើតឡើងនៅពេលណា ប៉ុន្តែឥឡូវត្រូវបានកំណត់យ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺមានសភាពខុសប្លែកទាំងស្រុងពីរដ្ឋធ្វើសង្រ្គាម និងការកាត់ទោសដោយកំបាំងមុខ ។

ជាការពិត ឧក្រិដ្ឋកម្មសង្រ្គាមមានធាតុផ្សំដែលទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធជាអន្តរជាតិ ឬមិនមែនអន្តរជាតិ ។ ការរំខានផ្ទៃក្នុង កុបកម្មដែលសម្តែងឲ្យឃើញពីភាពខ្សោយ ឬគណបក្សប្រឆាំងដែលមិនមានអំណាចគ្រប់គ្រាន់ មិនជំរុញឲ្យមានច្បាប់មនុស្សធម៌អន្តរជាតិ ឬមិនបានហាមឃាត់ឧក្រិដ្ឋកម្មសង្រ្គាម ។ ផ្ទុយទៅវិញ កន្លែងដែលជម្លោះប្រដាប់អាវុធកើតមានមិនថា អន្តរជាតិ ឬមិនមែនអន្តរជាតិ ឧក្រិដ្ឋកម្មដែលជាប់ពាក់ព័ន្ធនោះអាចចាត់ទុកជាឧក្រិដ្ឋកម្មសង្រ្គាម ។ ច្បាប់បន្តប្រឹងប្រែងជាមួយនឹងបញ្ហាថាតើមានភាពខុសគ្នាអ្វីខ្លះរវាងឧក្រិដ្ឋកម្ម និងជម្លោះប្រដាប់អាវុធដែលបានលើកឡើង ។

វិធីមួយដើម្បីបង្ហាញភាពខុសគ្នារវាងឧក្រិដ្ឋកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មក្នុងប្រទេស គឺតាមរយៈការផ្តោតលើទិដ្ឋភាពសកលដែលក្នុងនោះឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងរដ្ឋចាប់ពីពីរឡើងទៅតាមរយៈសញ្ជាតិនៃជនរងគ្រោះ ជនល្មើស ឬទីកន្លែងនៃបេសកកម្ម ។ តាមប្រវត្តិសាស្រ្តច្បាប់មនុស្សធម៌អន្តរជាតិបានទទួលស្គាល់ឧក្រិដ្ឋកម្មសង្រ្គាមជាទង្វើដែលប្រព្រឹត្តប្រឆាំងនឹងជាតិសាសន៍មួយផ្សេងទៀតដែលបង្កឲ្យមានជម្លោះប្រដាប់អាវុធជាអន្តរជាតិ ។ ច្បាប់រដ្ឋមានតិចតួចណាស់ដែលលើកឡើងពីជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (រួមបញ្ចូលជម្លោះផ្ទៃក្នុង ឬសង្រ្គាមស៊ីវិលដែលបង្កឲ្យជនរួមជាតិឈ្លោះគ្នា) មិនរួមបញ្ចូលសមាសភាពព្រហ្មទណ្ឌ ។ តាមរយៈនីតិវិធីនៃតុលាការអន្តរជាតិ សញ្ញាណនៃឧក្រិដ្ឋកម្មសង្រ្គាមក្រៅពីជម្លោះប្រដាប់អាវុធអន្តរជាតិត្រូវបានទទួលស្គាល់ពេញលេញនៅពេលបច្ចុប្បន្ន ។

ឧក្រិដ្ឋកម្មអន្តរជាតិក៏អាចចាត់ទុកជាឧក្រិដ្ឋកម្មទាំងឡាយណាដែលរំខានសណ្តាប់ធ្នាប់សាធារណៈអន្តរជាតិ បង្កគ្រោះថ្នាក់ដល់សន្តិភាព និងសន្តិសុខសហគមន៍អន្តរជាតិទាំងមូល ។ អំពើហិង្សាដ៏ឃោរឃៅ ការសម្លាប់ផ្តាច់ពូជប្រជាជនទាំងអស់ និងសូម្បីតែបេសកកម្ម ឧក្រិដ្ឋកម្មសង្រ្គាមធំៗក៏អាចបង្កអស្ថិរភាពតំបន់ទាំងមូលហើយនាំទៅរកជម្លោះប្រដាប់អាវុធអន្តរជាតិ ដូច្នេះការឆ្លើយតបនឹងរឿងព្រហ្មទណ្ឌជាអន្តរជាតិដែលមានលក្ខណៈជាសមូហភាពនិងដែលត្រូវបានសម្របសម្រួលជារឿងត្រឹមត្រូវ ។

ទំនាក់ទំនងនៃឧក្រិដ្ឋកម្មអន្តរជាតិ គឺផ្អែកលើការយល់ថាកម្រិតឃោរឃៅ និងភាពជាក់ស្តែង គឺជាការព្រួយបារម្ភនៃមនុស្សជាតិទាំងមូលដែលមិនត្រឹមតែជាការបារម្ភនៃជនរងគ្រោះ ឬអង្គភាពមួយប៉ុណ្ណោះទេ ។ នេះជាករណីដែលមិនបានកើតឡើងលើគ្រប់ជាតិសាសន៍ ។ ឧទាហរណ៍ មាត្រា១នៃបញ្ញត្តិតុលាការឧក្រិដ្ឋកម្មអន្តរជាតិកម្រិតសិទ្ធិនៃយុត្តាធិការចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដែលជាការព្រួយបារម្ភរបស់អន្តរជាតិ ។

នៅខណៈដែលវាជាបញ្ហាដែលមានការពិសោធន៍ច្បាស់លាស់ថា សាលាក្តីអន្តរជាតិដែលប្រើយុត្តាធិការអន្តរជាតិ និងតុលាការក្នុងប្រទេសដែលអនុវត្តតាមយុត្តាធិការជាសាកលបានផ្តោតលើឧក្រិដ្ឋកម្មដែលមានភាពធ្ងន់ធ្ងរបំផុត ឬការខូចខាតការប្រើភាពធ្ងន់ធ្ងរដើម្បីកំណត់ឧក្រិដ្ឋកម្មអន្តរជាតិ គឺមានភាពអត្តនោម័តខ្លះដែលការខូតខាតបង្កដោយឧក្រិដ្ឋកម្មផ្សេងៗមិនអាចវាស់វែងជារួមបាន ។ ជាបន្ថែម និយមន័យថ្មីភាគច្រើននៃឧក្រិដ្ឋកម្មអន្តរជាតិបង្ហាញពីការកាត់ទោសលើទង្វើឧក្រិដ្ឋកម្មមួយៗដាច់ពីគ្នា ប្រសិនបើឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តក្នុងបរិបទដែលមានការបំពាន ។

ការរាវរែកមួយនេះផ្តោតទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះជាមូលដ្ឋានរួមសម្រាប់ច្បាប់ប្រឆាំងឧក្រិដ្ឋកម្មអន្តរជាតិ ។ ឧក្រិដ្ឋកម្មអន្តរជាតិជាច្រើនជាប់ពាក់ព័ន្ធនឹងការគាបសង្កត់ជាក្រុម ។ សំខាន់បំផុត ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ (ឧក្រិដ្ឋកម្មមួយប្រឆាំងមនុស្សជាតិ) តម្រូវថា ជនរងគ្រោះជាគោលដៅដោយសារគាត់ជាសមាជិករបស់ក្រុមជាក់លាក់មួយ ឬដោយសារការរើសអើង ។ ទោះជាយ៉ាងនេះក្តី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀតត្រូវបានកាត់ទោស ប្រសិនបើឧក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តក្នុងស្ថានភាពវាយប្រហារដែលរាលដាល ឬជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល ។

ត្រឡប់មកនិយាយពីឧក្រិដ្ឋកម្មសង្គ្រាមវិញ បទបញ្ញត្តិព្រហ្មទណ្ឌនៃសន្ធិសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានអនុវត្តលុះណាតែជនរងគ្រោះត្រូវចាត់ចូលជាប្រភេទជនដែលទទួលបានការការពារ ។ ឧទាហរណ៍ ជំពូក៤នៃសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចាត់ទុកសកម្មភាពមួយជាឧក្រិដ្ឋកម្មសង្គ្រាមនៅពេលសកម្មភាពទាំងនោះត្រូវបានប្រព្រឹត្តិឡើងប្រឆាំងនឹងបុគ្គលដែលមិនត្រូវបានការពារដោយសន្ធិសញ្ញាបីទៀត (សំដៅលើទាហានរងរបួស ទាហានគ្រោះថ្នាក់លិចកប៉ាល់ និងចំណាប់ខ្មាំង) ។ លើសពីនេះ បុគ្គលទាំងនោះត្រូវរកឃើញនៅពេលណាមួយ និងតាមរបៀបណាក៏ដោយថា ពួកគេស្ថិតក្នុងដៃភាគីជម្លោះ ឬក្រុមឈ្លានពានដែលមានសញ្ជាតិផ្សេង ។ ទោះជាយ៉ាងនេះក្ដី យុត្តិសាស្ត្រថ្មីមិនសូវផ្ដោតលើការបែងចែកសញ្ជាតិរវាងជនរងគ្រោះ និងជនល្មើសទេ ។

ផ្ទុយមកវិញ គេអាចផ្ដោតលើឋានៈ និងអត្តសញ្ញាណនៃជនល្មើសជាជាងជនរងគ្រោះដើម្បីបង្ហាញភាពខុសគ្នារវាងឧក្រិដ្ឋកម្មអន្តរជាតិ និងឧក្រិដ្ឋកម្មធម្មតា ។ សកម្មភាពរដ្ឋដែលបង្ហាញឡើងតាមរយៈគោលនយោបាយរបស់រដ្ឋាភិបាល ឬទង្វើរបស់អ្នកការពាររដ្ឋ ឬការប្រើអំណាចរបស់រដ្ឋមួយ ជារឿយៗត្រូវចាត់ទុកជាធាតុដ៏សំខាន់សម្រាប់កំណត់និយមន័យនៃឧក្រិដ្ឋកម្មអន្តរជាតិ ។

ចុងក្រោយ ភាពជាសាកលនៃឧក្រិដ្ឋកម្មអន្តរជាតិឆ្លុះបញ្ចាំងពីការពិចារណាសមហេតុផលមួយដែលថា ប្រភេទឧក្រិដ្ឋកម្មខ្លះពិសេសឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្រោមការបញ្ជារបស់រដ្ឋ មិនត្រូវបានដាក់ទណ្ឌកម្មគ្រប់គ្រាន់តាមរយៈប្រព័ន្ធច្បាប់ឧក្រិដ្ឋកម្មក្នុងប្រទេស បើដូច្នេះត្រូវតែដាក់ទណ្ឌកម្ម និងកាត់ទោសជាអន្តរជាតិ ។ ជាការពិតណាស់ ច្បាប់ប្រឆាំងឧក្រិដ្ឋកម្មអន្តរជាតិបានអភិវឌ្ឍន៍មួយផ្នែកប៉ុណ្ណោះ ដោយសាររដ្ឋជាច្រើនមិនស្ម័គ្រចិត្ត ឬមិនអាចកាត់ទោសបទល្មើសតាមច្បាប់អន្តរជាតិ ។

នៅទីបញ្ចប់ គេនៅមានចំណាប់អារម្មណ៍មួយដែលថា ឧក្រិដ្ឋកម្មអន្តរជាតិផ្សេងត្រូវបានបង្កើតឡើងសម្រាប់ហេតុផលផ្សេង ។ វិសមភាពនេះឆ្លុះបញ្ចាំងការណ៍ពិតដែលថា ច្បាប់ប្រឆាំងឧក្រិដ្ឋកម្មអន្តរជាតិតាមប្រវត្តិសាស្ត្របានវិវត្តពីភាពខុសគ្នាមកជាភាពស្រដៀងគ្នានៅសម័យក្រោយសង្គ្រាមលោកលើកទី២ ។ តាម-និយមន័យ វាជាធាតុផ្សំនៃឧក្រិដ្ឋកម្មអន្តរជាតិដែលធ្វើឲ្យឧក្រិដ្ឋកម្មអន្តរជាតិខុសប្លែកពីឧក្រិដ្ឋកម្មក្នុងប្រទេស ។ ដោយសារមានធាតុបន្ថែមទាំងនេះ ការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិតម្រូវឲ្យមានការបង្ហាញភស្តុតាងដែលមានធាតុច្រើនជាងធាតុដែលតម្រូវឲ្យមានសម្រាប់កាត់ទោសក្នុងប្រទេស ។ ជំនួសមកវិញ បញ្ហានេះត្រូវការចំណាយពេលយូរនិងភាពសាំញ៉ាំនៃសាលាក្ដីអន្តរជាតិថ្មី ។

**ប៉ែត ខាន់ស្អាក់**



អ្នកភូមិកំពុងអានសៀវភៅណែនាំអំពីសាលាក្ដីខ្មែរក្រហមនៅខេត្តក្រចេះ

# ភាពចាំបាច់សម្រាប់ស្ថាប័នការពារ ដើម្បីជំរុញឱ្យមាន ក្រមសីលធម៌មេធាវីក្រមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តក្រមសីលធម៌មេធាវីក្រមនៅអំឡុងពេលកិច្ចប្រជុំពេញអង្គនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ។ តុលាការនេះត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដែលតុលាការនេះប្រឈមមុខនឹងការរិះគន់យ៉ាងខ្លាំងចំពោះលទ្ធភាពធានាឲ្យមានភាពមិនលម្អៀងដំណើរការស្របច្បាប់ និងយុត្តិធម៌តាមបទដ្ឋានអន្តរជាតិ ។ នៅក្រោមកិច្ចព្រមព្រៀងនេះ តុលាការត្រូវបានបង្កើតឡើងដោយមិនមានការសាកល្បង ហើយពឹងផ្អែកទៅលើតុលាការខ្មែរដែលគ្មានបទពិសោធន៍និងធ្លាប់មានប្រវត្តិពុករលួយនិងការគ្រប់គ្រងនយោបាយមិនល្អ ។ ការអនុម័តតាមក្រមសីលធម៌មេធាវីក្រមបង្ហាញពី ជំហានវិជ្ជមានសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ហើយច្បាប់ដែលគ្មានការយល់ព្រមចាត់ទុកថាគ្មានប្រសិទ្ធភាព ។ ច្បាប់នេះត្រូវតែស្របតាមក្រុមប្រឹក្សាឯករាជ្យដែលបានបង្កើតឬក៏ក្រុមប្រឹក្សាផ្សេងទៀត ដូចជាអង្គវិន័យដែលមានការវិនិច្ឆ័យល្អមួយ រួមមានមេធាវីក្រមធ្វើការតាមច្បាប់និងវិន័យ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមាននិន្នាការទៅរកច្បាប់អន្តរជាតិ ។ តាំងពីឆ្នាំ១៩៩៣ មានតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដាបន្ទាប់មក តុលាការព្រហ្មទណ្ឌចម្រុះនិងអន្តរជាតិមួយចំនួនទៀតត្រូវបានបង្កើតឡើងដើម្បីដោះស្រាយអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិនៅប្រទេសទាំងពីរនេះ គ្រប់គ្រងដោយបុគ្គលិកនិងធនធានអន្តរជាតិ ហើយមានទំនាក់ទំនងខ្សោយជាមួយប្រជាជនក្នុងស្រុកដែលគេមានបំណងចង់បម្រើនេះធ្វើឲ្យមានការបកស្រាយអំពីតុលាការថាជា «ឧបករណ៍សម្រាប់ធ្វើអន្តរាគមន៍នយោបាយនៅភាគខាងលិច» ។ នេះជាកត្តាមួយដែលជំរុញឲ្យមានការបង្កើតតុលាការចម្រុះឬ «កូនកាត់» ដោយមានការចូលរួមពីអន្តរជាតិនិងប្រជាជនក្នុងស្រុក ។ តុលាការកូនកាត់រួមបញ្ចូលដោយច្បាប់ មេធាវីក្រម និង ព្រះរាជអាជ្ញាជាតិដែលជួយបង្កើនប្រព័ន្ធតុលាការជាតិនិងប្រព័ន្ធច្បាប់ក្នុងស្រុក ព្រមទាំងរួមបញ្ចូលទំនៀមទម្លាប់និងបុគ្គលិកអន្តរជាតិដែលធ្វើឲ្យមានភាពស្របច្បាប់ ធនធាន និងអ្នកជំនាញបច្ចេកទេស ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានភាពខុសប្លែកពីតុលាការកូនកាត់ពីមុន ព្រោះវាជាផ្នែកដាក់លាក់មួយរបស់តុលាការជាតិដែលធ្វើឲ្យវាងាយស្រួលនឹងទទួលបរាជ័យ ។ កម្ពុជាជាប្រទេសមួយត្រូវបានបំផ្លិចបំផ្លាញក្នុងរយៈពេលជាង៣០ឆ្នាំ ដោយសារសង្គ្រាមនិងចលាចលនយោបាយ នេះធ្វើឲ្យមានកង្វះខាតឯករាជ្យ ភាពមិនលម្អៀង និងសក្តានុពលសម្រាប់លុបបំបាត់អំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌ ។ តុលាការចម្រុះអន្តរជាតិដែលមានពីមុនបានដោះស្រាយភាពខ្សោយនៃមេធាវីក្រមក្នុងស្រុកដោយតម្រូវឲ្យមានមេធាវីក្រមអន្តរជាតិភាគច្រើន ។ ប៉ុន្តែរចនាសម្ព័ន្ធនេះត្រូវបានបដិសេធយ៉ាងដាច់ខាតដោយរដ្ឋាភិបាលកម្ពុជា ។

កិច្ចព្រមព្រៀងរវាងកម្ពុជានិងអង្គការសហប្រជាជាតិបានបង្កើតប្រព័ន្ធអង្គជំនុំជម្រះជាពីរថ្នាក់ដោយច្បាប់កម្ពុជា (ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) និងរួមបញ្ចូលប្រព័ន្ធតុលាការដែលមានស្រាប់ សវនាការកាត់ទោស និងសវនាការតុលាការកំពូលដែលដើរតួនាទីជាតុលាការឧទ្ធរណ៍ចុងក្រោយ ។ រដ្ឋាភិបាលកម្ពុជាបានទទូចថា មេធាវីក្រមភាគច្រើននៅក្នុងសវនាការទាំងពីរគឺមេធាវីក្រមកម្ពុជាត្រូវមានតួនាទីជាប្រធាន ។ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងវិធានផ្ទៃក្នុងរបស់តុលាការ

គម្រូវឲ្យសវនាការដំបូងដោះស្រាយជម្លោះដែលបានកើតឡើងរវាងសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតចំពោះការទទួលខុសត្រូវផ្សេងៗ ។ សវនាការកាត់ទោសដំបូងក៏មានចៅក្រមកម្ពុជាភាគច្រើននិងមានតួនាទីជាប្រធានដែរ ។

ចៅក្រមកម្ពុជាដែលកាន់កាប់សវនាការនេះត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាតុលាការកំពូល អង្គភាពរដ្ឋាភិបាលកម្ពុជាគោរពដោយប្រយោលនូវអន្តរាគមន៍នយោបាយក្នុងកម្រិតខ្ពស់បំផុត ។ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវថា ចៅក្រមត្រូវតែតែងតាំងពីក្នុងចំណោមចៅក្រមប្រតិបត្តិថ្មីៗឬតែងតាំងបន្ថែមនៅក្នុងការអនុវត្តតាមនីតិវិធីដែលមានស្រាប់សម្រាប់តែងតាំងចៅក្រម គ្រប់ចៅក្រមជាអ្នកដែលត្រូវមានក្រមសីលធម៌ខ្ពស់ ភាពមិនលម្អៀងនិងសុភនិច្ច័យ និងបទពិសោធន៍ ជាពិសេសច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិ... ចៅក្រមត្រូវតែមានឯករាជ្យនៅក្នុងការបំពេញមុខងាររបស់ខ្លួននិងមិនត្រូវទទួលឬស្វែងរកការណែនាំពីរដ្ឋាភិបាលឬប្រភពផ្សេងៗទៀត ។

ប៉ុន្តែ នៅក្នុងប្រទេសកម្ពុជា ការជ្រើសរើសនិងការតែងតាំងចៅក្រមមិនមានតម្លាភាព ហើយងាយនឹងរងការជ្រៀតជ្រែកខាងនយោបាយ ។ យោងទៅតាម ដាយណា ដូខេមភ្នើ ទីប្រឹក្សាទូទៅនៃអ្នកឃ្លាំមើលសិទ្ធិមនុស្សបានឲ្យដឹងថា «ចៅក្រមនិងព្រះរាជអាជ្ញាកម្ពុជាភាគច្រើនជាគឺជាបុគ្គលិករដ្ឋាភិបាល ដូច្នេះគេត្រូវតែមានភាពស្មោះត្រង់ ហើយរៀបចំដោយអ្នកប្រតិបត្តិការដើម្បីកុំឲ្យពាក់ព័ន្ធនឹងនយោបាយក៏ដូចជាម្ចាស់ជំនួយ» ។

របនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលពឹងផ្អែកយ៉ាងខ្លាំងលើសមាជិកនៃតុលាការកម្ពុជា គឺជាបញ្ហាសំខាន់ពីព្រោះប្រទេសកម្ពុជានៅខ្វះខាតចៅក្រមដែលមានសមត្ថភាពនិងបទពិសោធន៍ ។ នៅអំឡុងរបបខ្មែរក្រហម ប្រព័ន្ធច្បាប់របស់កម្ពុជាស្ថិតនៅក្រោមការវាយប្រហារនិងបំផ្លាញ ។ ដើម្បីបង្កើតសង្គមរួមគ្នាមួយដោយមិនមានឋានៈនិងភាពខុសគ្នា ខ្មែរក្រហមត្រូវបានបញ្ញវន្តដែលមានសមត្ថភាពនិងលទ្ធភាពគំរាមកំហែង ហើយព្យាយាមប្រឆាំងនឹងការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ដូច្នេះ បុគ្គលទាំងនេះត្រូវបានចាត់ទុកជាសត្រូវសំខាន់ ។ ចៅក្រម មេធាវី និង ព្រះរាជអាជ្ញាមួយចំនួនមានសំណាងព្រោះគេបានលាក់មុខតំណែងរបស់គេ ប៉ុន្តែអ្នកឯទៀតភាគច្រើនត្រូវបានសម្លាប់ជាប្រព័ន្ធ ។ មានការវាយតម្លៃខ្លះបានឲ្យដឹងថា មានមេធាវីតិចជាង ១០ នាក់មានជីវិតនៅរស់ក្នុងរបបខ្មែរក្រហម ជាលទ្ធផលធ្វើឲ្យខ្វះបុគ្គលិកដែលមានសមត្ថភាពនៅពេលបច្ចុប្បន្ន ។ ទិន្នន័យធនាគារពិភពលោកឆ្នាំ២០០៨ បានឲ្យដឹងថា មានតែមួយភាគប្រាំមួយនៃចៅក្រមកម្ពុជា១១៧រូប និងមួយភាគប្រាំបួននៃចៅក្រមតុលាការកំពូលមានជំនាញច្បាប់ ហើយចៅក្រមមួយចំនួនតូចមានបទពិសោធន៍អំពីច្បាប់អន្តរជាតិ ។

តុលាការដែលគ្មានបទពិសោធន៍និងសមត្ថភាពងាយនឹងប្រព្រឹត្តអំពើពុករលួយ ហើយអាចទទួលផលប៉ះពាល់ដោយហេតុផលផ្សេងៗ ។ ទីមួយជាមួយនឹងការកើនឡើងនៃបទពិសោធន៍និងសមត្ថភាព ធ្វើឲ្យមានការកើនឡើងអត្តសញ្ញាណនៃតួនាទីរបស់ស្ថាប័ននៅក្នុងតុលាការដែលជាកត្តាធ្វើឲ្យចៅក្រមមិនមានអំពើពុករលួយ ។ តុលាការដែលមានគុណភាពនឹងមានកិត្យានុភាពក្នុងសង្គមអាចទាក់ទាញបុគ្គលិកមានសមត្ថភាពនិងបង្កើនអំណាចតុលាការដែលធ្លាប់ប្រព្រឹត្តមិនត្រឹមត្រូវ ។ ចុងក្រោយចៅក្រមដែលមានគុណភាពទំនងជាជ្រើសរើសយកចៅក្រមដែលមានឋានៈដូចគ្នានិងអ្នកជំនាញផ្នែកច្បាប់ផ្សេងជាក្រុមសម្អាង ។ តាមរបៀបនេះការពិនិត្យមិនផ្ទាល់ទៅលើអំពើពុករលួយត្រូវបានត្រួតពិនិត្យដោយមជ្ឈដ្ឋានអ្នកជំនាញ ខណៈពេលដែលចៅក្រមតាំងចិត្តធ្វើការទៅតាមតួនាទីរបស់គាត់ ។ តុលាការដែលគ្មានបទពិសោធន៍របស់កម្ពុជាគឺងាយនឹងបង្កើតឲ្យមានអំពើពុករលួយនិងរងឥទ្ធិពលនយោបាយ ។

ជាការពិត ប្រធានប្រតិបត្តិរបស់កម្ពុជាធ្លាប់ប្រើឥទ្ធិពលទៅលើតុលាការជាតិដែលមានភាពទន់ខ្សោយ ។ ខ្មែរក្រហមបានធ្វើឲ្យស្ថាប័នច្បាប់បាក់បែក ហើយបំផ្លាញវប្បធម៌ដែលតម្រូវថាប្រព័ន្ធយុត្តិធម៌កម្ពុជាត្រូវតែបង្កើតឡើងវិញតាមលក្ខណៈដែលមិនមានពីមុននិងខ្វះខាតធនធានកម្រ ។ ស្ទើរតែគ្មានការហ្វឹកហ្វឺនឲ្យអនុវត្តច្បាប់ត្រឹមត្រូវ ហើយជម្លោះនៅតែមានបន្តរហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ ។ ក្រោយមក តុលាការត្រូវបានបង្កើតឡើងម្តងទៀតដោយរដ្ឋាភិបាលថ្មីដែលមានជំនួយពីវៀតណាម ហើយតុលាការនេះត្រូវបានបង្កើតនិងតាក់តែងជាឧបករណ៍នៃ

នយោបាយ ។ ការជ្រៀតជ្រែកតាមតំបន់នេះនៅតែមានបន្តរហូតដល់សព្វថ្ងៃ ។

គណបក្សប្រជាជនកម្ពុជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ចាប់ផ្តើមមានឥទ្ធិពលខាងរដ្ឋបាលនិងអំណាចនីតិបញ្ញត្តិចាប់តាំងពីវៀតណាមបណ្តេញខ្មែរក្រហមចេញពីអំណាចនៅក្នុងឆ្នាំ១៩៧៩ ។ ហ៊ុន សែន ខ្លួនឯងគឺជាអតីតជនកុម្មុយនីស្តខ្មែរក្រហមមួយរូបដែលចាប់ផ្តើមការងារក្នុងផ្នែកនយោបាយ និងជាមេបញ្ជាការខ្មែរក្រហមកម្រិតទាបគ្រប់គ្រងនៅក្នុងតំបន់បូព៌ា ។ នៅពេល ប៉ុល ពត ចាប់ផ្តើមកម្ទេចកម្មាភិបាលតំបន់បូព៌ា ក្នុងឆ្នាំ១៩៧៧ ហ៊ុន សែន បានភៀសខ្លួនចូលទៅក្នុងប្រទេសវៀតណាមដែលនៅទីនោះគាត់ដើរតួនាទីក្នុងចលនាតស៊ូប្រឆាំងនឹង ប៉ុល ពត ខ្មែរក្រហមវិញ ។

នៅពេលដែលវៀតណាមបណ្តេញ ប៉ុល ពត ចេញពីអំណាចនៅឆ្នាំ១៩៧៩ គេបានតែងតាំង ហ៊ុន សែន ដែលមានអាយុ២៧ឆ្នាំ ជារដ្ឋមន្ត្រីការបរទេសនៃរដ្ឋាភិបាលថ្មី ។ ចាប់តាំងពីពេលនោះមក គាត់ប្រើគ្រប់មធ្យោបាយដើម្បីក្លាយទៅជាអ្នកដឹកនាំរដ្ឋាភិបាលកុម្មុយនីស្ត បន្ទាប់មកក្នុងឆ្នាំ១៩៨៥ គាត់បានបង្កើតគណបក្សប្រជាជនកម្ពុជាដែលគ្រប់គ្រងរដ្ឋាភិបាលរហូតដល់សព្វថ្ងៃនេះ ។

គណបក្សប្រជាជនកម្ពុជាដែលដំបូងជាទាហានរត់ចោលខ្មែរក្រហម មានទំនាក់ទំនងជាច្រើនជាមួយអតីតខ្មែរក្រហម ។ នៅពេលសង្គ្រាមស៊ីវិលបន្តរហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ ហ៊ុន សែន ព្យាយាមបញ្ឈប់ខ្មែរក្រហម ដែលជាការគំរាមខាងយោធា ដោយបញ្ចុះបញ្ចូលឲ្យមេដឹកនាំជាច្រើនឈប់តស៊ូ ហើយចុះចូលជាមួយរដ្ឋាភិបាល ។ មេដឹកនាំខ្មែរក្រហមយល់ព្រមចុះចូលដោយនាំទាហានកុម្មុយនីស្តរាប់រយនាក់មកជាមួយផង ។ «ក្នុងការកែប្រែអង្គភាពយោធាខ្មែរក្រហម វាងាយស្រួលហាក់ដូចជាផ្លាស់ប្តូរឯកសណ្ឋាន ដំបូងគេគឺជាឈ្លបខ្មែរក្រហមនៅក្នុងសម្លៀកបំពាក់ខ្មៅ បន្ទាប់មកគេប្រែទៅជាទាហានរបស់រដ្ឋាភិបាលក្នុងឯកសណ្ឋានពណ៌បៃតង» ។ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានអំណាចកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ព្រមទាំងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនេះប៉ុណ្ណោះ ។ ទំនងជាមិនមានការគំរាមកំហែងដល់អតីតមេដឹកនាំខ្មែរក្រហមដែលសព្វថ្ងៃនេះកំពុងតែធ្វើការនៅក្នុងរដ្ឋាភិបាលនិងយោធាផងទេ ។ ទោះជាយ៉ាងណាក៏ដោយ នៅតែមានព័ត៌មានជាច្រើនអំពីការគ្រប់គ្រងរបស់ខ្មែរក្រហមដែលជាអតីតមេដឹកនាំនេះ ។

ប្រជាជនកម្ពុជាដែលធ្លាប់មានបទពិសោធន៍ដូចគ្នានឹងទាមទាររកយុត្តិធម៌ ។ ដោយខ្មែរក្រហមធ្វើឲ្យប្រជាជនកម្ពុជាទទួលរងសោកនាកម្ម ហើយចៅក្រមកម្ពុជាផ្ទាល់ទំនងជាមានបទពិសោធន៍នៅក្នុងរបបខ្មែរក្រហមនិងឧក្រិដ្ឋកម្មនេះដែរ ។ នេះធ្វើឲ្យចៅក្រមកម្ពុជាមានទស្សនៈផ្សេងពីចៅក្រមអន្តរជាតិ ។ ជាច្រើនឆ្នាំមកនេះប្រជាជនកម្ពុជាដឹងថា ឧក្រិដ្ឋកម្មដែលកើតមាននៅអំឡុងកម្ពុជាប្រជាធិបតេយ្យបង្កឲ្យមានអំពើប្រល័យពូជសាសន៍ ដែលរបប ប៉ុល ពត គឺជាអ្នកទទួលខុសត្រូវ ។ ជាលទ្ធផល ការគិតទុកជាមុនពីបទឧក្រិដ្ឋដែលនឹងត្រូវចោទប្រកាន់មេដឹកនាំខ្មែរក្រហម គឺជាការព្រួយបារម្ភដ៏ធំមួយ ។ ដោយសារតែចៅក្រមក្នុងស្រុកមានបទពិសោធន៍ដូចគ្នានេះ មិនមានន័យថាគេមិនមានយុត្តិធម៌និងមិនមានអ្នកការពារក្តីឲ្យចុងចោទទេ ។ តែនេះអាចជាលទ្ធភាពមួយដែលត្រូវតែយកមកពិចារណានិងការពារ ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ប្រឈមមុខនឹងសម្ពាធពីប្រជាជនយ៉ាងខ្លាំងក្នុងការផ្តន្ទាទោសចុងចោទ ។ ចៅក្រមត្រូវតែមិនទទួលសម្ពាធនយោបាយនិងប្រជាជន ហើយមិនត្រូវប្រើអារម្មណ៍ ព្រមទាំងគោរពតាមការសន្មតភាពគ្មានទោសនិងនីតិក្រមយុត្តិធម៌ ។ ដើម្បីធ្វើដូច្នេះ គឺតម្រូវឲ្យចៅក្រមត្រូវតែមានបទដ្ឋានខ្ពស់ ។ កិច្ចព្រមព្រៀងអង្គការសហប្រជាជាតិ វិធានអង្គជំនុំជម្រះ និងប្រព័ន្ធច្បាប់ដែលមានការយល់ស្របគ្នាថ្មីៗនេះធ្វើឲ្យមានឯករាជ្យ យុត្តិធម៌ ភាពមិនលម្អៀង សុចរិត និងបទពិសោធន៍ ។ ប៉ុន្តែគ្មានអង្គភាពណាផ្តល់យន្តកម្មដើម្បីធានាឲ្យមានបទដ្ឋានបែបនេះទេ ។

រដ្ឋធម្មនុញ្ញរបស់កម្ពុជាបានបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការដោយធ្វើការជ្រើសរើសនិងផ្លាស់ប្តូរចៅក្រម ព្រមទាំងជំរុញឲ្យមានការគោរពវិន័យនៃយុត្តិធម៌ ។ ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យឯករាជ្យភាពនៅក្នុងតុលាការ ។

យ៉ាងណាមិញ ប្រធានប្រតិបត្តិដែលជាគណបក្សប្រជាជនកម្ពុជា នៅតែមានអំណាចច្រើនដើម្បីគ្រប់គ្រងក្រុមប្រឹក្សា ។ ជាងនេះទៅទៀត នៅខែឧសភា ឆ្នាំ២០០៥ នាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើឲ្យក្រុមប្រឹក្សាបាត់បង់អំណាចដោយបំបែកអគ្គលេខាធិការដ្ឋាន និងប្រគល់អំណាចទៅឲ្យក្រសួងយុត្តិធម៌ដែលដឹកនាំដោយសមាជិកបក្សរបស់គាត់ ។ ក្រុមប្រឹក្សាស្ទើរតែមិនមានតួនាទីអ្វីនៅក្នុងការត្រួតពិនិត្យឬកែប្រែរចនាសម្ព័ន្ធតុលាការ ដែលក្រុមប្រឹក្សាជាន់ខ្ពស់ជាក់ស្តែងមានមុខតំណែងជា «អង្គភាពរបស់គណបក្សប្រជាជន» ។

ការយល់ស្របដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះក្រមសីលធម៌ចៅក្រម ដែលរួមមានឯករាជ្យភាពជាសកល យុត្តិធម៌ សុចរិត ភាពសមរម្យ សមត្ថភាព និង ការយកចិត្តទុកដាក់ក្នុងការងារ គឺជាកត្តាសំខាន់ចម្បងដើម្បីធានាឲ្យមានបទដ្ឋានយុត្តិធម៌ ។ វត្តមាននៃវិធានដាក់លាក់ក្នុងការដឹកនាំមិនបានធានាថាវានឹងត្រូវយកមកអនុវត្តតាមនោះទេ ។ ដោយសារតែប្រព័ន្ធច្បាប់មិនបានបង្កើតយន្តកម្មបង្គាប់ឲ្យគោរពច្បាប់ដោយឯករាជ្យ នាំឲ្យច្បាប់នេះមិនមានប្រសិទ្ធភាពក្នុងការលុបបំបាត់ភាពខ្វះខាតខាងឯករាជ្យនិងអំពើពុករលួយនៅក្នុងតុលាការកម្ពុជា ។

ដោយសារតែប្រជាជនកម្ពុជាប្រកាន់តាមគណៈវិនិច្ឆ័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាភាគច្រើន ដូច្នេះរដ្ឋាភិបាលកម្ពុជាងាយនឹងត្រួតពិនិត្យសវនាការអង្គជំនុំជម្រះ ។ ទស្សនៈដែលថាគ្រាន់តែផ្លាស់ប្តូរចៅក្រមកម្ពុជានៅអគារដដែលដោយអ្នករួមការងារអន្តរជាតិ ប្រហែលជាអាចបិទមិនឲ្យមានឥទ្ធិពលពីខាងក្រៅនិងធានាឲ្យមានសកម្មភាពឯករាជ្យគឺជាទស្សនៈដែលមិនអាចធ្វើទៅរួច ។ ស្រដៀងគ្នានេះដែរ ដោយគ្រាន់តែអះអាងថា ចៅក្រមមានឯករាជ្យមិនអាចបញ្ជាក់ថា ការពិតវាមានឯករាជ្យនោះទេ ។ អ្វីដែលចាំបាច់គឺការការពាររដ្ឋធម្មនុញ្ញនៅក្នុងទម្រង់ជាក្រុមប្រឹក្សាថ្មី ដោយរួមបញ្ចូលចៅក្រមនិងប្រតិបត្តិតាមក្រមសីលធម៌ថ្មីរបស់ចៅក្រមដែលទើបតែមាន ។

ក្រុមប្រឹក្សាបែបនេះ គួរតែត្រូវបានត្រួតពិនិត្យដោយតុលាការដើម្បីទប់ស្កាត់ឥទ្ធិពលមិនសមស្របរបស់ផ្នែកប្រតិបត្តិនិងផ្នែកច្បាប់ ។ ការស៊ើបអង្កេតរបស់ចៅក្រមឬការគំរាមកំហែងមិនមែនជាឧបករណ៍ចាំបាច់ដែលប្រើប្រាស់ដោយផ្នែកផ្សេងទៀតរបស់រដ្ឋាភិបាលដើម្បីជាការសងសឹកចំពោះការសម្រេចចិត្តដែលមិនមានប្រជាប្រិយភាពឬដាក់សម្ពាធទៅលើចៅក្រមទេ ។ ការប្រតិបត្តិដ៏មានប្រសិទ្ធភាពគួរតែរួមបញ្ចូលអំណាចដើម្បីគ្រប់គ្រងសមាជិកតុលាការទាំងផ្នែកឧក្រិដ្ឋកម្មនិងមិនមែនឧក្រិដ្ឋកម្ម ដូចជាក្នុងករណីពាក់ព័ន្ធនឹងការស៊ីសំណូក ។ ការត្រួតពិនិត្យត្រូវតែរៀបចំឡើងដើម្បីការពារកុំឲ្យមានការប្រតិបត្តិមិនត្រឹមត្រូវ ហើយធ្វើការស៊ើបអង្កេតដោយភាពយុត្តិធម៌និងមិនប៉ះពាល់ដល់ភាពឯករាជ្យរបស់តុលាការ ។ ការការពារឯករាជ្យភាពរបស់យុត្តិធម៌និងតម្រូវការដើម្បីផ្តល់ការទទួលខុសត្រូវរបស់ចៅក្រមចំពោះសកម្មភាពខ្លួនត្រូវតែមានតុល្យភាព ។ ដំណើរការត្រូវតែមានតម្លាភាពដើម្បីបង្ហាញឲ្យមានភាពជឿជាក់លើខ្លួនឯងជាសាធារណៈ ។

បន្ទាប់ពីប្រជាជនទាំងអស់ទទួលរងការឈឺចាប់ គេបានទន្ទឹងរង់ចាំយុត្តិធម៌និងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបខ្មែរក្រហមអស់ជាងបីទសវត្សរ៍ ។ អង្គជំនុំជម្រះដែលលេចរូបរាងបន្ទាប់ពីកិច្ចចរចាជាច្រើនឆ្នាំ ប៉ុន្តែឥឡូវនេះបែរជាមានអំពើពុករលួយ ព្រមទាំងមានការឆ្លៀតឱកាសពីនយោបាយនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាទាំងមូល ។ យ៉ាងណាមិញ ដូចដែលបានកត់សម្គាល់ដោយបញ្ញវន្តកម្ពុជា លោក ស៊ីវ ហេង ័រ បានឲ្យដឹងថា ច្បាប់និងកិច្ចព្រមព្រៀងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនខុសអ្វីទេ «យ៉ាងហោចណាស់នៅក្នុងរបាយការណ៍ក៏មាននិយាយអំពីសិទ្ធិរបស់បុគ្គលដែរ ។ អ្វីដែលជាបញ្ហាធ្ងន់ធ្ងរ គឺជាលទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការធានាឲ្យមានការអនុវត្តច្បាប់នេះដោយមន្ត្រីកម្ពុជាដែលមានឯករាជ្យនិងយុត្តិធម៌ ។ ខ្ញុំពេញចិត្តចំពោះការយល់ស្របនឹងក្រមសីលធម៌ចៅក្រម ប៉ុន្តែការពេញចិត្តនេះនឹងមានការធ្លាក់ចុះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែដោះស្រាយបញ្ហាឯករាជ្យភាព យុត្តិធម៌និងសមត្ថភាពរបស់តុលាការដោយមានរបាយការណ៍តែមួយ ព្រមទាំងបង្កើតឲ្យមានក្រុមប្រឹក្សាយុត្តិធម៌ដោយមានវិន័យនិងការត្រួតពិនិត្យដ៏មានប្រសិទ្ធភាព ព្រោះថាការគ្រប់គ្រងនយោបាយផ្សេងៗដែលមានឯករាជ្យធ្លាប់ធ្វើឲ្យគ្មានភាពយុត្តិធម៌នៅប្រទេសកម្ពុជាយូរណាស់មកហើយ ។

**រ៉ាក់ហ្វេត ហឺន**

00189686

C20/I/22

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ:00២/១៩-0៩-២00៧-អវតក-កសចស(អបជ0២)

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 21 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

## **របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង**

I) **នីតិវិធី**

II) **ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍**

ORIGINAL DOCUMENT
RECEIVED ON 21-05-2008
AT 09 h 10 BY
CHEA Kosal, court officer

I) **នីតិវិធី**

**ក) សេចក្តីផ្តើម**

អនុលោមតាមវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") ប្រធានអង្គបុរេជំនុំជម្រះបានចាត់តាំងលោកចៅក្រម **ហួត វុទ្ធី** និង លោកចៅក្រម Rowan Downing ឱ្យធ្វើរបាយការណ៍បង្ហាញពីអង្គហេតុ និង អង្គច្បាប់ នៅក្នុងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាឃុំខ្លួនដែលត្រូវបានប្តឹងឧទ្ធរណ៍ និងធ្វើការត្រួតពិនិត្យលើសំណុំរឿង លេខ:00២/១៩-0៩-២00៧-អវតក-កសចស(អបជ0២) ។

**ដែលក្នុងនោះជនត្រូវចោទ:-**

**អៀង ធីរិទ្ធ** ហៅ " **ភា** " ភេទស្រី កើតថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់លេខ ៥ ក្រុងភ្នំពេញ ប្រទេសកម្ពុជា សញ្ជាតិ ខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន នៅផ្ទះលេខ ៤៧បេ ផ្លូវលេខ២១ ក្រុម៣៦ មណ្ឌល៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ **ខៀវ អុន** (ស្លាប់) ម្តាយឈ្មោះ **អ៊ុក ប៊ុន** (ស្លាប់) ។ តំណាងដោយសហមេធាវីការពារក្តី លោក **ផាត់ ពៅស៊ាង** និង កញ្ញា Diana ELLIS ។

**ជនចោទប្រកាន់**

**អៀង ធីរិទ្ធ** ត្រូវបានចោទប្រកាន់ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ( មនុស្ស[illegible] ការ[illegible] បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និង អំពើអមនុស្សធម៌ផ្សេងៗទៀត ) ដែលជា[illegible]មានចែង

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C

00189687

C20/I/22

និង ផ្តន្ទាទោស តាមមាត្រា ៥, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (ច្បាប់ អ.វ.ត.ក)

ដោយជននេះ នៅលើទឹកដីនៃប្រទេសកម្ពុជា ចន្លោះថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី ០៦ ខែមករា ឆ្នាំ១៩៧៩:

- ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច បានប្រើប្រាស់អំណាច និង គ្រប់គ្រងជាក់ស្តែងលើក្រសួងនេះ និងស្ថាប័នក្រោមចំណុះក្រសួងទាំងអស់
- បានញុះញង់ បញ្ជា ខកខានមិនបានទប់ស្កាត់ និងផ្តន្ទាទោស ឬម្យ៉ាងទៀត បានសមគំនិតក្នុងការប្រព្រឹត្តិនូវបទល្មើសខាងលើ
- បានដឹកនាំ ជំរុញ ដាក់ឱ្យដំណើរការ ឬ ផ្តល់ជំនួយក្រោមរូបភាពផ្សេងទៀត ដល់គោលនយោបាយ និងការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលចារឹកលក្ខណៈជា មនុស្សឃាត ការសម្លាប់បំផុតពូជ ការចាប់ដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ឬអំពើអមនុស្សធម៌ដទៃទៀតដូចជា ការជម្លៀសដោយបង្ខំ ការដាក់ជាទាសករ ឬ ការធ្វើការដោយបង្ខំ
- នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាប្រព័ន្ធ និងជាទូទៅ សំដៅលើប្រជាជនស៊ីវិល[1] ។

**គោលបំណងនៃរបាយការណ៍**

របាយការណ៍របស់សហចៅក្រមរបាយការណ៍នេះ បង្ហាញពីអង្គហេតុ និង អង្គច្បាប់នៅក្នុងសេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍ និងអង្គហេតុដែលពាក់ព័ន្ធផ្សេងៗទៀត នៅចំពោះមុខតុលាការ ។ របាយការណ៍នេះ ផ្តល់ជាជំនួយដល់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីឱ្យយល់អំពីរឿងក្តីនេះ នៅចំពោះមុខតុលាការ ។

**១) ការស្នើសុំរបស់សហព្រះរាជអាជ្ញាឱ្យធ្វើការឃុំខ្លួនបណ្តោះអាសន្ន**

នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា នៃ អ.វ.ត.ក បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលក្នុងនោះស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបអង្កេតលើជនសង្ស័យមួយចំនួន រួមមានទាំង **អៀង ធីរិទ្ធ** ផងដែរ ហើយបានស្នើសុំឱ្យធ្វើការចាប់ខ្លួន និងឃុំខ្លួនជនសង្ស័យទាំងនោះ[2]។

សហព្រះរាជអាជ្ញាបានស្នើឱ្យមានការឃុំខ្លួន **អៀង ធីរិទ្ធ** ជាបណ្តោះអាសន្ន ដោយផ្អែកលើសំអាងថា មានមូលហេតុគ្រប់គ្រាន់ដោយជឿជាក់ថា **អៀង ធីរិទ្ធ** បានចូលរួមប្រព្រឹត្តិបទល្មើសដូចដែលបានរៀបរាប់ខាងលើ ហើយការឃុំខ្លួននេះទៀតសោត ជាការចាំបាច់ដើម្បីរារាំងការគាបសង្កត់លើសាក្សី ដើម្បី[illegible]

[1] កំណត់ហេតុនៃការចូលខ្លួនដំបូង, ១២ វិច្ឆិកា ២០០៧, D42 ទំព័រ ២

[2] សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ១៨ កក្កដា ២០០៧, កថាខណ្ឌ ១២៤

00189688

C22/I/22

**អៀង ធីរិទ្ធ** ក្នុងពេលសវនាការ ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់ និងដើម្បីធានានូវសណ្តាប់ ធ្នាប់សាធារណៈ[3]។

**គ). ដីកាឃុំខ្លួនចេញដោយសហចៅក្រមស៊ើបអង្កេត**

នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត អ.វ.ត.ក បានចេញដីកានាំខ្លួនជនត្រូវចោទ **អៀង ធីរិទ្ធ** មកចំពោះមុខតុលាការ[4]។ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០០៧ **អៀង ធីរិទ្ធ** ត្រូវបានចាប់ខ្លួន និងនាំខ្លួនមកចំពោះមុខសហចៅក្រមស៊ើបអង្កេត ដើម្បីបង្ហាញខ្លួនជាលើកដំបូង[5]។ **អៀង ធីរិទ្ធ** បានស្នើសុំពន្យារពេលសវនាការតទល់គ្នាលើការឃុំខ្លួនបណ្តោះអាសន្នដើម្បីរៀបចំការពារខ្លួន។ សហចៅក្រមស៊ើបអង្កេតបានទទួលយកការស្នើសុំពន្យារពេលនេះ ហើយបានបង្គាប់ឱ្យឃាត់ខ្លួនជននេះក្នុងចិរៈវេលា៤៨ម៉ោង[6]។ តាមការស្នើសុំរបស់សហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ **អៀង ធីរិទ្ធ** ត្រូវបានត្រួតពិនិត្យដោយវេជ្ជបណ្ឌិតនាពេលដែលគាត់ស្ថិតនៅក្រោមការឃាត់ខ្លួន[7]។ នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៧ សវនាការតទល់គ្នាត្រូវបានធ្វើឡើងបន្ត[8] ហើយសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលមានរយៈពេលកំណត់មិនលើសពី ១ឆ្នាំ[9]។

**មូលហេតុចំពោះការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត**

**អង្គហេតុ និងអង្គច្បាប់ដែលបានលើកឡើងក្នុងសេចក្តីសម្រេច**

សហព្រះរាជអាជ្ញាបានស្នើឱ្យឃុំខ្លួនជនត្រូវចោទ **អៀង ធីរិទ្ធ** បណ្តោះអាសន្ន ដោយសំអាងលើមូលហេតុដូចខាងក្រោម:

> (...) ដោយសារជនត្រូវចោទមានលិខិតឆ្លងដែន ជននេះអាចរត់គេចខ្លួនទៅក្រៅប្រទេសបានយ៉ាងងាយស្រួល ប្រសិនបើត្រូវដោះលែងឱ្យមានសេរីភាព និងទំនងជាមានហានិភ័យកាន់តែខ្លាំងថែមទៀត ព្រោះជននេះប្រឈមនឹងការជាប់ឃុំឃាំងមួយជីវិតប្រសិនបើត្រូវបានផ្តន្ទាទោស។ម្យ៉ាងវិញទៀតប្រសិនបើគ្មានការឃុំខ្លួន ជនរងគ្រោះអាចធ្វើការសងសឹក ហេតុដូច្នេះហើយ ការឃុំខ្លួនបណ្តោះអាសន្នគឺជាការចាំបាច់

---

[3] សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ១១៨

[4] ដីកាបង្គាប់ឱ្យនាំខ្លួន, ៨ វិច្ឆិកា ២០០៧, C13

[5] កំណត់ហេតុនាំខ្លួន អៀង សារី និង អៀង ធីរិទ្ធ មកការិយាល័យនៅម្តុំនៅទីក្រុងភ្នំពេញ, ១៣ វិច្ឆិកា ២០០៧, D31/III និង កំណត់ហេតុនៃការចូលខ្លួនដំបូង, ១២ វិច្ឆិកា ២០០៧, D39

[6] សេចក្តីសម្រេចឃាត់ខ្លួន ១២ វិច្ឆិកា ២០០៧, C15

[7] ដីកាសម្រេចឱ្យនាំខ្លួនជនត្រូវចោទទៅពិនិត្យសុខភាព ១៣ វិច្ឆិកា ២០០៧, A58, របាយការណ៍ស្តីពីការឃាត់ខ្លួន ១៥ វិច្ឆិកា ២០០៧, C15/...

[8] កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ១៤ វិច្ឆិកា ២០០៧, C20

[9] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ១៤ វិច្ឆិកា ២០០៧, C20

00189689

C20/I/22

ដើម្បីទប់ស្កាត់កុំឲ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង ដើម្បីធានាសន្តិសុខឱ្យជនត្រូវចោទ និង ចំនុចចុងក្រោយ គឺទំនងដែលថា មានហានិភ័យដែលអាចមានការដាក់សម្ពាធលើលើសាក្សី[10]។

នាពេលបង្ហាញខ្លួនលើកដំបូង និង សវនាការតទល់គ្នា **អៀង ធីរិទ្ធ** បានបដិសេធចំពោះការពាក់ព័ន្ធនឹងបទល្មើសដែលបានដាក់បន្ទុកមកលើខ្លួន ហើយទាមទារឲ្យតុលាការបង្ហាញភស្តុតាងអំពីពិរុទ្ធភាពរបស់ខ្លួន ដោយគូសបញ្ជាក់ថា នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់គាត់នៅក្រសួងសង្គមកិច្ច និងក្នុងវិស័យសុខាភិបាល គាត់បានត្រឹមតែជួយប្រជាជន និងអ្នកជម្ងឺ ដូចជាទទួលបន្ទុកស្តារឡើងវិញនូវមន្ទីរពេទ្យដែលត្រូវបានខូចខាត និងផលិតថ្នាំពេទ្យជាដើម[11]។ សហមេធាវីជាតិរបស់ **អៀង ធីរិទ្ធ** ក៏បានតវ៉ាផងដែរថា ការឃុំខ្លួនបណ្តោះអាសន្ននេះពុំមានលក្ខណៈចាំបាច់ទេ[12] ហើយការឃុំខ្លួននេះអាចនាំទៅរកភាពស្មុគស្មាញ ដោយសារជនត្រូវចោទមានអាយុ ៧៥ ឆ្នាំ និងមានជម្ងឺរ៉ាំរ៉ៃខាងផ្លូវកាយ និង ផ្លូវចិត្តទៀត[13]។

ដូច្នេះហើយ បញ្ហាដែលនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតគឺថា (i) អនុលោមតាមវិធាន ៦៣(៣)(ក) តើមានមូលហេតុច្បាស់លាស់ដែលនាំឲ្យជឿជាក់ថា **អៀង ធីរិទ្ធ** បានប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់ ឬ យ៉ាងណា និង (ii) ថាតើការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់ ដោយគោរពតាមល័ក្ខខ័ណ្ឌដូចដែលមានចែងក្នុងវិធាននៃក្នុងវិធាន៦៣(៣)(ខ) ឬទេ ។

**សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត**

សហចៅក្រមស៊ើបអង្កេតផ្តល់ហេតុផលដូចខាងក្រោម:

> "តាមរយៈឯកសារ និងចម្លើយសាក្សីជាច្រើនដែលមានក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលដាក់បន្ទុកលើ **អៀង ធីរិទ្ធ** បង្កើតបានជាហេតុផលដែលអាចជឿជាក់បានថា **អៀង ធីរិទ្ធ** បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុកមែន[14]។"

ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតរកឃើញថា ល័ក្ខខ័ណ្ឌនៃវិធាន ៦៣(៣)(ក) ត្រូវបានបំពេញ ។

សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់ យោងតាមល័ក្ខខ័ណ្ឌក្នុងវិធាន ៦៣(៣)(ខ) (i), (iii), (iv) និង (v) ។ សហចៅក្រមស៊ើបអង្កេត ពីដំបូង យល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទ:

---

[10] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៣

[11] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៤

[12] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៤

[13] កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ១៤ វិច្ឆិកា ២០០៧, ទំព័រ៣

[14] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៥

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia 4 of 16
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

00189690

C20/I/22

"អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ទោះជាវាមានរយៈពេល ៣០ឆ្នាំ ក្រោយពេលឧក្រិដ្ឋកម្មបានកើតឡើងក៏ដោយ ក៏នៅតែបង្កបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈដដែល។ ហេតុដូច្នេះ វាមិនមែនជាការហួសហេតុ ពេកដែលអះអាងថា នៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឲ្យ មានការសំដែងនូវការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហឹង្សា ឬអាចប៉ះពាល់ដល់សន្តិសុខរបស់ជនត្រូវចោទ ផ្ទាល់។ម្យ៉ាងវិញទៀត ស្ថានភាពមិនអាចមើលឃើញជាក់លាក់ដូចគ្នាទេ រវាងពេលមុនការចោទប្រកាន់ និង ក្រោយពេលចោទប្រកាន់ជាផ្លូវការនោះ[15]។"

សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់បន្ថែមទៀតថា ប្រសិនបើ **អៀង ធីរិទ្ធ** ត្រូវបានដោះលែងឲ្យមានសេរីភាព វាអាចនាំឲ្យមានការព្រួយបារម្ភដែលថា ជននេះអាចនឹងធ្វើការដាក់សម្ពាធលើសាក្សី ដោយសារថាគាត់មានសិទ្ធិពិនិត្យមើលសំណុំរឿងទាំងមូលបាន ហើយជនត្រូវចោទមានសមាជិកគ្រួសារ និងអ្នកដែលគាំទ្រច្រើនដែលអ្នកទាំងនោះមួយចំនួន កាន់មុខតំណែងដ៏មានឥទ្ធិពល នាពេលបច្ចុប្បន្ន[16]។ សហចៅក្រមស៊ើបអង្កេតបានបន្ថែមទៀតថា ជនត្រូវចោទអាចមានចេតនារត់គេចដោយសារមានមធ្យោបាយគ្រប់គ្រាន់ និងមូលហេតុនៃការប្រឈមមុខនឹងទោសឧក្រិដ្ឋជាប់ឃុំឃាំងមួយជីវិត[17]។

ចុងក្រោយ សហចៅក្រមស៊ើបអង្កេតលើកឡើងថា មិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹងគ្រប់គ្រាន់ ធ្វើឱ្យការឃុំខ្លួនបណ្តោះអាសន្នមិនមានលក្ខណៈចាំបាច់ អនុលោមតាមវិធាន ៦៣(៣)[18] ហើយពុំមានឯកសារណាមួយដែលបង្ហាញដោយមេធាវី នាំឲ្យយើងជឿជាក់ថា ស្ថានភាពសុខភាពជនត្រូវចោទមានវិសមតិភាពជាមួយនឹងការឃុំខ្លួនឡើយ[19]។

## ឃ) បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីរបស់ **អៀង ធីរិទ្ធ** បានធ្វើការប្រកាសប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ហើយ នៅថ្ងៃ ទី០២ ខែមករា ឆ្នាំ២០០៨ បានដាក់សារណាគាំទ្របណ្តឹងឧទ្ធរណ៍ចូលមកអង្គបុរេជំនុំជម្រះ ។

សហមេធាវីស្នើសុំឲ្យមានការដោះលែងជនត្រូវចោទ **អៀង ធីរិទ្ធ** ក្រោមល័ក្ខខ័ណ្ឌទាំងឡាយណាដែលអង្គបុរេជំនុំជម្រះ យល់ឃើញថាសមស្រប ហើយតវ៉ាថាល័ក្ខខ័ណ្ឌសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន ដូចដែលមានចែងក្នុងវិធាន ៦៣(៣) មិនត្រូវបានបំពេញ ។

---

[15] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៦
[16] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៧
[17] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៨
[18] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ៩
[19] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ ១០

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00189691

C20/I/22

## ខ) សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា

សេចក្តីសន្និដ្ឋានតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍ ត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញា និងដាក់ជូនមកអង្គបុរេជំនុំជម្រះនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨។

សហព្រះរាជអាជ្ញាលើកឡើងថា បណ្តឹងឧទ្ធរណ៍នេះគួរបដិសេធចោល ហើយការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតមានភាពត្រឹមត្រូវ ដោយសារមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នតាមវិធាន៦៣ (៣) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ និង នៅតែមានដដែល ហើយពុំមានការរំលោភបំពានលើការសន្មតជាមុននៃភាពគ្មានទោសនោះឡើយ[20]។

## គ) សេចក្តីសន្និដ្ឋានតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី

នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចមួយ ដោយអនុញ្ញាតអោយភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងករណី **នួន ជា**។ ដូច្នេះ នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់សេចក្តី សន្និដ្ឋានតបទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ក្នុងរយៈពេល១៥ថ្ងៃ ដែលរយៈពេលនេះ ត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៨។ នៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៨ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ជូនមកនូវសេចក្តីសន្និដ្ឋានតបរួមគ្នាមួយ តបទៅនឹងបណ្តឹងរបស់ **អៀង ធីរិទ្ធ** ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[21]។ ក្នុងសេចក្តីសន្និដ្ឋាននេះ សហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យបដិសេធបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី ហើយគាំទ្រជំហររបស់សហព្រះរាជអាជ្ញា ។

## ឃ) ការអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តីឲ្យដាក់សារណា

ដើម្បីជាជំនួយដល់តុលាការ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានអញ្ជើញអង្គការ និងសាធារណជនទាំងអស់ ឲ្យដាក់សារណាជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងរឿងក្តីខាងលើ ក្នុងរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។ ក៏ប៉ុន្តែពុំមានសារណារបស់អង្គការ ឬ សាធារណជនត្រូវបានដាក់ជូនមកអង្គបុរេជំនុំជម្រះឡើយ ក្នុងរឿងក្តីរបស់ **អៀង ធីរិទ្ធ** មួយនេះ។

---

[20] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ១៤ វិច្ឆិកា ២០០៧, (ចម្លើយតបរបស់សហព្រះរាជអាជ្ញា) កថាខណ្ឌ១

[21] ចម្លើយតបរួមគ្នារបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៨, ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន C20/I/17(ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី)

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Web: www.eccc.gov.kh

00189692

C20/I/22

II. **ការពិនិត្យសំណុំរឿងដោយចៅក្រមឧបការណ៍**

**អៀង ធីរិទ្ធ** ប្រសិនត្រូវបានគេរកឃើញពិរុទ្ធភាពនៃបទល្មើសដែលខ្លួនកំពុងជាប់ឃុំនាពេលបច្ចុប្បន្ន និង កំពុងដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ត្រូវផ្តន្ទាទោសតាម មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "ដោយត្រូវផ្តន្ទាទោសឧក្រិដ្ឋដាក់ពន្ធនាគារ ពី ៥ ឆ្នាំ រហូតអស់មួយជីវិត" ។

ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នក្នុងរឿងក្តីនេះ បានអនុវត្តតាមវិធាន៦៣ នៃវិធានផ្ទៃក្នុង ។ វិធាន ៦៣(៣) ចែងអំពីមូលហេតុ ដែលសហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ហើយ វិធាន៦៣(៤) ចែងអំពីសិទ្ធិប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីកាបែបនេះ ។

**វិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង**

សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ដោយគោរពតាមល័ក្ខខ័ណ្ឌ ដូចខាងក្រោម :

ក) មានមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់ច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់ដើម្បី:

(១) រារាំងកុំឱ្យជននោះគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និង អ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង និងការពារមិនឱ្យបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅពេលដំណើរការនីតិវិធី ។

(៤) ការការពារសុវត្ថិភាពជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

សហមេធាវីលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនគោរពការសន្មតជាមុននៃភាពគ្មានទោស នៅពេលខ្លួនបានរកឃើញមូលហេតុគួរឱ្យជឿជាក់ថា **អៀង ធីរិទ្ធិ** បានប្រព្រឹត្តិបទល្មើស ដែលដាក់បន្ទុកមកលើខ្លួន។ សហមេធាវីបានលើកឡើងទៀតផងដែរថា ការដោះលែងបណ្តោះអាសន្នដែលកំពុងរង់ចាំការជំនុំជម្រះ គឺជាវិធាននៃច្បាប់ អនុលោមតាមច្បាប់កម្ពុជា និង វិធានផ្ទៃក្នុងនៃអវតក។ ហេតុដូច្នេះ សហមេធាវីសន្និដ្ឋានថា សហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភស្តុតាងថា មានមូលហេតុក្នុងការបដិសេធដោះលែងជនត្រូវចោទបណ្តោះអាសន្ន ដោយត្រូវផ្អែកលើមូលដ្ឋានភស្តុតាងមួយឱ្យបានត្រឹមត្រូវ។ ក្នុងការយល់ឃើញរបស់សហមេធាវី សហចៅក្រមស៊ើបអង្កេត ខកខានមិនបានផ្តល់ភស្តុតាងគួរឱ្យជឿជាក់ និង មូលហេតុគ្រប់គ្រាន់ដើម្បីគាំទ្រ សេចក្តីសម្រេចនោះទេ។

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: +(855) 023 219 814 Fax: +(855) 023 219 841 Web: www.eccc.gov.kh

E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00189693

C20/I/22

សហព្រះរាជអាជ្ញាធ្វើការសេចក្តីសន្និដ្ឋានតបថា សហចៅក្រមស៊ើបអង្កេតមិនបានរំលោភបំពានសិទ្ធិនៃការសន្មតជាមុននៃភាពគ្មានទោសឡើយ ដោយលើកឡើងថា បន្ទាប់ពីបានពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងឡើងវិញ "បទដ្ឋាននៃមូលហេតុច្បាស់លាស់នាំឱ្យជឿជាក់យ៉ាងច្បាស់" ត្រូវបានបំពេញ ដែលបទដ្ឋាននោះមានមានកំរិតភស្តុតាងទាបណាស់ប្រៀបធៀបនឹងបទដ្ឋានជាន់ខ្ពស់ដែលត្រូវការចាំបាច់ដើម្បីនឹងកាត់ឱ្យជនត្រូវចោទណាម្នាក់មានទោសក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្មអន្តរជាតិ[22]។ សហព្រះរាជអាជ្ញាបានធ្វើការសន្និដ្ឋានតបទៀតថា សហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការឈានដល់ការសម្រេចសេចក្តី ដែលថាការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការមួយដែលចាំបាច់[23]។ នៅក្នុងយល់ឃើញរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែពិចារណាថា ផ្អែកលើសំណុំរឿង ហេតុផលមួយក្នុងចំណោមហេតុផលទាំងឡាយដូចមានចែងនៅក្នុងវិធាន៦៣(៣)(ខ)បានបំពេញដែរឬទេ[24] ។ សហព្រះរាជអាជ្ញាលើកឡើងថា តាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បន្ទុកនៃការបង្ហាញភស្តុតាងត្រូវជាកាតព្វកិច្ចរបស់ជនត្រូវចោទ ដែលធ្វើយ៉ាងណាឱ្យតុលាការជឿថា ខ្លួនគួរតែត្រូវដោះលែងពីការឃុំខ្លួនបណ្តោះអាសន្ន[25]។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រដល់ជំហររបស់សហព្រះរាជអាជ្ញាទាំងស្រុង ប៉ុន្តែបន្ថែមថា ដោយសារសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន គឺជាឆន្ទានុសិទ្ធិ អង្គបុរេជំនុំ ជម្រះគ្រាន់តែធ្វើការសម្រេចថាតើសហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនត្រឹមត្រូវដែរឬទេ ក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួននេះ[26]។ ចំពោះករណីនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា បណ្តឹងឧទ្ធរណ៍ត្រូវទាត់ចោល ដោយសារបណ្តឹងឧទ្ធរណ៍នេះ "ពុំមានការវិភាគលើករណីថាតើការិយាល័យសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តខុសទៅនឹងអង្គហេតុ និងអង្គច្បាប់" ហើយស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ជំនួសឆន្ទានុសិទ្ធិរបស់ខ្លួន ជាមួយនឹង ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត[27]។

***១). អត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់ច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ( វិធាន ៦៣(៣)(ក) )***

សហមេធាវីការពារក្តីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនគោរពការសន្មតជាមុននៃភាពគ្មានទោស នៅពេលខ្លួនបានរកឃើញមូលហេតុគួរឱ្យជឿជាក់ថា **អៀង ធីរិទ្ធ** បានប្រព្រឹត្តិបទល្មើស ដែលដាក់បន្ទុកមកលើខ្លួន។ សហមេធាវីការពារក្តីក៏បានលើកឡើងថា **អៀង ធីរិទ្ធ** បានបដិសេធការ ទទួលខុសត្រូវចំពោះអំពើ

[22] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៤

[23] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៣

[24] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤

[25] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៥

[26] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៦-១៣

[27] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៧

00189694

C20|I|22

ឧក្រិដ្ឋកម្មទាំងអស់ ដែលចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។ សហមេធាវី ការពារក្តីបានតវ៉ាថា ជនត្រូវចោទមិនធ្លាប់បានធ្វើជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលទទួលខុសត្រូវលើសេចក្តីសម្រេចដែលធ្វើឡើងដោយគណបក្សកុម្មុយនីស្តកម្ពុជានោះទេ ហើយជនត្រូវចោទមិនធ្លាប់ បានចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការខាងលើនេះឡើយ។

សហព្រះរាជអាជ្ញាធ្វើការសេចក្តីសន្និដ្ឋានតបថា សហចៅក្រមស៊ើបអង្កេតមិនបានរំលោភបំពានសិទ្ធិនៃការសន្មតជាមុននៃភាពគ្មានទោសឡើយ ដោយលើកឡើងថា បន្ទាប់ពីបានពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងឡើងវិញ "បទដ្ឋាននៃមូលហេតុច្បាស់លាស់នាំឱ្យជឿជាក់យ៉ាងច្បាស់" ត្រូវបានបំពេញ ដែលបទដ្ឋាននោះមានមានកំរិតភស្តុតាងទាបណាស់ប្រៀបធៀបនឹងបទដ្ឋានជាន់ខ្ពស់ដែលត្រូវការចាំបាច់ដើម្បីនឹងកាត់ឱ្យជនត្រូវចោទណាម្នាក់មានទោសក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្មអន្តរជាតិ[28]។

សហព្រះរាជអាជ្ញាបានលើកឡើងថា ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតថា មានមូលហេតុផលត្រឹមត្រូវដែលនាំឱ្យជឿយ៉ាងច្បាស់ថា **អៀង ធីរិទ្ធ** បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដូចដែលបានបង្ហាញក្នុងកថាខណ្ឌទី ១២២.ក ដល់ ឃ នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរនោះមែន ដោយផ្អែកតាមឯកសារនានានៅក្នុងសំណុំរឿង ហើយត្រូវបានធ្វើឱ្យកាន់តែរឹងមាំថែមទៀត ដោយឯកសារភស្តុតាងបន្ថែមដែលបានបង្ហាញចាប់ពីពេលដែលមានការចេញដីកាឃុំខ្លួន ។ សហព្រះរាជអាជ្ញាបានលើកឡើងថា ទោះបីជាជនត្រូវចោទ **អៀង ធីរិទ្ធ** បានបដិសេធចំពោះការទទួលខុសត្រូវលើបទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់មកលើខ្លួនក៏ដោយ ក៏ជនត្រូវចោទមិនបានប្រកែកថា គាត់មិនមែនជារដ្ឋមន្ត្រីក្រសួងឃោសនាអប់រំ និងយុវជន ក្នុងឆ្នាំ១៩៧៥ និងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចយ៉ាងហោចណាស់ពីឆ្នាំ១៩៧៦ ដល់ ១៩៧៩ នោះទេ ហើយជនត្រូវចោទមិនបានប្រកែកថា ខ្លួនមិនមានការទទួលខុសត្រូវធំទូលាយក្នុងវិស័យសុខាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ[29]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ស្ថិតនៅក្នុងមុខតំណែងជាអ្នកទទួលខុសត្រូវទាំងនេះ និង មុខតំណែងដទៃទៀតដូចដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជនត្រូវចោទ **អៀង ធីរិទ្ធ** បានចូលរួមក្នុងការបង្កើត និងការអនុវត្តនូវគោលនយោបាយឧក្រិដ្ឋ ដែលបណ្តាលឱ្យឧក្រិដ្ឋកម្មទាំងឡាយកើតមានឡើង ដូចមានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ យោងតាមសហព្រះរាជអាជ្ញា ក៏មានភស្តុតាងគាំទ្រផងដែរចំពោះ "ការជាប់ពាក់ព័ន្ធដោយផ្ទាល់" របស់ **អៀង ធីរិទ្ធ** ក្នុងការសម្លាប់បុគ្គលិកក្រសួងសង្គមកិច្ចរាប់រយនាក់ ដោយខុសច្បាប់ នៅមន្ទីរ ស-២១[30] ។

[28] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៤

[29] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០ - ២២

[30] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៣



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

00189695

C20/I/22

***២. ការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចាំបាច់ ( វិធានផ្ទៃក្នុងវិធាន ៦៣(៣)(ខ) )***

***វិធានការចាំបាច់ដើម្បីការពារជនត្រូវចោទក្នុងការគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ ការពារ ការឃុបឃិតគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតនៃបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក (វិធានផ្ទៃក្នុងវិធាន ៦៣(៣)(ខ) (i) )***

សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនបានធ្វើសេចក្តីសម្រេចរបស់ខ្លួនដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងណាមួយដែលបង្ហាញថា **អៀង ធីរិទ្ធ** ធ្លាប់បានធ្វើការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះណាមួយទេក្នុងពេលអតីតកាលនោះឡើយ ដោយគ្រាន់តែបញ្ជាក់នូវកង្វល់ថា "វាខ្លាចក្រែងមាន... ថាជនត្រូវចោទអាចប៉ុនប៉ងធ្វើការគាបសង្កត់ទៅលើសាក្សី"[31] ។ គ្មានភស្តុតាងបញ្ជាក់ថា **អៀង ធីរិទ្ធ** គ្រួសារ ឬ អ្នកគាំទ្របានធ្វើការគាបសង្កត់ទៅលើសាក្សីនាពេលអតីតកាលនោះឡើយ។ សហមេធាវីលើកឡើងថា ការដែលគ្រាន់តែជាការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត មិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការ គាំទ្រមូលដ្ឋានសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ននោះឡើយ ។

សហព្រះរាជអាជ្ញាលើកឡើងថា "ជាការកត់សំគាល់ គឺដោយសារមុខតំណែងជាន់ខ្ពស់ដែលគាត់បានកាន់កាប់ **អៀង ធីរិទ្ធ** ជាស្ត្រីម្នាក់ដ៏មានឥទ្ធិពលនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលសឹងតែក្នុងមួយជីវិតពេញវ័យរបស់គាត់"[32] ។ សហព្រះរាជអាជ្ញាបានលើកឡើងផងដែរថា **អៀង ធីរិទ្ធ** "បានបន្តនូវការចូលរួមជាមួយប្តីរបស់គាត់គឺ **អៀង សារី** ដែលកាន់តំណែងជាន់ខ្ពស់ និងការចូលរួមក្នុងចលនានយោបាយនាពេលថ្មីៗ ក្នុងកំឡុងពេល និង ចាប់តាំងពីរបបរបបកម្ពុជាប្រជាធិបតេយ្យ មានការទទួលស្គាល់ជាខ្លាំង"[33]។ យោងតាមសហព្រះរាជអាជ្ញា **អៀង ធីរិទ្ធ** នៅតែបន្តទទួលការគាំទ្រដ៏មានប្រជាប្រិយ នៅប៉ៃលិន ភ្នំម៉ាឡៃ និង ភ្នំពេញ និងនៅតែមានឥទ្ធិពលគ្របដណ្តប់ទៅលើជនរងគ្រោះ និងសាក្សីនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

សហព្រះរាជអាជ្ញាលើកឡើងថា "ការពិតដែលថា គ្មានជនណាម្នាក់ត្រូវបានគេនាំមកកាត់ទោសក្នុងរយៈពេលជិត៣០ឆ្នាំ ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តកន្លងមកនេះ បានបង្កើតឱ្យមានវប្បធម៌និទណ្ឌភាពសម្រាប់អតីតៈមេដឹកនាំខ្មែរក្រហមនិងជនដែលបានទទួលខុសត្រូវខ្ពស់បំផុតដទៃទៀត"[34]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងថា មានលេចចេញនូវការសាយភាយនៃការភ័យខ្លាចរបស់សាក្សីក្នុងការផ្តល់កសិណសាក្សី ដោយព្រួយបារម្ភ ខ្លាចមានការសងសឹក និងការបំភិតបំភ័យ និងម្យ៉ាងទៀត ពុំមានគំរោងផែនការសម្រាប់ការការពារសាក្សី និងមាន

[31] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (បណ្តឹងឧទ្ធរណ៍) កថាខណ្ឌ ៤៩

[32] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦

[33] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៦

[34] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia 
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

00189696

C20/I/22

អត្រានៃអំពើឧក្រិដ្ឋកម្មដោយហិង្សាក្នុងកំរិតខ្ពស់នៅឡើយ និងអាចរកអាវុធជាតិផ្ទុះមកប្រើប្រាស់បាន។ សហព្រះរាជអាជ្ញាបន្ថែមថា "សាក្សីដែលនៅរស់ពីក្រសួងសង្គមកិច្ច ជាញឹកញាប់ធ្លាប់បានសម្តែងចេញនូវអារម្មណ៍ភ័យខ្លាចរបស់ខ្លួនកាលនៅបំរើការងារជាបុគ្គលិកនៅក្នុងក្រសួងសង្គមកិច្ច ដែលនៅក្រោមបង្គាប់ជនត្រូវចោទ[35] ដូច្នេះអារម្មណ៍ភ័យខ្លាចនេះអាចនឹងវិលត្រឡប់មកវិញ ហើយនឹងរារាំងពួកគេក្នុងការចូលមកធ្វើជាកសិណសាក្សី ប្រសិនបើ **អៀង ធីរិទ្ធ** ត្រូវបានដោះលែង ។

សហព្រះរាជអាជ្ញាលើកឡើងបន្ថែមទៀតថា "ជនត្រូវចោទ មិនត្រឹមតែប្រកែកពីអត្ថិភាពនៃឧក្រិដ្ឋកម្មនានា និងការចូលរួមរបស់គាត់ក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរប៉ុណ្ណោះទេ ថែមទាំងបានថ្កោលទោសជាសាធារណៈចំពោះកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ទៀតផង។ ភស្តុតាងនៃការប្រមាថវិធាននៃច្បាប់ ការប្រព្រឹត្តរបស់គាត់ពីអតីតកាល ឱកាសដែលកំពុងនៅមាន បន្តក្នុងការឃុបឃិតជាមួយនឹងអ្នកសមគំនិត ឬសមាជិកគ្រួសារមានអំណាច និង មុខតំណែងនានាដ៏មានឥទ្ធិពល ពីមុនបង្កើនហានិភ័យយ៉ាងខ្លាំងដែលជនត្រូវចោទអាចនឹងធ្វើការគាបសង្កត់លើសាក្សី និងជនរងគ្រោះ ជាពិសេសអ្នករស់នៅតំបន់ប៉ៃលិន ភ្នំម៉ាឡៃ និងទីក្រុងភ្នំពេញ"[36]។

ជាចុងក្រោយ "សហព្រះរាជអាជ្ញាយល់ស្របជាមួយនឹងការយល់ឃើញដែលបានស្តែងចេញដោយ សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាបង្គាប់ឲ្យឃុំខ្លួនថា ឥឡូវនេះជនត្រូវចោទមានសិទ្ធិពិនិត្យមើលសំណុំរឿងបាន ហើយដឹងអំពីអត្តសញ្ញាណរបស់សាក្សីដាក់បន្ទុកនានា និងជនរងគ្រោះដែលពាក់ព័ន្ធក្នុងកិច្ចដំណើរការនីតិវិធី ការភ័យខ្លាចពីឥទ្ធិពលនិងការគាបសង្កត់លើសាក្សីសំខាន់ៗ គឺជាមូលដ្ឋានត្រឹមត្រូវ[37]។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រទឡ្ហីករណ៍ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ដោយបន្ថែមថា "ដូចដែលលើកឡើងដោយការស្ទាបស្ទង់មតិចុងក្រោយនៅក្នុងសហរដ្ឋអាមេរិកអំពីសិទ្ធិមនុស្ស និងនីតិរដ្ឋ អាជ្ញាធរកម្ពុជាពុំស្ថិតក្នុងឋានៈដ៏មានប្រសិទ្ធិភាព ក្នុងការជំនុំជម្រះអ្នកដែលបំភិតបំភ័យសំខាន់ៗនោះឡើយ"[38] ។

***វិធានការចាំបាច់ដើម្បីរក្សាភស្តុតាង ឬការពារមិនឲ្យមានការបំផ្លាញភស្តុតាង (វិធានផ្ទៃក្នុងវិធាន ៦៣(៣)(ខ)(ii) )***

សហព្រះរាជអាជ្ញាលើកឡើងថា ចម្លើយរបស់សាក្សីអាចចាត់ទុកជាភស្តុតាង ដូច្នេះការធ្វើការគាបសង្កត់លើសាក្សីអាចនាំទៅរកការបំភ្លឺចបំផ្លាញភស្តុតាង ។

[35] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៧

[36] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៩

[37] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០

[38] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៣

00189697

C20/I/22

***វិធានការចាំបាច់ដើម្បីធានានូវការបង្ហាញខ្លួនរបស់ជនត្រូវចោទពេលសវនាការ (វិធានផ្ទៃក្នុងវិធាន ៦៣(៣) (ខ)(iii))***

សហមេធាវីលើកឡើងថា ហានិភ័យពិតប្រាកដនៃការគេចខ្លួនត្រូវតែបង្ហាញ ចំណែកឯសំអាងមិនអាចត្រូវផ្អែកលើតែភាពធ្ងន់ធ្ងរនៃការកាត់ទោសដែលបានប្រឈមមុខប៉ុណ្ណោះទេ ។ លើសពីនេះទៀត យោងតាមសហមេធាវី ប្រសិនបើហេតុផលនោះគឺសម្រាប់តែការឃុំខ្លួន និងប្រសិនបើអាចទទួលបានការធានាចំពោះការចូលរួមក្នុងសវនាការនាពេលអនាគត ជនត្រូវចោទត្រូវតែទទួលបានការដោះលែង[39] ។

សហមេធាវីលើកឡើងថា **អៀង ធីរិទ្ធ** "បានបង្ហាញនូវសកម្មភាពរបស់ខ្លួនដែលថា គាត់ពុំមានចេតនាដើម្បីគេចវេសក្នុងការចូលរួមក្នុងការជំនុំជម្រះក្តីរបស់ខ្លួនឡើយ ប្រសិនបើទទួលបានការដោះលែងបណ្តោះអាសន្ន"[40]។ សហមេធាវីលើកឡើងថា ទោះបីជាជនត្រូវចោទតែងតែធ្វើដំណើរជារឿយៗទៅប្រទេសថៃដើម្បីព្យាបាលជម្ងឺ ប៉ុន្តែតែងតែត្រឡប់មកវិញជាដរាប ។ម្យ៉ាងវិញទៀតសហមេធាវីបានបញ្ជាក់ថា ប្រទេសថៃ និងប្រទេសកម្ពុជាមានសន្ធិសញ្ញាបត្យាប័នរវាងប្រទេសទាំងពីរ ។ សហមេធាវីលើកឡើងបន្ថែមទៀតថា ជនត្រូវចោទមានគ្រួសារកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានចំណងមេត្រីភាពជាមួយនឹងប្រទេសជាតិខ្លាំងក្លាណាស់ដែលជំរុញឲ្យគាត់រស់នៅក្នុងប្រទេស ។ សហមេធាវីលើកឡើងបន្ថែមថា ទោះបីជា **អៀង ធីរិទ្ធ** បានដឹងជាយូរណាស់មកហើយថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ( អវតក ) នឹងត្រូវបានបង្កើតឡើង ហើយទោះជាបានដឹងថាការចាប់ខ្លួននឹងជិតមកដល់ក៏ដោយ[41] គាត់មិនបានព្យាយាមរត់គេចឡើយ ហើយគាត់ត្រូវបានចាប់ខ្លួននៅផ្ទះរបស់គាត់នៅទីក្រុងភ្នំពេញ ។

សហព្រះរាជអាជ្ញាបានលើកឡើងថា ភស្តុតាងពីសំណុំរឿងគាំទ្រការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតសម្រាប់ធ្វើការវាយតម្លៃទៅលើជនម្នាក់ថាតើអាចនឹងរត់គេចខ្លួនឬអត់ ទាក់ទងជាចាំបាច់ទៅនឹងវិធានការនៃការព្យាករណ៍ទុកជាមុន ។ តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញា ភាពធ្ងន់ធ្ងរនៃការផ្តន្ទាទោសប្រសិនបើត្រូវបានដាក់ទោស និងការដែលជនត្រូវចោទនឹងត្រូវផ្តន្ទាទោសជាសាធារណៈនៅចំពោះមុខអតីតៈជនរងគ្រោះចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ ពិតជាបានផ្តល់ការលើកទឹកចិត្តយ៉ាងខ្លាំងដល់ជនត្រូវចោទឱ្យរត់គេចខ្លួន។ **អៀង ធីរិទ្ធ** ក៏មានមធ្យោបាយក្នុងការគេចខ្លួនផងដែរព្រោះថាគាត់ និង ប្តីរបស់គាត់មានមធ្យោបាយសេដ្ឋកិច្ចសន្ធឹកសន្ធាប់ ព្រមទាំងមានសម្ព័ន្ធមិត្តនៅក្នុង និង ក្រៅប្រទេស និងមានលំនៅដ្ឋានមួយដែលនៅជាប់នឹងព្រំដែនថៃ ។ ជាងនេះទៅទៀត សហព្រះរាជអាជ្ញាបានលើកឡើងថា ជនត្រូវចោទបានធ្វើដំណើរ ជាប្រចាំទៅបរទេសចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសគឺ បាងកកប្រទេសថៃ ដែលគាត់អាចមានលំនៅដ្ឋានមួយ

[39] បណ្តឹងឧទ្ធរណ៍ កឋាខណ្ឌ ២៦

[40] បណ្តឹងឧទ្ធរណ៍ កឋាខណ្ឌ ៥៧

[41] បណ្តឹងឧទ្ធរណ៍ កឋាខណ្ឌ ៣

00189698

C20 | I | 22

នៅទីនោះ។ សហព្រះរាជអាជ្ញាបានលើកឡើងថា សហមេធាវីជាតិរបស់ **អៀង ធីរិទ្ធ** បានប្រកាសដោយមិនពិត ក្នុងពេលសវនាការតទល់គ្នាថា លិខិតឆ្លងដែនរបស់ **អៀង ធីរិទ្ធ** មិនទាន់ត្រូវបានពន្យារឡើយបន្ទាប់ពី ខែសីហា ឆ្នាំ២០០៦ តែតាមការពិតជនត្រូវចោទកាន់លិខិតឆ្លងដែនដែលមានសុពលភាពរហូតដល់ថ្ងៃ២៤ ខែមេសា ឆ្នាំ ២០០៩ ។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា **អៀង ធីរិទ្ធ** ដែលទំនងជាបាន ដឹងអំពីការចាប់ខ្លួនមុនពេលការចាប់ខ្លួនដែលបានធ្វើឡើងនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ បានទទួលទិដ្ឋាការប្រទេសថៃមួយ នៅថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០០៧ "ជាទិដ្ឋាការដែលជនត្រូវចោទអាចប្រើប្រាស់សម្រាប់ធ្វើការគេចខ្លួនចេញពីប្រទេសប្រសិនបើការចាប់ខ្លួនមិនត្រូវបានធ្វើឡើងជាបន្ទាន់នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧[42] ។ ចុងក្រោយ សហព្រះរាជអាជ្ញាបានលើកឡើងថា ចាប់តាំងពីពេលដែលមានការដាក់ជូននូវសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបុំណ្ណោះ ដែលឈ្មោះរបស់ **អៀង ធីរិទ្ធ** បានលេចមានក្នុងបណ្តាញសារព័ត៌មានថាជាជនសង្ស័យសក្តានុពល ។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមថា "វាគួរតែត្រូវបានគេកត់សម្គាល់ផងដែរថា អ្នកដែលរស់នៅក្នុងក្រុងប៉ៃលិនមានសិទ្ធិទទួលបាននូវអ្វីដែលហៅថា "ប័ណ្ណឆ្លងដែលពិសេស" ដែលត្រូវគេទទួលស្គាល់ដោយអនុញ្ញាតឱ្យឆ្លងកាត់ព្រំដែន ទោះបីជាគ្មានលិខិតឆ្លងដែន ឬទិដ្ឋាការក៏ដោយ"[43]

<u>**ការពិចារណាទៅលើ ស្ថានភាពសុខភាពរបស់ អៀង ធីរិទ្ធ**</u>

សហមេធាវីលើកឡើងថា **អៀង ធីរិទ្ធ** រងការឈឺចាប់ដោយសារជម្ងឺខាងផ្នែកផ្លូវកាយ និងផ្លូវចិត្តដែលត្រូវការការព្យាបាលខាងផ្នែកវេជ្ជសាស្ត្រ ដូចដែលបានអះអាងក្នុងលិខិតបញ្ជាក់ផ្នែកវេជ្ជសាស្ត្រដែលបានដាក់ជូននាពេលសវនាការតទល់គ្នា និងកំណត់ត្រាផ្នែកវេជ្ជសាស្ត្រ ដែលបានដាក់ជូនមកក្នុង **(ឯកសារបន្ថែម ក)** ហើយដោយផ្អែកតាមឯកសារទាំងនេះ ជនត្រូវចោទមិនអាចមានលទ្ធភាពក្នុងការរត់គេចខ្លួនឡើយ ។ ពេលដែលពិភាក្សាអំពីច្បាប់ជាធរមាន សហមេធាវីធ្វើសំអាងដោយយោងលើយុត្តិសាស្ត្រដែលថា "ការដោះលែងបណ្តោះអាសន្នដោយរង់ចាំការជំនុំជម្រះក្តី ត្រូវបានគេអនុញ្ញាតដោយឈរលើមូលហេតុមនុស្សធម៌[44] ។

សហព្រះរាជអាជ្ញាបានឆ្លើយតបថា ល័ក្ខខ័ណ្ឌសុខភាពរបស់ **អៀង ធីរិទ្ធ** មិនអាចរារាំងគាត់មិនឱ្យរត់គេចដូចដែលសហមេធាវីធ្វើការសន្និដ្ឋានឡើយ ។ សហព្រះរាជអាជ្ញាបានបន្ថែមទៀតថា ពុំមានបញ្ហាសុខភាពផ្លូវកាយណាមួយដូចដែលបានលើកឡើងក្នុងរបាយការណ៍ផ្នែកវេជ្ជសាស្ត្រ ដែលដាក់ជូនមកដោយសហមេធាវី **(ឯកសារបន្ថែម ក)** មានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ដែលបញ្ជាក់ថា ស្ថានភាពសុខភាពរបស់ **អៀង ធីរិទ្ធ** មិនអាចទ្រាំទ្របានជាមួយនឹងការឃុំខ្លួនឡើយ ហើយពុំមានភស្តុតាងណាមួយដែលផ្តល់ការគាំទ្រដល់ការលើកឡើងរបស់សហមេធាវី

---

[42] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៤

[43] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២៨

[44] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩

00189699

C20/I/22

ដែលថាជនត្រូវចោទរងការឈឺចាប់ដោយសារជម្ងឺផ្លូវចិត្តនោះឡើយ[45] ។ ការឃុំខ្លួនបណ្តោះអាសន្ន មិនបានរារាំង **អៀង ធីរិទ្ធ** ក្នុងការទទួលបាននូវការថែទាំសុខភាពគ្រប់គ្រាន់នោះទេ ព្រោះថាការថែទាំសុខភាពត្រូវបានផ្តល់ឱ្យដោយមន្ទីរឃុំឃាំង អ.វ.ត.ក ហើយមានការរៀបចំផ្តល់ឱ្យនូវការត្រួតពិនិត្យសុខភាពជាប្រចាំ ដែលធ្វើឡើងដោយមន្ទីរពេទ្យកាល់ម៉ែត ។

***វិធានការចាំបាច់ដើម្បីការពារសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទ និងរក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈ (វិធានផ្ទៃក្នុងវិធាន ៦៣(៣) (ខ)(iv) និង (v)***

សហមេធាវីការពារក្តីបានលើកឡើងថា ពុំមានភស្តុតាងដើម្បីគាំទ្រសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត ដែលថាការដោះលែង **អៀង ធីរិទ្ធ** បណ្តោះអាសន្នជា "គ្រោះថ្នាក់ដែលនាំឱ្យមានការសម្តែងចេញនូវការមិនសុខចិត្តដែលកើតឡើងពីការឈឺចាប់ ដែលអាចនាំឱ្យកើតមាននូវអំពើហិង្សា ហើយប្រហែលជាអាចធ្វើឱ្យគ្រោះថ្នាក់ដល់ជនត្រូវចោទ" ។ **អៀង ធីរិទ្ធ** បានរស់នៅជាមួយនឹងឈ្មោះពិតប្រាកដ និងឈ្មោះហៅក្រៅ "ភា" នៅតំបន់ដើមរបស់ខ្លួននៅ ម៉ាឡៃ ប៉ៃលិន និងទីក្រុងភ្នំពេញ តាំងពីឆ្នាំ ១៩៧៩ មក[46] ។ ទោះបីជាមានការបង្ហាញប្រាប់ឱ្យដឹងនៅក្នុងអត្ថបទផ្សព្វផ្សាយជាច្រើនថា គាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏គាត់មិនធ្លាប់បានទទួលរងការវាយប្រហារណាមួយ និងមិនធ្លាប់បានទទួលរងការឈឺចាប់ដោយសារបញ្ហានោះឡើយ[47] ។

សហព្រះរាជអាជ្ញាបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តត្រឹមត្រូវក្នុងការយល់ឃើញថាសុវត្ថិភាពរបស់ជនត្រូវចោទអាចជួបនឹងគ្រោះថ្នាក់នៅក្នុងពេលឥឡូវនេះ ដែលការចោទប្រកាន់ជាផ្លូវការប្រឆាំងនឹងរូបគាត់បានចាប់ផ្តើម ម្យ៉ាងវិញទៀត ដោយសារព័ត៌មាននៃការចាប់ខ្លួនរបស់ជនត្រូវចោទត្រូវបានប្រកាសឱ្យដឹងជាសាធារណៈ និងព័ត៌មានស្តីពីតួនាទីរបស់ជនត្រូវចោទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាសឱ្យដឹងជាសាធារណៈដោយប្រព័ន្ធឃោសនាសារព័ត៌មាន ដូច្នេះមានន័យថា ប្រសិនបើគាត់ត្រូវបានដោះលែងនោះគាត់មិនទទួលបាននូវការការពារដូចមុនទៀយ ។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ដោយពិចារណាលើបញ្ហាដែលថា សាធារណជនបានរង់ចាំជាច្រើនឆ្នាំមកហើយ ដើម្បីមើលឃើញនូវការបញ្ចប់នៃនិទណ្ឌភាព ហើយប្រសិនបើ **អៀង ធីរិទ្ធ** ត្រូវបានដោះលែងក្នុងដំណាក់កាលនេះអាចនឹងបញ្ឆេះកំហឹងដល់ក្រុម ឬ សហគមន៍មួយចំនួនឱ្យធ្វើការសងសឹងប្រឆាំងនឹងជនត្រូវចោទ ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា គ្រោះថ្នាក់នៃការវាយប្រហារដោយការសងសឹកត្រូវបានបញ្ជាក់ភស្តុតាងដោយព្រឹត្តការណ៍ដែលថា សាធារណជនមួយចំនួនធំបានរ

---

[45] Annex A សហព្រះរាជអាជ្ញាស្នើសុំឱ្យបដិសេធរបាយការណ៍វេជ្ជសាស្ត្រសរសេរជាភាសាថៃ ដោយសារពុំមានការផ្តល់ការបកប្រែជាភាសាផ្លូវការណាមួយរបស់ អ.វ.ត.ក ។ សូមមើល: ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៩

[46] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧ និង ៥៥

[47] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៥- ៥៦

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00189700

C20/I/22

លំបាកក្នុងការទប់ចិត្តមិនឱ្យប្រព្រឹត្តនូវអំពើហឹង្សានៅពេលដែល **ឌុច** ត្រូវបានចូលមកកាន់សវនាការលើកដំបូងចំពោះមុខ អ.វ.ត.ក ។ យោងតាមសហព្រះរាជអាជ្ញា "ការគំរាមកំហែងដល់សុវត្ថិភាពជនត្រូវចោទ ចេញពីជនរងគ្រោះ និងសាច់ញាតិរបស់ពួកគេ សមាជិក និង បុគ្គលិកដែលធ្លាប់បំរើការងារនៅក្រសួងសង្គមកិច្ចរបស់គាត់ និងសូម្បីតែពីជនត្រូវចោទនានា ឬ ជនសង្ស័យផ្សេងៗទៀតក៏អាចនឹងមានផងដែរ"[48] ។

សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តត្រឹមត្រូវក្នុងការយល់ឃើញថា ការដោះលែង **អៀង ធីរិទ្ធ** អាចនាំឱ្យមានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈដោយពិចារណាថា មានប្រជាជនសឹងតែទាំងអស់បានបាត់បង់សាច់ញាតិ និងមិត្តភ័ក្តិរបស់ខ្លួន នៅក្នុងសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងថាសមាមាត្រមួយផ្នែកនៃចំនួនប្រជាជនសរុបដែលបានរស់នៅឆ្លងកាត់សម័យកាលនោះ ទទួលរងការឈឺចាប់ដោយសារជម្ងឺតានតឹងខាងផ្លូវអារម្មណ៍យ៉ាងធ្ងន់ធ្ងរក្រោយពេលព្រឹត្តិការណ៍ដ៏រន្ធត់នេះបានបញ្ចប់ទៅ សហព្រះរាជអាជ្ញាបានលើកឡើងថា នីតិវិធីរបស់ អ.វ.ត.ក អាចនឹងដាក់ការគំរាមកំហែងដល់សង្គមកម្ពុជា ។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា **អៀង ធីរិទ្ធ** និងប្តីរបស់គាត់បានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈដែលនិយាយអំពី "សេចក្តីបញ្ជាក់ដែលប្រកបដោយភាពលាក់លៀមស្លូតស្លោងបំផុតដល់ផលអវិជ្ជមានទាក់ទងនឹងសន្តិភាព និងសន្តិសុខនៅកម្ពុជា ប្រសិនបើប្រជាជនកម្ពុជាត្រូវបានចោទប្រកាន់"[49] ។ ដូច្នេះការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីទប់ស្កាត់ជនត្រូវចោទកុំឱ្យចេញ សេចក្តីថ្លែងការណ៍បែបនេះតទៅទៀត និងដើម្បីកុំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ។ ស្ថានភាពនេះត្រូវ តែធ្វើការពិចារណានៅក្នុងបរិបទដែលថា ការគាំទ្រអតីតមេដឹកនាំខ្មែរក្រហមនៅតែមាននៅតំបន់ប៉ៃលិន ដែលនៅទីនោះមន្ត្រីរដ្ឋាភិបាលបានធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈថា ការចាប់ខ្លួនជនសង្ស័យដោយ អ.វ.ត.ក គឺជា "រឿងកើតទុក្ខព្រួយបារម្ភ និងរំខានដល់សន្តិភាព"[50] ហើយព្រឹត្តិការណ៍កុប្បកម្មប្រឆាំងនឹងថៃក្នុងឆ្នាំ២០០៣ បង្ហាញ ឱ្យឃើញថាការវាយប្រហារតូចតាចណាមួយមកលើប្រវត្តិសាស្ត្រកម្ពុជាអាចក្លាយទៅជាការផ្ទុះឡើងយ៉ាងធំ ។

__**ការស្នើឡើងនៃការត្រួតពិនិត្យតាមផ្លូវតុលាការ**__

**អៀង ធីរិទ្ធ** បានស្នើឡើងនូវល័ក្ខខ័ណ្ឌមួយចំនួនដែលអាចដាក់បញ្ចូលជាមួយនឹងល័ក្ខខ័ណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដើម្បីធានាថាគាត់នឹងស្នាក់នៅក្នុងទីក្រុងភ្នំពេញ ហើយនឹងមិនធ្វើការទាក់ទងជាមួយនឹងសាក្សី ឬជនរងគ្រោះឡើយ[51]។

---

[48] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥២

[49] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៦

[50] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៨

[51] សំណើសុំឱ្យផ្តល់នូវលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការរបស់អៀង ធីរិទ្ធ Annex C

00189701

C20/I/22

សហព្រះរាជអាជ្ញាបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តដោយត្រឹមត្រូវ ក្នុងការដែលមិនផ្តល់ឱ្យនូវការដោះលែងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ព្រោះថាការប្រកាសរបស់ **អៀង ធីរិទ្ធ** ក្នុង **(ឯកសារបន្ថែម គ)** មិនមែនជាការប្រកាសដែលពិតអាចទុកចិត្តបាននោះទេ ដោយក្នុងសេចក្តីប្រកាសនេះមិនបានបញ្ជាក់នូវផលលំបាក ដែលអាចកើតឡើងក្នុងករណីដែលជនត្រូវចោទនេះមិនបានគោរពតាមល័ក្ខខ័ណ្ឌដែលបានលើកឡើង ហើយមិនបានបញ្ជាក់អំពីការព្រួយបារម្ភទាក់ទងនឹងការការពារសុវត្ថិភាពផ្ទាល់ខ្លួន ឬ ការរក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈឡើយ។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ពុំដែលមានរឿងដូច្នេះពីមុនមកទេក្នុងប្រទេសកម្ពុជា ហើយក៏ពុំមានការដែលធ្លាប់អនុវត្តពីមុន ឬក៏សមត្ថភាពនៃការធានាណាមួយដែលអាចផ្តល់នូវការការពារ ឬ យន្តការនៃការដាក់ឱ្យអនុវត្តដោយបង្ខំឡើយ ព្រោះថាទស្សនៈនេះទើបតែត្រូវបានណែនាំឱ្យប្រើប្រាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានាពេលថ្មីៗនេះប៉ុណ្ណោះ ។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា យោងតាមច្បាប់នីតិវិធីដែលអនុវត្តនៅកំរិតអន្តរជាតិ ជនត្រូវចោទទទួលបន្ទុកក្នុងការបង្ហាញឱ្យឃើញថា គាត់សមនឹងទទួលបានការដោះលែងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[52]។

ភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៨

**សហចៅក្រមបាយការណ៍**

**ចៅក្រម ហួត វុទ្ធី** ចៅក្រម Rowan Downing

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

[52] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣៣-៣៤

# ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ផលវិបាក ការវិភាគ និងអនុសាសន៍

**(តចប់)**

ស្របពេលជាមួយគ្នានឹងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានត្រឹមត្រូវ គ្រូបង្រៀនប្រហែលជានឹងជួបប្រទះនូវជម្លោះនៃការយល់ឃើញប្រវត្តិសាស្ត្រ មិនត្រឹមតែរវាងគ្រូនិងសិស្សទេ ប៉ុន្តែរវាងគ្រូនិងគ្រូទៀតផង ដោយសារតែអ្នកទាំងនេះមានបទពិសោធន៍ ចំណេះដឹង និងនិន្នាការនយោបាយខុសៗគ្នា ។ ជាឧទាហរណ៍ គ្រូមួយចំនួនអាចយល់ឃើញថាវត្តមានរបស់វៀតណាមនៅកម្ពុជាគឺជាទម្រង់នៃការឈ្លានពាន នៅពេលដែលគ្រូមួយចំនួនទៀតចាត់ទុកថាជាការធ្វើអន្តរាគមន៍ ។ នៅក្នុងស្ថានភាពនយោបាយតឹងតែងបែបនេះ គ្រូប្រវត្តិសាស្ត្រអាច "ជួបប្រទះនូវការគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ហើយជាទូទៅស្ថិតនៅក្នុងសម្ពាធធ្ងន់ធ្ងរ...ក្នុងការដើរតួនាទីជាច្រើនចាប់តាំងពីអ្នកចិត្តវិទ្យា អ្នកផ្ដល់ប្រឹក្សា អ្នកជំនាញក្នុងការដោះស្រាយជម្លោះ និងអាជ្ញាកណ្ដាល" ។ ដូច្នេះ មុនពេលបង្ហាត់បង្រៀនសិស្សអំពីចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម វាមានសារសំខាន់ណាស់ក្នុងការហ្វឹកហ្វឺនគ្រូបង្រៀនឲ្យយល់ឲ្យបានទូលំទូលាយអំពីប្រធានបទដ៏រសើបមួយនេះ ។ គ្រូបង្រៀនក៏ត្រូវតែបានបណ្ដុះបណ្ដាលអំពីសីលធម៌ខ្ពស់ក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមផងដែរ ។ គ្រូបង្រៀនត្រូវការការគាំទ្រពីប្រជាជននិងជាពិសេសពីរដ្ឋាភិបាលដើម្បីអាចបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានត្រឹមត្រូវនិងដោយគ្មានការភ័យខ្លាច ។

ដើម្បីជម្នះឲ្យបាននូវឧបសគ្គនេះ ក្រសួងអប់រំស្ថិតនៅក្នុងតួនាទីមួយដ៏ប្រសើរក្នុងការស្វែងរកជំនួយពីប្រភពខាងក្រៅដើម្បីហ្វឹកហ្វឺនបុគ្គលិករបស់ក្រសួង បើកវគ្គបណ្ដុះបណ្ដាលគ្រូបង្រៀនរៀបរៀងឯកសារសម្រាប់បង្រៀននិងបង្កើនវិធីសាស្ត្រក្នុងការបង្រៀនក៏ដូចជាបណ្ដុះការចាប់អារម្មណ៍ដើម្បីធានាឲ្យបានថា គ្រូបង្រៀនមានទាំងសមត្ថភាពនិងឆន្ទៈក្នុងការបង្រៀន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានដើរតួនាទីតាំងពីដំបូងមក ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្ដល់ធនធានឯកសារក្នុងការបង្រៀនជូនដល់ក្រសួងអប់រំ ហើយយល់ព្រមជួយបណ្ដុះបណ្ដាលគ្រូក៏ដូចបង្កើតសៀវភៅណែនាំ ។ សំខាន់ជាងនេះទៅទៀត ឯកសារដែលរៀបរៀងឡើងដោយអង្គការក្រៅរដ្ឋាភិបាលមានភាពត្រឹមត្រូវ និងមិនលម្អៀងនយោបាយ ។ ទោះជាយ៉ាងនេះក្ដី ស្ថាប័នទាំងពីរនេះត្រូវសហការជាមួយគ្នាឲ្យបានល្អ ។

## ដំណោះស្រាយ

វាគឺជាការចាំបាច់ណាស់ក្នុងការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវតែលាតត្រដាងឲ្យបានត្រឹមត្រូវនិងដោយយុត្តិធម៌ មិនមែនត្រូវបានបកស្រាយនិងលើកដាក់ទៅតាមតែអ្នកនយោបាយនោះទេ ។ អ្នកនយោបាយខ្មែរត្រូវតែឈប់ប្រើប្រាស់ទុក្ខវេទនារបស់ប្រជាជនខ្លួនជាឧបករណ៍នយោបាយ ហើយអនុញ្ញាតឲ្យអ្នកវិជ្ជាជីវៈ



អ្នកភូមិកំពុងបំពេញពាក្យបណ្ដឹងនៅខេត្តសៀមរាប

របស់ក្រសួងអប់រំរៀបចំកម្មវិធីសិក្សារបស់សាលា រៀបចំផែនការបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រដើម្បីឲ្យគាត់អាចបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមបាននិងអភិវឌ្ឍវិធីសាស្ត្រក្នុងការបង្រៀនដើម្បីឲ្យសមស្របទៅនឹងការផ្លាស់ប្តូរនេះ ។ វាមានសារសំខាន់ណាស់ក្នុងការជួយឲ្យសិស្សានុសិស្សកម្ពុជាដឹកកកាយការពិតនៃប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន ហើយស្វែងយល់ថា អំពើប្រល័យពូជសាសន៍នៅកម្ពុជាមិនមែនជាវាសនាដែលគាត់តែងឡើងដោយព្រះជាម្ចាស់ឬឥទ្ធិពលនៃមន្តអាគមអ្វីនោះទេ ។ វាគឺបណ្តាលមកពីមនោគមន៍វិជ្ជាជ្រុលហួសហេតុរបស់មេដឹកនាំកម្ពុជាមួយក្រុមដែលជាស្ថាទិកនៃអំពើប្រល័យពូជសាសន៍នេះ ។ កូនខ្មែរត្រូវតែស្វែងយល់ឲ្យបានច្បាស់ថាតើហេតុអ្វីបានជាកម្ពុជាដែលប្រកបដោយវប្បធម៌ខ្ពង់ខ្ពស់ អាចប្រព្រឹត្តអំពើឧក្រិដ្ឋនិងសម្លាប់ប្រជាជនខ្លួនឯងអស់រាប់លាននាក់ដូច្នេះ ។ ដើម្បីដោះស្រាយនូវឧបសគ្គទាំងនេះ អនុសាសន៍មួយចំនួនខាងក្រោមគួរតែត្រូវបានពិចារណានិងអនុវត្ត ។

**ឆន្ទៈនយោបាយ**

ការអភិវឌ្ឍនិងពង្រឹងដំណោះស្រាយចំពោះឧបសគ្គទាំងនេះគឺស្ថិតនៅលើឆន្ទៈនយោបាយភាគច្រើន ។ ដំបូងបំផុតអ្នកនយោបាយត្រូវដករនាំងហាមឃាត់ និងសម្ពាធទាំងឡាយចេញពីផ្លូវឆ្ពោះទៅកាន់ការសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យ ។ រដ្ឋាភិបាលគួរបង្កើតបរិយាកាសសន្តិសុខ ទើបអ្នកសរសេរ អ្នក-និពន្ធ និងអ្នកអប់រំមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការពិភាក្សាពីប្រធានបទប្រកបដោយភាពចម្រូងចម្រាស់ផ្នែកនយោបាយនេះ ។ អ្នកវិភាគភាគច្រើនយល់ឃើញថា សន្តិសុខគ្រប់គ្រាន់ប្រហែលជានឹងមិនអាចទទួលបានទេនៅក្នុងសង្គមមួយដែលទើបតែងើបពីជម្លោះនិងអំពើហិង្សា ។ ទោះជាយ៉ាងនេះក្តី ឆន្ទៈនិងការលះបង់ផ្នែកនយោបាយគឺកូនសោក្នុងការដោះស្រាយឧបសគ្គទាំងនោះ ។ ទាល់តែរនាំងនេះត្រូវរបើកឡើងទើបយើងអាចបន្តដំណើរឆ្ពោះទៅជំហានផ្សេងៗទៀតដែលគ្រាន់តែជាដំណោះស្រាយផ្នែកបច្ចេកទេសប៉ុណ្ណោះ ។

**កំណែទម្រង់កម្មវិធីសិក្សាថ្នាក់វិទ្យាល័យ**

ក្រសួងអប់រំយុវជននិងកីឡាបានអនុម័តជាផ្លូវការយកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យៈ ១៩៧៥-១៩៧៩» បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាជាឯកសារគោលក្នុងការតែងនិពន្ធប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីដាក់បញ្ចូលទៅក្នុងសៀវភៅសិក្សាសង្គមថ្នាក់វិទ្យាល័យដែលនឹងគ្រោងធ្វើឡើងវិញនៅឆ្នាំ២០០៩ ។ ប្រសិនបើរឿងនេះកើតឡើង ហើយដោយសារក្រសួងអប់រំបានរិះគន់ថាសៀវភៅប្រវត្តិសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានចំនួនវែងច្រើនទំព័រវែងពេក ក្រសួងគួរតែដកស្រង់ចេញពីជំពូកសំខាន់ៗបួនដែលរួមមាន : ជំពូកទី២ : តើខ្មែរក្រហមជាអ្នកណា? តើខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណា? ជំពូកទី៣ : កាឡើងកាន់អំណាចរបស់ខ្មែរ-ក្រហម ជំពូកទី៦ : គម្រោងផែនការបួនឆ្នាំ១៩៧៧-១៩៨០ និងជំពូកទី៧ : ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាងនេះទៅទៀត គណៈកម្មាធិការកំណែទម្រង់កម្មវិធីសិក្សាមិនគួរធ្វើការកែប្រែមិនចាំបាច់ណាមួយទៅលើអត្ថន័យដើមទេ ប្រសិនបើចង់ឲ្យកំណែទម្រង់ថ្មីនេះបម្រើឲ្យគោលដៅចម្បង ។ សៀវភៅសិក្សាសង្គមថ្មីគួរតែជាមានលក្ខណៈអព្យាក្រឹតផ្នែកនយោបាយ និងបម្រើដល់ការពង្រីកចំណេះដឹងជាជាងកំណត់ព្រំដែននៃការយល់ដឹងរបស់សិស្ស ។ និយាយម្យ៉ាងទៀត សៀវភៅសិក្សាគឺជាមធ្យោបាយក្នុងការវែកផ្លូវឲ្យសិស្សមើលឃើញកាន់តែទំលំទូលាយដែលអាចនាំឲ្យពួកគេទទួលបានការយល់ដឹងថ្មីៗ ធ្វើបែបនេះ សិស្សអាចពង្រីកចំណេះដឹងរបស់ខ្លួន និង «មានឱកាសបញ្ចេញប្រតិកម្មនិងបង្ហាញពីអារម្មណ៍របស់ខ្លួន និងស្គាល់ពីអារម្មណ៍របស់មិត្តរួមថ្នាក់ផងខ្លួនថែមទៀត» ។ ដូច្នេះ សំណេរប្រវត្តិសាស្ត្រត្រូវតែសរសេរយ៉ាងណាឲ្យបានច្បាស់លាស់ មិនបញ្ចេញបញ្ចូល ប្រាកដប្រជា សមហេតុផលត្រឹមត្រូវនិងមិនលម្អៀងតាមតែអាចធ្វើទៅបាន ។

ជាងនេះទៅទៀត បរិមាណអត្ថបទប្រវត្តិសាស្ត្រខ្មែរក្រហមគួរតែមានចំនួនច្រើនជាងមុនៗ ។ ជាការពិតណាស់ដែលសៀវភៅសិក្សាសង្គមរបស់ក្រសួងអប់រំពីថ្នាក់ទី៩ដល់ថ្នាក់ទី១២រួមមានមេរៀនសំខាន់ៗជាច្រើន ហើយមានចំនួនជាង២០០ទំព័រ ។ គណៈកម្មការត្រួតពិនិត្យរបស់ក្រសួងធ្លាប់បានលើកឡើងពីកង្វល់ដែលថា ការដាក់បញ្ចូលចំនួនទំព័រអំពីប្រវត្តិសាស្ត្រខ្មែរក្រហម

ច្រើនពេកអាចធ្វើឲ្យសៀវភៅសិក្សាមានបរិមាណច្រើនលើសលប់ហើយសិស្សមិនអាចរៀនចប់មេរៀនប្រវត្តិសាស្ត្រនៅក្នុងឆ្នាំសិក្សារបស់ខ្លួនបានទេ ។ ជាងនេះទៅទៀត គណៈកម្មាធិការស្រាវជ្រាវគរុកោសល្យរបស់ក្រសួងអប់រំត្រូវការថ្លឹងថ្លែងរវាងបរិមាណប្រវត្តិសាស្ត្រខ្មែរក្រហមនិងមេរៀនប្រវត្តិសាស្ត្រផ្សេងៗទៀត និងមិនអនុញ្ញាតឲ្យមេរៀនមួយមានចំនួនលើសលប់លើមេរៀនមួយទៀត ។ ទោះជាយ៉ាងនេះក្តី មេរៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមគួរតែមានចំនួន២០ទំព័រក្នុងថ្នាក់នីមួយៗ ។ ជាងនេះទៅទៀត កម្មវិធីសិក្សាថ្មីគួរបញ្ចូលឯកសារបន្ថែមមួយចំនួនទៀត ដូចជាសៀវភៅស្តីអំពីប្រវត្តិរបស់អ្នកដែលនៅរស់រានមានជីវិត ប្រសិនបើចង់ឲ្យសិស្សស្វែងយល់ឲ្យបានច្បាស់អំពីរយៈកាលដ៏ខ្មៅងងឹតនេះ ។

## ការកែប្រែកម្មវិធីសិក្សានៅថ្នាក់មហាវិទ្យាល័យ

ដេប៉ាតឺម៉ង់ប្រវត្តិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវកែសម្រួលកម្មវិធីសិក្សាមួយចំនួនដែលផ្តល់លទ្ធភាពដល់ក្រសួងអប់រំក្នុងការពង្រឹងកំណែទម្រង់កម្មវិធីសិក្សានៅថ្នាក់វិទ្យាល័យ ។ វានឹងក្លាយជាឥតប្រយោជន៍ ប្រសិនបើបរិមាណប្រវត្តិសាស្ត្រខ្មែរក្រហមនៅថ្នាក់វិទ្យាល័យត្រូវបានបង្កើន ប៉ុន្តែសមត្ថភាពគ្រូក្នុងការបង្រៀននៅតែដដែលនោះ ។ ដេប៉ាតឺម៉ង់ប្រវត្តិសាស្ត្រដែលមានតួនាទីបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រត្រូវតែបង្កើនទាំងម៉ោងសិក្សានិងបរិមាណប្រវត្តិសាស្ត្រខ្មែរក្រហម ។ ដេប៉ាតឺម៉ង់គួរតែរៀបចំកម្មវិធីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យទៅជាមុខវិជ្ជាចម្បងមួយ នៅក្នុងកម្មវិធីសិក្សាបរិញ្ញាបត្ររយៈពេលបួនឆ្នាំរបស់ខ្លួន ។ ជាងនេះទៅទៀត សិស្សប្រវត្តិសាស្ត្រទាំងនេះគួរតែត្រូវបានផ្តល់ឱកាសឲ្យទៅទស្សនាមជ្ឈមណ្ឌលប្រល័យពូជសាសន៍សំខាន់ៗមួយចំនួន ដូចជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងវាលពិឃាតជើងឯក ដើម្បីមើលឲ្យឃើញផ្ទាល់ផ្នែកនូវវត្ថុសេសសល់ លលាដ៍ក្បាល រណ្តៅសាកសព ឧបករណ៍ធ្វើទារុណកម្ម និងរូបថតជនរងគ្រោះ ។ និស្សិតទាំងអស់ក៏គួរតែទទួលបាននូវឱកាសទស្សនាខ្សែភាពយន្តឯកសារផងដែរ ។ ដេប៉ាតឺម៉ង់ប្រវត្តិសាស្ត្រអាចបង្កើតកម្មវិធីនេះ ដោយសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបញ្ចាំងខ្សែភាពយន្តជូនដល់និស្សិត ។ ទាំងនេះ នឹងជួយឲ្យនិស្សិតសិក្សាបានកាន់តែច្រើនអំពីរបបខ្មែរក្រហមហើយអាចជួយឲ្យពួកគេធ្វើជាគ្រូបង្រៀនដ៏មានប្រសិទ្ធភាពនាពេលអនាគត ។

## ការបណ្តុះបណ្តាលគ្រូបង្រៀននិងការរៀបរៀងសៀវភៅណែនាំ

ឧបមាថាក្រសួងអប់រំដាក់បញ្ចូលដោយផ្អែកប្តុទាំងស្រុងសៀវភៅប្រវត្តិសាស្ត្រដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាទៅក្នុងកម្មវិធីសិក្សារបស់សាលា ហើយគ្រូបង្រៀនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារបន្ថែមដូចដែលបានពិភាក្សាពីខាងដើម សំណួរបន្ទាប់គឺថាតើយើងត្រូវធ្វើកិច្ចការនេះដោយរបៀបណា? កិច្ចការនេះគឺប្រហាក់ប្រហែលទៅនឹងការអភិវឌ្ឍកម្មវិធីសិក្សានៅថ្នាក់សាកលវិទ្យាល័យដែរ ។ ប៉ុន្តែយើងឈានជំហានវែងជាងមុនមួយជំហានទៀត គឺកសាងសមត្ថភាពគ្រូបង្រៀនឲ្យអាចប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្របានត្រឹមត្រូវនិងផ្តល់ការណែនាំដល់សិស្សឲ្យបានសមស្រប ។ សិក្ខាសាលាស្តីអំពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមមួយគួរតែត្រូវបានរៀបចំឡើងក្នុងកម្រិតថ្នាក់ជាតិ ។ គ្រូប្រវត្តិសាស្ត្រទូទាំងប្រទេសនឹងត្រូវបានអញ្ជើញឲ្យចូលរួមវគ្គសិក្សានេះ ហើយចែករំលែកបទពិសោធន៍និងផលវិបាកដែលខ្លួនជួបប្រទះក្នុងពេលបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ។ កត្តានេះនឹងអនុញ្ញាតឲ្យគ្រូបង្កើតឡើងនូវគោលនយោបាយទូទៅមួយ ដើម្បីដោះស្រាយជាមួយនឹងផលវិបាកទាំងនោះនិងបង្កើតវិធីសាស្ត្រក្នុងការបង្រៀនថ្មីមួយ ។ នៅក្នុងដំណាក់កាលនេះលោកគ្រូអ្នកគ្រូនឹងត្រូវបានផ្តល់ជូននូវឯកសារថ្មីៗព្រមទាំងទទួលការបណ្តុះបណ្តាលបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងអំពីអំពើប្រល័យពូជសាសន៍ផ្សេងៗទៀត ដើម្បីឆ្លុះបញ្ចាំងឲ្យពួកគាត់មើលឃើញថា អំពើប្រល័យពូជសាសន៍មិនមែនកើតឡើងតែនៅប្រទេសកម្ពុជាមួយនោះទេ ប៉ុន្តែវាកើតមានឡើងនៅក្នុងប្រទេសផ្សេងៗជាច្រើនទៀតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។ វគ្គបណ្តុះបណ្តាលនេះអាចត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយនឹងក្រសួងអប់រំយុវជននិងកីឡា និងស្ថាប័នអន្តរជាតិផ្សេងៗទៀត ដែលមានជំនាញខាងការសិក្សាពីអំពើប្រល័យពូជសាសន៍ ។ នៅក្នុងកំឡុងពេលនៃវគ្គបណ្តុះបណ្តាល សៀវភៅណែនាំសម្រាប់គ្រូបង្រៀននឹងត្រូវ

បានដាក់ឲ្យពិភាក្សាក្នុងចំណោមលោកគ្រូអ្នកគ្រូ និងអ្នកជំនាញ ដូច្នេះយើងអាចរៀបរៀងសៀវភៅណែនាំមួយ ដែលអាចយកមកប្រើប្រាស់នៅក្នុងប្រព័ន្ធអប់រំកម្ពុជាបាន ។ សៀវភៅណែនាំនឹងជួយគ្រូក្នុងការរៀបចំផែនការសម្រាប់បង្រៀននិងវិធីសាស្ត្រក្នុងការបង្រៀន ។

## ការស្រាវជ្រាវនិងការបោះពុម្ព

ក្រសួងអប់រំយុវជននិងកីឡាគួរជំរុញលើកទឹកចិត្តអ្នកស្រាវជ្រាវនិងនិស្សិតថ្នាក់ឧត្តមសិក្សាឲ្យធ្វើការស្រាវជ្រាវទៅលើជម្លោះនៅកម្ពុជា សង្គ្រាម និងអំពើប្រល័យពូជសាសន៍ ដើម្បីជួយឲ្យពួកគេស្វែងយល់ពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន និងរកវិធីដើម្បីដោះស្រាយបញ្ហាទាំងនេះប្រកបដោយគតិបណ្ឌិតនាពេលអនាគត ។ ជាងនេះទៅទៀត រដ្ឋាភិបាលគួរបង្កើតបរិយាកាសមួយដែលអ្នកស្រាវជ្រាវអាចចែករំលែកការសិក្សារកឃើញរបស់ខ្លួនជាមួយអ្នកបង្កើតច្បាប់ និងអ្នកអប់រំរបស់ក្រសួងអប់រំដែលចាំបាច់ក្នុងការបំភ្លឺឲ្យអ្នកបង្កើតគោលនយោបាយមើលឃើញថាតើត្រូវរៀបចំកំណែទម្រង់កម្មវិធីសិក្សាដោយរបៀបណា ដើម្បីឲ្យសមស្របទៅនឹងគោលដៅនៃការសិក្សាប្រវត្តិសាស្ត្រដែលមិនមែនគ្រាន់តែដើម្បីថែរក្សាប្រវត្តិសាស្ត្រក្នុងន័យត្រឹមត្រូវមួយនោះទេ ប៉ុន្តែដើម្បីជំរុញដល់ការកសាងសន្តិភាព និងបង្កើតឡើងនូវសេចក្តីអាណិតមេត្តានិងសីលធម៌នៅក្នុងចិត្តរបស់សិស្សទៀតផង ។ និយាយម្យ៉ាងទៀត ការពិភាក្សារវាងអ្នកស្រាវជ្រាវនិងអ្នកអប់រំក្នុងការប្រាប់បញ្ចូលគ្នារវាងការសិក្សាពីអំពើប្រល័យពូជសាសន៍ ការគោរពសិទ្ធិមនុស្ស សន្តិភាព និងប្រជាធិបតេយ្យ និងជំរុញដល់ការយល់ដឹងពីអំពើប្រល័យពូជសាសន៍ ការចងចាំពីអំពើប្រល័យពូជសាសន៍ ការគោរពច្បាប់ ការគោរពសិទ្ធិមនុស្ស សន្តិភាព ប្រជាធិបតេយ្យ ការផ្សះផ្សាជាតិ និងការបង្រួបបង្រួមជាតិ ។ បរិយាកាសនេះនឹងជួយសម្រាលដល់ក្រសួងអប់រំក្នុងកិច្ចការងាររបស់ខ្លួនព្រោះក្រសួងមានការខ្វះខាតផ្នែកធនធានក្នុងការសរសេរមេរៀនប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានត្រឹមត្រូវឬសៀវភៅប្រវត្តិសាស្ត្រដោយខ្លួនឯង ។ សំណើរបស់ក្រសួងដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការរៀបរៀងមេរៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងឆ្នាំ២០០០ គឺជាជំហានដ៏មានសារសំខាន់មួយដែលបង្ហាញឲ្យឃើញថាពីការសហការដ៏ល្អរវាងមន្ត្រីរបស់ក្រសួងនិងអ្នកស្រាវជ្រាវឯករាជក្នុងការផលិតមេរៀនដ៏ចាំបាច់សម្រាប់សិស្ស ។

## ការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល

ក្រសួងអប់រំយុវជននិងកីឡាគួរបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាលដែលមានជំនាញខាងប្រវត្តិសាស្ត្រខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្រាវជ្រាវនិងប្រមូលឯកសារពីរបបខ្មែរក្រហមតាំងពីឆ្នាំ១៩៩៥ ។ ឯកសាររាប់លានទំព័រ បទសម្ភាសន៍រាប់ពាន់ ភាពយន្តឯកសាររាប់រយ និងសៀវភៅស្រាវជ្រាវផ្សេងៗទៀតត្រូវបានរក្សាទុកនៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌល ។ សិស្ស និស្សិត គ្រូបង្រៀន អ្នកស្រាវជ្រាវ និងប្រជាពលរដ្ឋទូទៅអាចធ្វើការស្រាវជ្រាវលើឯកសារទាំងអស់នេះបាន ។ ជាពិសេសទៅទៀត ក្រសួងអប់រំអាចស្នើសុំជំនួយពីមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន ។ កិច្ចការឆ្ពោះទៅកាន់ការសិក្សាពីអំពើប្រល័យពូជសាសន៍គឺជាដំណើរដ៏វែងឆ្ងាយ ។ ដូចគ្នាទៅនឹងដំណើរការនៃការបង្កើតសាលាក្តីដើម្បីកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែរ ។ ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍ត្រូវការកិច្ចខិតខំប្រឹង


អ្នកភូមិកំពុងបំពេញពាក្យបណ្ដឹងនៅខេត្តសៀមរាប

ប្រែងរួមគ្នាមួយរវាងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ។ យើងត្រូវការឆន្ទៈពីរដ្ឋាភិបាលក្នុងការលើកឡើងពីបញ្ហាការយល់ដឹងនិងការចូលរួមពីប្រជាជនដើម្បីដោះស្រាយបញ្ហាការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល ដូចដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើក្នុងការគាំទ្រដំណើរការសាលាក្តីខ្មែរក្រហម និងជំនួយផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសពីម្ចាស់ជំនួយអន្តរជាតិ ។

មិនដូចមួយឬពីរទសវត្សរ៍មុនទេ រាជរដ្ឋាភិបាលកម្ពុជាឥឡូវនេះអាចសម្រួលដល់ការបង្រៀនកូនចៅខ្មែរជំនាន់ក្រោយពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ អ្នកសិក្សាជាតិនិងអន្តរជាតិជាច្រើនបានសរសេរអត្ថបទនិងបោះពុម្ពសៀវភៅដែលអាចប្រើប្រាស់ជាធនធានសម្រាប់បង្រៀនឬជាឯកសារបន្ថែមក្នុងការបង្រៀន ។ ជាងនេះទៅទៀត សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតជើងឯក ទីតាំងបូជនីយដ្ឋាន អតីតមន្ទីរសន្តិសុខខ្មែរក្រហម និងទីតាំងសម្លាប់ដទៃទៀតនៅទូទាំងប្រទេស គឺជាធនធានដែលមិនអាចកាត់ថ្លៃបានសម្រាប់បង្ហាត់បង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ សំខាន់ជាងនេះទៅទៀត កម្ពុជានៅសេសសល់សាក្សីរស់ជាច្រើន ។ អ្នកទាំងនេះគឺមានទាំងជនរងគ្រោះ និងជនដៃដល់ដែលនៅរស់រានជីវិតពីការកាប់សម្លាប់របស់ខ្មែរក្រហម ។ ឯកសាររស់ទាំងនេះគឺជាប្រភពធនធានដ៏ល្អបំផុតសម្រាប់ជាការផ្តល់ប្រឹក្សា ឬការពិភាក្សានៅក្រៅសាលា ។

## ការធ្វើឲ្យប្រសើរឡើងផ្នែកហិរញ្ញវត្ថុ

រដ្ឋាភិបាលគួរតែពង្រីកថវិកាជាតិទៅលើការអភិវឌ្ឍវិស័យអប់រំនិងការស្រាវជ្រាវគរុកោសល្យ ដើម្បីធានាឲ្យបានថាអ្នកអប់រំអាចប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រឲ្យបានត្រឹមត្រូវ ។ កំណែទម្រង់និងការអភិវឌ្ឍវិស័យអប់រំត្រូវការពេលវេលាច្រើននិងចំណាយច្រើន ។ វាគឺជាដំណើរការដ៏វែងមួយដែលតម្រូវឲ្យមានការខិតខំប្រឹងប្រែងរួមគ្នា ។ ដូច្នេះរដ្ឋាភិបាលត្រូវតែបង្កើតបរិយាកាសមួយដែលការអប់រំមិនពាក់ព័ន្ធទៅនឹងបញ្ហាកង្វះថវិកា ដែលនេះជាបញ្ហាចម្បងមួយនៅកម្ពុជានាពេលបច្ចុប្បន្ន ។ តម្រូវការចាំបាច់ជាបន្ទាន់មួយក្នុងការពង្រឹងការបង្ហាត់បង្រៀនគឺស្ថានភាពរស់នៅរបស់គ្រូបង្រៀន ។ ប្រាក់បៀវត្សរ៍ទាបនឹងធ្វើឲ្យគ្រូគ្មានទឹកចិត្តក្នុងការស្រាវជ្រាវបន្ថែមដើម្បីពង្រឹងគុណភាពបង្រៀនរបស់ខ្លួន ។

## សេចក្តីបញ្ចប់

វាមានរយៈពេលជិតបីសតវត្សរ៍មកហើយចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ការអប់រំអំពីព្រឹត្តិការណ៍ដ៏មានសារសំខាន់នៅក្នុងរយៈកាលនៃរបបខ្មែរក្រហមនៅតែគ្មានដំណោះស្រាយ ហើយការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមមិនដែលត្រូវបានដាក់ឲ្យសិក្សាឲ្យបានត្រឹមត្រូវ សមស្រប និងប្រកបដោយគរុកោសល្យនៅតាមគ្រឹះស្ថានសិក្សារបស់រដ្ឋទេ ។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏មានសារសំខាន់នេះត្រូវបានបកស្រាយនិងឲ្យនិយមន័យទៅតាមទស្សនយោបាយផ្សេងៗគ្នាជាច្រើនអាស្រ័យទៅលើបរិយាកាសនយោបាយនិងនិន្នាការ-នយោបាយ ។ បរិយាកាសនយោបាយជាអ្នកកំណត់នូវវិធីដែលអ្នកសរសេរ អ្នកនិពន្ធនិងគណៈកម្មការនិពន្ធនិងត្រួតពិនិត្យរបស់ក្រសួងអប់រំក្នុងការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ។ ការរៀបរាប់ពីប្រវត្តិសាស្ត្រនៅក្នុងសៀវភៅសិក្សារបស់សាលាត្រូវតែតំណាងឲ្យផលប្រយោជន៍របស់មេដឹកនាំនយោបាយដែលមានអំណាច ។ ប្រសិនបើមិនដូច្នេះទេ នោះប្រវត្តិសាស្ត្រនឹងមិនត្រូវបានអនុម័តឲ្យដាក់បញ្ចូលទៅក្នុងសៀវភៅសិក្សារបស់សាលាឡើយ ហើយសិស្សនឹងមិនអាចមានលទ្ធភាពស្វែងយល់ពីការពិតនៃប្រវត្តិសាស្ត្រដែលចុងក្រោយប្រវត្តិសាស្ត្រនឹងក្លាយទៅជារឿងអាថ៌កំបាំង ហើយការពិតនៃប្រវត្តិសាស្ត្រត្រូវបានបញ្ចេញបញ្ចូលនិងផ្តេកផ្តួលទៅតាមបរិយាកាសនយោបាយ ។

អវត្តមាននៃប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងការអប់រំជាសាធារណៈបានអនុញ្ញាតឲ្យអ្នកនយោបាយធ្វើការបកស្រាយនិងបន្ថែមបន្ថយដើម្បីបង្កើតទៅជាសារនយោបាយដល់ប្រជាពលរដ្ឋនិងជាពិសេសកូនខ្មែរជំនាន់ក្រោយ ។ ឧទាហរណ៍ លោក ខៀវ សំផន នៅក្នុងបទសម្ភាសន៍ចុងក្រោយមួយជាមួយវិទ្យុសំឡេងសហរដ្ឋអាមេរិកនាខែតុលាឆ្នាំ២០០៧ បានអះអាងថា ប្រសិនបើគ្មានបដិវត្តន៍ខ្មែរក្រហមទេនោះ កម្ពុជានឹងក្លាយទៅជាវៀតណាមហើយថាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនឹងមិនអាចឈានដល់ចំណុចត្រូវរ៉ូវគ្នាបានឡើយបើគ្មានខ្មែរក្រហម ព្រោះភាគីខ្មែរ

ក្រហមគឺជាកម្លាំងចលករធំមួយនៅពីក្រោយការបរបោ ។ ម្យ៉ាងវិញទៀត មេដឹកនាំគណបក្សប្រជាជនកម្ពុជានៅក្នុងសុន្ទរកថាជាសាធារណៈជាច្រើន ជាពិសេសក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០ បានបញ្ជាក់ជាញឹកញាយថា ប្រសិនបើគ្មានថ្ងៃ៧មករា ខ្មែរក្រហមនឹងបន្តកាន់អំណាចនៅកម្ពុជា ហើយប្រជាជនខ្មែរជាច្រើនសែននាក់ថែមទៀតនឹងត្រូវបានកាប់សម្លាប់ ហើយថានឹងមិនមានកម្ពុជានៅថ្ងៃនេះទេ ។ ដូច្នេះ តើអ្វីទៅជាការពិតនៅពីក្រោយការឃោសនានយោបាយទាំងនេះ? បញ្ហានេះគឺមានលក្ខណៈដូចជារឿងនិទាន «ពងមាន់និងមេមាន់» មិនដឹងមួយណាកើតមុន ។ សិស្សនឹងមានការពិបាកក្នុងការបែងចែកនិងស្វែងរកការពិត ប្រសិនបើគ្មានការសិក្សាឲ្យបានត្រឹមត្រូវច្បាស់លាស់ ។

តាមរយៈការអង្កេតនិងការស្រាវជ្រាវទៅលើសៀវភៅសិក្សាជាច្រើនដែលរៀបរៀងឡើងសម្រាប់កម្មវិធីសិក្សារបស់សាលាចាប់តាំងពីឆ្នាំ១៩៧៩ រហូតមកដល់ពេលបច្ចុប្បន្ននេះ សៀវភៅសិក្សាសម្រាប់សាលានិយាយតែអំពីព្រឹត្តិការណ៍អស្ចារ្យរបស់របបដែលមានជ័យជម្នះ ហើយនិយាយអំពីរឿងអាក្រក់របស់របបដែលចាញ់សង្គ្រាម ។ អ្នកនិពន្ធមិនបានបន្សល់ទុកនូវចំណុចវិវាទសម្រាប់ការពិភាក្សានៅក្នុងថ្នាក់រៀនទេ ។ ផ្ទុយទៅវិញ អ្នកនិពន្ធបានបង្ហាញពីការវិនិច្ឆ័យច្បាស់លាស់ទៅលើចំណុចដែលអាចយកមកពិភាក្សាបានដែលធ្វើឲ្យសិស្សមានអារម្មណ៍ថា ខ្លួនត្រូវតែទទួលយកនូវគំនិតដែលដាក់មកឲ្យសិក្សាថាជាការពិតនៃប្រវត្តិសាស្ត្រជាជាងថាខ្លួនមានកាតព្វកិច្ចក្នុងការពិភាក្សាដើម្បីស្វែងរកការពិត ។ ប្រវត្តិសាស្ត្រគួរតែត្រូវបានបង្រៀន «ក្នុងទម្រង់មួយដែលបណ្តុះគំនិតក្មេងឲ្យជឿលើសមត្ថភាពរបស់ខ្លួនក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គម ហើយចេញពីនេះមានលទ្ធភាពរួមចំណែកក្នុងការពង្រឹងសន្តិភាពនិងយុត្តិធម៌នាពេលអនាគត» ។

ចំណុចវិវាទនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហមគឺជាឧទាហរណ៍ដ៏ល្អនៅក្នុងបញ្ហានេះ ។ ការនិយាយពីរឿងរ៉ាវពិតនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនឹងជួបប្រទះនូវសម្ពាធនយោបាយដោយសារអ្នកនយោបាយជាច្រើននៅកម្ពុជាមិនទាន់អាចទទួលយកបាននូវការពិតមួយចំនួនថាជាការពិតនៃប្រវត្តិសាស្ត្រ ។ នេះគឺជាវិបត្តិធំមួយនៅក្នុងប្រព័ន្ធអប់រំនៅកម្ពុជា ដែលត្រូវការការលះបង់និងការតាំងចិត្តផ្នែកនយោបាយខ្លាំងដើម្បីពុះពារនូវឧបសគ្គទាំងនេះ ។

ទោះជាយ៉ាងនេះក្តី វាជារឿងមួយដែលអាចយល់បានថាប្រទេសក្រោយសង្គ្រាមនិងជាប្រទេសដែលប្រកបដោយការបែងចែកនៅក្នុងសង្គមដូចជាកម្ពុជាត្រូវតែទទួលរងនូវឥទ្ធិពលនយោបាយច្រើនប្រភេទ ដែលផលប្រយោជន៍របស់បុគ្គលឬបក្សពួកមានអាទិភាពលើផលប្រយោជន៍ជាតិ ។ ទោះបីជាការពិតនៃប្រវត្តិសាស្ត្រត្រូវបានដាក់ឲ្យសិក្សា ក៏ជាទូទៅវាមានភាពលម្អៀងដែលលើកតម្កើង តែអ្នកមានអំណាច និងអ្នកដែលមានសមិទ្ធផលក្នុងការបញ្ចប់ជម្លោះ អាណានិគម អំពើប្រល័យពូជសាសន៍ ឬក៏ការឈ្លានពាន និងអ្នកដែលមានលទ្ធភាពក្នុងការផ្សះផ្សានិងកសាងជាតិ ។ ជាងនេះទៅទៀត វាមានការលំបាកសម្រាប់កម្ពុជាដែលទទួលរងនូវភាពខ្ទេចខ្ទាំ ក្នុងការដាក់ឲ្យសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមដែលពិតឥតលម្អៀង ដោយសារតែកន្លងមកមិនទាន់មានការយល់ស្របគ្នារវាងអ្នកនយោបាយ និងអ្នកអប់រំថា តើត្រូវបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ក៏ដូចជាប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើបផ្សេងៗទៀតដោយរបៀបណា ។ អ្នកវិភាគមួយចំនួនបានកត់សម្គាល់ថា «នៅក្នុងសង្គមដែលទើបតែងើបពីជម្លោះហិង្សា សំណួរមួយដែលថាតើត្រូវដោះស្រាយជាមួយអតីតកាលដោយរបៀបណាគឺមានលក្ខណៈស្រួចស្រាវ ជាពិសេសនៅពេលដែលអតីតកាលនោះជាប់ពាក់ព័ន្ធទៅនឹងការចងចាំនូវភាពរងគ្រោះ ការស្លាប់និងភាពខ្ទេចខ្ទាំក្នុងទ្រង់ទ្រាយធំដែលប្រជាជនភាគច្រើនទទួលរងនូវការប៉ះទង្គិច» ។ ទោះជាយ៉ាងនេះក្តី យោងតាមស្ថានភាពជាក់ស្តែងនៅកម្ពុជា សំណួរដែលថាតើប្រវត្តិសាស្ត្រដែលប្រកបដោយភាពចម្រូងចម្រាស់នេះគួរត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាលាឬអត់ គឺស្ថិតនៅលើសុឆន្ទៈ ការតាំងចិត្ត ការលះបង់និងសម្បទានក្នុងចំណោមអ្នកនយោបាយសំខាន់ៗមួយចំនួន ។

ប្រវត្តិសាស្ត្រខ្មែរក្រហមមានលក្ខណៈរសើបផ្នែកនយោបាយនិងផ្លូវចិត្ត ពីព្រោះវាប៉ះពាល់និងផ្សារភ្ជាប់គ្រប់ផ្នែកនៃប្រវត្តិសាស្ត្រកម្ពុជាទាំងអស់តាំងពីសម័យអាណានិគមនិយមបារាំងរហូតមកដល់ពេលបច្ចុប្បន្ន ។ វាមានសារសំខាន់ណាស់ដែលកូនខ្មែរជំនាន់ក្រោយនាពេលបច្ចុប្បន្ននិងអនាគតយល់ដឹងឲ្យបានច្បាស់លាស់អំពីរបៀបដែលមេដឹកនាំខ្មែរនៅគ្រប់សម័យកាលទាំងអស់ដឹកនាំ

ប្រទេស ។ វាមានសារសំខាន់សម្រាប់សិស្សក្នុងការយល់ដឹងអំពីរបៀបដែលអតីតមេដឹកនាំខ្មែរមួយចំនួនសាបព្រោះមនោគមន៍វិជ្ជាប្រកបដោយឥទ្ធិពលទៅក្នុងសំណាញ់សង្គមដែលជះឥទ្ធិពលដល់ប្រជាជននៅទូទាំងប្រទេស ។ ប្រសិនបើយើងគ្មានលទ្ធភាពស្វែងយល់ពីបញ្ហាដែលកើតមានឡើងនៅក្នុងអតីតកាល បញ្ហានោះនឹងកាន់តែរីកធំឡើង ហើយអនុញ្ញាតឲ្យរចនាសម្ព័ន្ធសង្គមពុករលួយពីអតីតកាលកើតឡើងសាជាថ្មីម្តងទៀតដែលជះផលអាក្រក់ដល់ប្រជាជននិងសង្គមជាតិទាំងមូល ។

ការស្រាវជ្រាវពីប្រវត្តិនៃអំពើហិង្សា ជម្លោះ និងអំពើប្រល័យពូជសាសន៍នៅក្នុងសង្គមកម្ពុជាកន្លងមក ជាពិសេសរបបខ្មែរក្រហមត្រូវតែធ្វើឡើងដោយហ្មត់ចត់ និងដាក់ឲ្យសិស្សសិក្សាឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ។ បញ្ហាពេលវេលាអាចផ្លាស់ប្តូរអត្ថន័យនិងតម្លៃនៃប្រវត្តិសាស្ត្រ និងផ្លាស់ប្តូរទស្សនៈរបស់សិស្សទៅលើប្រវត្តិសាស្ត្រ ។ នៅក្នុងជំនាន់បច្ចុប្បន្ននៃទសវត្សរ៍ឆ្នាំ ២០០០នេះ សិស្សវិទ្យាល័យអាចចែករំលែកអ្វីដែលខ្លួនបានរៀនពីសាលា ជាមួយឪពុកម្តាយ ជីដូនជីតា និងបងប្អូនដែលធ្លាប់រស់នៅនិងរួចរស់ជីវិតពីរបបខ្មែរក្រហម ។ នៅក្នុងមួយឬពីរជំនាន់ទៅមុខទៀត សិស្សអាចមើលឃើញ ប្រវត្តិសាស្ត្រខ្មែរក្រហមក៏ដូចជាប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជាដទៃទៀតផ្សេងគ្នា ហើយប្រហែលជាយល់ឃើញថា ប្រវត្តិសាស្ត្រទាំងនោះមិនមានទំនាក់ទំនងអ្វីជាមួយជីវិតប្រចាំថ្ងៃរបស់ខ្លួន ។ សំខាន់ជាងនេះទៅទៀត ទោះជារបបខ្មែរក្រហមបានបញ្ចប់ទៅមែន ប៉ុន្តែមរតកនៃរបបនេះនៅបន្សល់ទុកនៅឡើយ ។ នេះគឺជាវិបត្តិថ្មីនៅក្នុងសង្គមដែលអ្នកស្រាវជ្រាវមួយចំនួនបានអះអាងថា «ជម្លោះស្ទើរតែទាំងអស់តែងតែបន្តទៅមុខនៅក្នុងកម្រិតណាមួយ ហើយអំពើហិង្សាលេចចេញជារូបរាងថ្មីនៅពេលបច្ចុប្បន្ន» ។ ដូច្នេះទម្រង់ចាស់នៃជម្លោះហិង្សាគួរតែត្រូវតែសិក្សា ដើម្បីបង្កើតជាមូលដ្ឋានក្នុងការដោះស្រាយជាមួយទម្រង់ថ្មីនៃអំពើហិង្សាទាំងនេះ ។ អ្នកស្រាវជ្រាវបានបន្តអះអាងថា «ប្រសិនបើសង្គមមួយមិនលើកយកមូលហេតុនៃជម្លោះមកពិភាក្សាឲ្យបានត្រឹមត្រូវទេ បញ្ហានេះនឹងក្លាយទៅជាបង្អែកនៃអស្ថិរភាពនិងជម្លោះនាពេលអនាគត» ។ នៅកម្ពុជា ការតស៊ូអំណាច ការរំលោភបំពានលើផ្លូវភេទ អំពើពេស្យាចារក្មេងពាលាអាវ៉ាសែ អំពើហិង្សាក្នុងគ្រួសារ អយុត្តិធម៌ នៅក្នុងសង្គម ការរំលោភសិទ្ធមនុស្ស អំពើពុករលួយ ភាពអវិជ្ជា និងនិទ្ទណ្ឌភាពនៅតែបន្តជាបញ្ហាចម្បងនៅក្នុងសង្គមនៅឡើយ ។ វិបត្តិទាំងអស់នេះបានកើតមានឡើងនៅរបបមុនៗ ហើយបញ្ហាមួយចំនួនកាន់តែមានសភាពធ្ងន់ធ្ងរនាពេលបច្ចុប្បន្ន ។

ជាទូទៅ ឧបសគ្គផ្នែកសង្គម សេដ្ឋកិច្ច និងគរុកោសល្យចំពោះការសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាមិនមែនជាឧបសគ្គចម្បងដូចឧបសគ្គនយោបាយនោះទេ ។ នៅពេលដែលបញ្ហានយោបាយត្រូវបានដោះស្រាយឧបសគ្គដទៃៗទៀតនឹងមិនមានការលំបាកក្នុងការដោះស្រាយ ឬជាផ្នែកមួយដែលធ្វើឲ្យមានការខ្វល់ខ្វាយខ្លាំងទេ ដោយសារបញ្ហាទាំងអស់នេះគ្រាន់តែជាផ្នែកមួយនៃជំនាញបច្ចេកទេសប៉ុណ្ណោះ ។ ប្រសិនបើស្ថាប័ននយោបាយមិនគាំទ្រដល់គោលដៅក្នុងការបង្ហាត់បង្រៀនកូនខ្មែរជំនាន់ក្រោយអំពីរបបកម្ពុជាប្រជាធិបតេយ្យ ឧបសគ្គទាំងអស់ប្រហែលជានឹងមិនអាចត្រូវបានដោះស្រាយឡើយ ។ បញ្ហាជាគន្លឹះនាពេលបច្ចុប្បន្ននេះគឺថារដ្ឋាភិបាលហាក់ដូចជាមិនចែករំលែកការខ្វល់ខ្វាយអំពីតម្រូវការជាបន្ទាន់នៃការសិក្សាពីអំពើប្រល័យពូជសាសន៍ផងទេ ។ ដោយមានការជំរុញលើកទឹកចិត្តនិងសម្ពាធពីខាងក្រៅមួយចំនួន រដ្ឋាភិបាលយល់ព្រមទទួលយកប្រធានបទនេះដាក់ចូលក្នុងរបៀបវារៈសម្រាប់ការពិភាក្សារបស់ខ្លួន ប៉ុន្តែបានលើកហេតុផលចំពោះការដកចេញប្រវត្តិសាស្ត្រខ្មែរក្រហមពីកម្មវិធីសិក្សារបស់សាលាថាមកពីការខ្វះខាតធនធាននិងហិរញ្ញវត្ថុក្នុងការស្រាវជ្រាវនិងបោះពុម្ព ។ បើទោះបីជាការស្រាវជ្រាវនិងការបោះពុម្ពដូចជា សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានបំពេញពីប្រភពខាងក្រៅដូចជាអង្គការនិងស្ថាប័នក្រៅរដ្ឋាភិបាលដែលមានជំនាញលើផ្នែកនេះក៏ដោយក៏រដ្ឋាភិបាលមិនមានឆន្ទៈនយោបាយគ្រប់គ្រាន់ក្នុងការដាក់បញ្ចូលការស្រាវជ្រាវនេះទៅក្នុងកម្មវិធីសិក្សារបស់សាលានៅឡើយ ។ នៅពេលដែលពេលវេលាបានកន្លងផុតទៅ ហើយគួបផ្សំនឹងការបង្កើតសាលាក្តីខ្មែរក្រហម និងដោយមានការទាមទារពីសំណាក់សិស្ស គ្រូបង្រៀន និងប្រជាពលរដ្ឋទូទៅក្នុងការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម រដ្ឋាភិបាលបានយល់ព្រមប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រដែល

បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែជាមួយនឹងលក្ខណ្ឌថា ក្រសួងអប់រំនឹងអនុវត្តសិទ្ធិពេញលេញក្នុងការកែសម្រួលទៅលើសៀវភៅនេះ ដោយមិនមានអន្តរាគមន៍ឬការចូលរួមពីខាងក្រៅ ។ នៅទីបញ្ចប់ ប្រវត្តិសាស្ត្រខ្មែរក្រហមហាក់ដូចជាស្ថិតនៅជាឧបករណ៍នយោបាយដដែល ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ ស្ថានភាពស្តីពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ។ ទោះបីជារដ្ឋាភិបាលមិនបានយល់ព្រមឲ្យដាក់បញ្ចូលសៀវភៅប្រវត្តិ-សាស្ត្រខ្មែរក្រហមដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាទៅក្នុងកម្មវិធីសិក្សារបស់សាលាក៏ដោយ ក៏រដ្ឋាភិបាលបានយល់ព្រមឲ្យទទួលយកការពិភាក្សា និងចែករំលែកកន្លែងមួយចំនួនដែលអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត ដែលធ្វើការទាក់ទងនឹងការអប់រំ បង្កើតបានជាមូលដ្ឋានក្នុងការសម្របសម្រួលនិងដោះស្រាយបញ្ហានេះ ។ ជាងនេះទៅទៀត គណៈកម្មការត្រួតពិនិត្យសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានអនុញ្ញាតជាផ្លូវការឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការបោះពុម្ពនិងចែកចាយសៀវភៅប្រវត្តិសាស្ត្រទៅគ្រប់វិទ្យាល័យទាំងអស់នៅទូទាំងប្រទេស ។ នេះគឺជាលើកទីមួយដែលរាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឲ្យធ្វើការចែកចាយការបោះពុម្ពសៀវភៅជាភាសាខ្មែរដែលប្រកបដោយជម្លោះនយោបាយនេះ ។

ការសិក្សាពីអំពើប្រល័យពូជសាសន៍ គឺជាវិធីដ៏មានប្រសិទ្ធភាពមួយ ដើម្បីបង្កើតសង្គមមួយដែលចាកផុតពីការរំលោភសិទ្ធិមនុស្សនិងអំពើហិង្សាក្នុងទ្រង់ទ្រាយធំ ។ ប្រទេសកម្ពុជានិងប្រជាជនកម្ពុជាបានទទួលរងគ្រោះនិងការឈឺចាប់ពីសង្គ្រាម អំពើប្រល័យពូជសាសន៍ ជម្លោះ និងអំពើហិង្សាអស់ជាច្រើនទសវត្សរ៍មកហើយ ។ ឥឡូវនេះគឺជាពេលវេលាដែលយើងត្រូវសិក្សាពីអតីតកាលដើម្បីកសាងអនាគតមួយ ហើយប្រើប្រាស់បទពិសោធន៍ទាំងឡាយក្នុងអតីតកាលជាយន្តការមួយក្នុងការបង្ហាត់បង្រៀនកូនចៅជំនាន់ក្រោយឲ្យមានសាមគ្គីភាពក្នុងសង្គម ។ ធ្វើដូច្នេះ ទើបអត្ថន័យនៃពាក្យប្រជាធិបតេយ្យ សន្តិភាព ការផ្សះផ្សាជាតិ ការគោរពច្បាប់ ការគោរពសិទ្ធិមនុស្ស និងឯកភាពជាតិ ដែលអ្នកនយោបាយតែងតែនិយាយអាចដាក់ឲ្យទៅជាការអនុវត្តជាក់ស្តែងបាន ។ ការបង្ហាត់បង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្មេងជំនាន់ក្រោយបម្រើឲ្យផលប្រយោជន៍រួមរបស់ប្រជាជនកម្ពុជានិងមនុស្សជាតិទាំងអស់ ។ វាគឺជាប្រវត្តិសាស្ត្ររបស់យើង ហើយវាគឺជាកាតព្វកិច្ចរបស់យើងក្នុងការសិក្សា ។ មិនមានអ្នកណាម្នាក់មានសិទ្ធិដកហូតការយល់ដឹងពីអតីតកាលរបស់កូនខ្មែរជំនាន់ក្រោយបានទេ ។ ការដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងសៀវភៅសិក្សាសម្រាប់សិស្ស មិនមែនគ្រាន់តែទទួលស្គាល់ការឈឺចាប់របស់មនុស្សជំនាន់មុនប៉ុណ្ណោះទេ ប៉ុន្តែដើម្បីបណ្តុះឥរិយាបថរបស់មនុស្សជំនាន់ក្រោយឲ្យក្លាយទៅជាអ្នកដឹកនាំល្អនាពេលអនាគតថែមទៀត ។ ការយល់ដឹង ពីព្រឹត្តិការណ៍ទាំងមូលនៅក្នុងប្រវត្តិសាស្ត្រខ្មែរក្រហមនឹងអនុញ្ញាតឲ្យក្មេងជំនាន់ក្រោយមានលទ្ធភាពចូលរួមក្នុងការដោះស្រាយបញ្ហាក្នុងសង្គម និងដំណើរការនៃការអភិវឌ្ឍប្រទេសជាតិ ។

**ឌី ខាំបូលី**

# ការចូលរួមរបស់ជនរងគ្រោះ

នៅអំឡុងឆ្នាំ២០០៨មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងចង់ឲ្យជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិច ១០,០០០នាក់ ចូលរួមបំពេញពាក្យបណ្តឹង (ជាឧក្រិដ្ឋកម្ម ឬជាដើមបណ្តឹងរដ្ឋប្បវេណី) មុនពេលចូលទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញពីសកម្មភាពនេះថាជាការជួយដល់ប្រជាជនសាមញ្ញកម្ពុជាឲ្យចូលរួមក្នុងដំណើរការនាំយកមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាត់ទោសនៅមុខច្បាប់និងដំណើរការម្តងទៀតនូវ «គណៈកម្មការស្វែងរកការពិត» ជាលក្ខណៈមិនសូវផ្លូវការដែលគណៈកម្មការនេះបានចាប់ផ្តើមតាំងពីអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០ម៉្លេះ ដោយការចុះហត្ថលេខាលើញត្តិរណសិរ្ស ។

សម្រាប់ព័ត៌មានលម្អិតសុំទំនាក់ទំនង លោក ជី ទេរិទ្ធិ តាមរយៈលេខទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

# យុវជនទទួលចំណេះដឹងពីរបបខ្មែរក្រហម

នៅកម្ពុជាប្រជាជនចំនួន៦០ភាគរយកើតក្រោយរបបខ្មែរក្រហម ។ យុវជនទាំងនេះដឹងក្តីនៅក្នុងភាពស្រពេចស្រពិលទាក់ទងនឹងសោកនាដកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រោះមិនទាន់បានបញ្ចូលនៅក្នុងកម្មវិធីសិក្សា គឺបានត្រឹមតែស្តាប់ឪពុកម្តាយរៀបរាប់ប្រាប់ដោយខ្វះចន្លោះដែលធ្វើឲ្យគេពិបាកនឹងជឿ ។ នៅចំពោះមុខការមិនយល់ដឹងរបស់មនុស្សជំនាន់នេះ អំពីជំពូកប្រវត្តិសាស្ត្រដែលកត់ត្រាជាប់នៅក្នុងសង្គមខ្មែរ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បំផុសគំនិតយុវជនទាំងនោះឲ្យក្លាយជាអ្នកប្រមូលនូវការចងចាំ ។ ប៉ុន្តែមិនមែនចេះតែប្រមូលនោះទេ គឺគេប្រមូលតែការចងចាំរបស់ឪពុកម្តាយពួកគេដែលនៅរស់ប៉ុណ្ណោះ ។

## សិក្សារឿងប្រវត្តិសាស្ត្រតាមរយៈដំណើររឿងគ្រួសារ

ស៊ុត ណាស៊ាត ជនជាតិចាម អាយុ២៥ឆ្នាំ មានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំងទាក់ទងរឿងរបស់ម្តាយដែលបានសរសេរនៅលើក្រដាសក្នុងក្របខ័ណ្ឌនៃការប្រឡងប្រជែងមួយដែលរៀបចំឡើងកាលពីឆ្នាំមុនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឯកសារនេះមានកម្រាស់១០ទំព័រ សរសេរយ៉ាងជ្និតជ្និតដុង់ជាមួយអត្ថន័យ «ជនជាតិកម្ពុជាមិនអាចបំភ្លេចនូវរបបកាប់សម្លាប់ដែលរំលោភសេរីភាពពួកគេបានឡើយ ។ ពេលហូប ពេលដេក គ្រប់យ៉ាងបានប្រព្រឹត្តទៅក្រោមការឃ្លាំមើលដ៏តឹងតែងពីអង្គការ» ។

ណាស៊ាត បានសង្កត់ធ្ងន់ទៅលើការជម្លៀស និងគ្រោះទុរ្ភិក្សដែលក្រុមគ្រួសាររបស់គាត់បានឆ្លងកាត់ ។ បងស្រីរបស់ ណាស៊ាត បានដាច់ពោះស្លាប់ ។ យុវជនជាសាសនិកឥស្លាមនេះរៀបរាប់ថា «មុនពេលដាច់ខ្យល់ បងស្រីខ្ញុំបានសុំបាយពីម្តាយខ្ញុំដើម្បីបំពេញក្រពះ ប៉ុន្តែម្តាយខ្ញុំមិនអាចរកបាយឲ្យគាត់ហូបបានទេ ហើយថែមទាំងមិនអាចបញ្ចេញការឈឺចាប់បានទៀតផង ។ ពួកខ្មែរក្រហមហាមគាត់មិនឲ្យមានមនោសញ្ចេតនា និងបង្ខំឲ្យទៅធ្វើការក្នុងថ្ងៃដដែល» ។ ណាស៊ាត មិនអាចបំភ្លេចសម្តីរបស់ម្តាយដែលប្រាប់ថា «គាត់មិនដែលជួបប្រទះរបបណាដែលសាហាវព្រៃផ្សៃដូច្នេះទេ ។ ការភ័យខ្លាចតាមជាប់យើងជានិច្ច ។ កាលពីមុន គាត់និយាយរឿងខ្មែរក្រហមតែនៅពេលគាត់ខឹងកូនៗ ឬខឹងក្មេងៗប៉ុណ្ណោះ ប៉ុន្តែនេះគឺជាលើកទី១ ហើយដែលខ្ញុំបានឮគាត់និយាយរៀបរាប់រឿងរ៉ាវរបស់គាត់តាំងពីដើមរហូតដល់ចប់» ។

## បង្កើតកិច្ចសន្ទនារវាងឪពុកម្តាយ និងកូនៗ

ណាស៊ាត បានស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈសាស្ត្រាចារ្យម្នាក់នៅព្រះវិហារឥស្លាមក្នុងក្រុងភ្នំពេញ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអង្គការដែលចងក្រងឯកសាររបបកម្ពុជាប្រជាធិបតេយ្យអស់រយៈពេល១១ឆ្នាំមកហើយ ។ អង្គការនេះបានអញ្ជើញ ណាស៊ាត មកទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ណាស៊ាត រួមជាមួយយុវជនជាតិចាម១០០នាក់ផ្សេងទៀត ប្រមូលយកការរៀបរាប់រឿងរ៉ាវរបស់ឪពុកម្តាយពួកគេ ក្នុងគោលបំណងដើម្បីបង្កើតទំនាក់ទំនងឲ្យកាន់តែជិតស្និទ្ធថែមទៀតរវាងឪពុកម្តាយនិងកូនៗ ។

ពីដំបូង ណាស៊ាត ជឿថា បេសកកម្មនេះមិនអាចទៅរួចទេ ព្រោះម្តាយរបស់គេនៅតែមានះមិនព្រមនិយាយអ្វីទាំងអស់ ។ យុវជននេះរំឭកឡើងវិញថា «គាត់គ្មានពេល ហើយគ្មានបានការអ្វីដែលត្រូវជីកកកាយអតីតកាលដ៏ឈឺចាប់នេះឡើងវិញទេ» ។ ប៉ុន្តែកញ្ញា សូ ហ្វារីណា អ្នកទទួលខុសត្រូវគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយលើកទឹកចិត្តយុវជននេះថា «វាមានសារសំខាន់ខ្លាំងណាស់ដែលយុវជនជំនាន់ក្រោយត្រូវស្គាល់ប្រវត្តិសាស្ត្រអ្នកជំនាន់មុន» ។ ដោយសារអំណះអំណាងនេះ ណាស៊ាត បានព្យាយាមនិយាយបញ្ចុះបញ្ចូលម្តាយគេម្តងទៀត ហើយក៏បានយកឈ្នះភាពមានះរបស់ម្តាយគាត់ ។ ណាស៊ាត បានចំណាយពេលមួយសប្តាហ៍ដើម្បីស្តាប់និងកត់ត្រាសម្តីម្តាយបញ្ចូលក្នុងកូនសៀវភៅមួយ ។

## យល់ពីឪពុកម្តាយកាន់តែច្បាស់

នៅពេលបានដឹងរឿងអតីតកាលដ៏ខ្មៅងងឹតរបស់ម្តាយ ទើប ណាស៊ាត ដឹងថា ហេតុអ្វីគ្រួសាររបស់គាត់មិនចង់រំឭករឿងរ៉ាវក្នុងរបបខ្មែរក្រហម ហេតុអ្វីសុខភាពម្តាយរបស់គាត់ទន់ខ្សោយយ៉ាងនេះ ។ ណាស៊ាត និយាយដោយបើកចំហថា «តាំងពីតូចមកខ្ញុំស្រឡាញ់ម្តាយខ្ញុំណាស់ ។ នៅពេលនេះខ្ញុំបានដឹងរឿងរ៉ាវដែលគាត់បានឆ្លងកាត់ ខ្ញុំកាន់តែគោរពស្រឡាញ់គាត់ថែមទៀត ។ ខ្ញុំមិនអាចបំភ្លេចរឿងសោកនាដកម្មដែលធ្វើឲ្យគាត់ឈឺចាប់ឥតទីបំផុតនេះបានទេ ។ រឿងតែមួយគត់ដែលខ្ញុំអាចធ្វើបានសម្រាប់គាត់ គឺខ្ញុំនឹងថែទាំគាត់ឲ្យបានល្អ និងខំយល់ពីគាត់ឲ្យបានកាន់តែច្រើន» ។

ការដឹងរឿងប្រវត្តិសាស្ត្រតាមវិធីនិយាយផ្ទាល់មាត់ធ្វើឲ្យណាស៊ាត ចង់ដឹងរឿងខ្មែរក្រហមកាន់តែច្រើនថែមទៀត ។ ណាស៊ាត ជឿថា «សម្រាប់យើងជាក្មេងជំនាន់ក្រោយ យើងដឹងត្រឹមថាខ្មែរក្រហមមានឈ្មោះតែប៉ុន្មាននាក់ប៉ុណ្ណោះ គឺ ប៉ុល ពត អៀង សារី និង ខៀវ សំផន ។ ប៉ុន្តែ ដោយសារសាលាក្តីខ្មែរក្រហមខ្ញុំដឹងថាអ្នកទទួលខុសត្រូវធំមិនមែនមានតែប៉ុន្មាននាក់នោះទេ ហើយដោយសារតែសាលាក្តី នៅចុងបញ្ចប់យើងនឹងដឹងពីប្រវត្តិសាស្ត្រសំខាន់មួយនេះ» ។

## ស្រាយបំភ្លឺទេវកថា

ទុំ ជ័យនុប អាយុ២៩ឆ្នាំ តែងតែគិតថា ខ្មែរក្រហមគឺជាតួអង្គក្នុងរឿងព្រេងនិទាន ។ វាគឺជារឿងប្រឌិតផុសចេញពីគំនិតឪពុកម្តាយដែលទទួលការអប់រំមិនបានជ្រៅជ្រះ ។ នៅពេលមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យ នុប ចូលរួមកម្មវិធីសរសេររឿងរ៉ាវគ្រួសារការកត់ត្រាសេចក្តីលម្អិតពីជីវភាពប្រចាំថ្ងៃរបស់ឪពុកម្តាយបានធ្វើឲ្យគំនិតដែលគិតថា «តើឲ្យជឿម្តេចកើតថាមានរបបមួយដែលក្មេងៗបានបញ្ជាមនុស្សចាស់ឲ្យធ្វើការដូចសត្វធាតុ» បានផ្លាស់ប្តូរនឹងជឿថាមានខ្មែរក្រហមពិតមែន ។ នុប សារភាពថា «វាគួរឲ្យចាប់អារម្មណ៍ណាស់ ។ ខ្ញុំមានអារម្មណ៍ហាក់ដូចជាស្ថិតនៅក្នុងរឿងនោះដែរ ។ បច្ចុប្បន្នខ្ញុំយល់ហើយ បើទោះជាខ្ញុំមិនបានឆ្លងកាត់រឿងភ័យរន្ធត់ដូចគាត់ក៏ដោយ» ។

## និយាយចេញដើម្បីជម្រុះការឈឺចាប់

អ៊ិត ទីម៉ាស់ ម្តាយរបស់ ណាស៊ាត បានខិតខំរំឭកឡើងវិញនូវជីវិតប្រចាំថ្ងៃក្រោមសម័យមួយដែលបានឆក់យកជីវិតប្តី និងកូនម្នាក់របស់គាត់ ។ ការលើកយកអំពើសាហាវឃោរឃៅរបស់ខ្មែរក្រហមមកប្រៀនប្រដៅកូនៗ នៅខណៈពេលគេបង្ហាញអាកប្បកិរិយាមិនសមរម្យ គឺជាអ្វីដែលគាត់គិតថា អាចធ្វើទៅបាន ។ ស្ត្រីអាយុ៦០ឆ្នាំនេះ ពន្យល់ថា «ពីមុនខ្ញុំលាក់ទុករឿងគ្រប់យ៉ាងតែម្នាក់ឯង គឺបិទជិតឈឹង ។ ឥឡូវនេះចាប់តាំងពីខ្ញុំនិយាយប្រាប់កូនប្រុសខ្ញុំមក ខ្ញុំមានអារម្មណ៍ធូរស្រាល ខ្ញុំមានចិត្តស្ងប់ឡើងវិញ» សព្វថ្ងៃខ្ញុំសង្ឃឹមថា កូនៗនឹងដឹងពីការលំបាករបស់ខ្ញុំកាលពីអតីតកាល ហើយគេនឹងចេះតស៊ូនៅក្នុងជីវិត «ពួកគេសុទ្ធតែកើតក្នុងពេលប្រទេសមានសន្តិភាព ហើយមិនដែលស្គាល់អ្វីលំបាកទេ ។ ដូច្នេះ អតីតកាលរបស់ខ្ញុំអាចជួយពួកគេឲ្យគិតពិចារណាអំពីជីវិត» ។

## ដកស្រង់បទពិសោធន៍ពីរឿងអតីតកាល

តាមរយៈការស្តាប់រឿងរ៉ាវរបស់ឪពុកម្តាយ យុវជនអាចមានការតក់ស្លុត និងរំជួលចិត្ត ប៉ុន្តែតាមរយៈលំហាត់មួយនេះគេនឹងចោទសួរខ្លួនឯងច្រើនថែមទៀតអំពីប្រវត្តិសាស្ត្ររបស់ខ្លួន និងយកចំណេះដឹងទាំងនេះទៅចែករំលែកជាមួយមិត្តរួមថ្នាក់ ។ ហ៊ុរីណា បន្ថែមថា «វាគឺជាវិធីសាស្ត្រនៃការពិចារណាមួយដែលតម្រូវឲ្យអ្នកចូលរួមក្នុងគម្រោងនេះប្រៀបធៀបមេដឹកនាំខ្មែរក្រហម ជាមួយនឹងមេដឹកនាំសព្វថ្ងៃ ដើម្បីរួមចំណែកបង្ការកុំឲ្យសោកនាដកម្មប្រភេទនេះកើតឡើងម្តងទៀតនៅកម្ពុជា» ។

**ឈាង បុប្ផា**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ដំណឹងស្វែងរកឪពុកមា

នាងខ្ញុំឈ្មោះ ង្វៀន ង៉ុកហឿងថាវ ត្រូវជាកូនស្រីរបស់អ្នកស្រី តា ធីត្វៀនម៉ាយ និង លោក ង្វៀន វ៉ាន់ធីញ ។ យើងខ្ញុំជាជនជាតិវៀតណាមមកពីភូមិហ្គោយ៉ូវក្នុងខេត្តតៃនិញ ប្រទេសវៀតណាម ។

នាងខ្ញុំកំពុងស្វែងរកឪពុកមាឈ្មោះ តា មិញម៉ាន (ឈ្មោះនៅផ្ទះហៅថា ហុង ខាញ់) កើតនៅឆ្នាំ១៩៦៥ ។ ម៉ាន ត្រូវជាប្អូនប្រុសពៅរបស់ម្តាយនាងខ្ញុំឈ្មោះ តា ធីត្វៀនម៉ាយ និងជាកូនប្រុសរបស់លោកតានាងខ្ញុំឈ្មោះ តា ថាញ់សឺន ។

ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៩ ឪពុកម្តាយ, ជីដូនមួយ (អាយុ១៥ឆ្នាំ), ឪពុកមាអាយុ១៥ឆ្នាំ និងបងប្រុសរបស់ខ្ញុំ(អាយុ១២ខែ) បានចាកចេញពីប្រទេសវៀតណាមនិងបានធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជាទៅជំរំជនភៀសខ្លួនស៊ីឃ្យូវ នៅក្នុងប្រទេសថៃ និងជាកន្លែងដែលរូបនាងខ្ញុំបានកើតនៅទីនោះ ។

នៅក្នុងព្រៃចន្លោះពីស្វាយស៊ីសូផុនទៅប៉ោយប៉ែត (គឺជាព្រៃដែលពួកអ្នករត់ពន្ធបានរត់ឆ្លងកាត់) ឪពុកមារបស់នាងខ្ញុំត្រូវបានមើលឃើញថាគាត់ត្រូវចងដៃទៅក្រោយខ្នងដោយយោធាមួយក្រុម (ប្រហែលជាខ្មែរក្រហម) ដែលស្ថិតនៅម្តុំប៉ោយប៉ែត ។ ចាប់តាំងពីពេលនោះមក យើងខ្ញុំមិនដែលបានទទួលដំណឹងអ្វីពីគាត់ឡើយ ។



ផ្លូវដែលយើងខ្ញុំបានធ្វើដំណើរពីវៀតណាមទៅជំរំត្រូវឆ្លងកាត់កម្ពុជាគឺតាមបាវិត, ស្វាយរៀង, អ្នកលឿង, កំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, ស្វាយស៊ីសូផុន ហើយនិងប៉ោយប៉ែត ។ បន្ទាប់ពីមកដល់ប៉ោយប៉ែត គ្រួសាររបស់នាងខ្ញុំបានទៅស្នាក់នៅតាមជំរំជនភៀសខ្លួនមួយចំនួនដូចជា ណុន ម៉ាក ម៉ុន, ខាវអ៊ីដាង និងស៊ីឃ្យូវ ។ គ្រួសាររបស់នាងខ្ញុំបានចាកចេញពីជំរំជនភៀសខ្លួនស៊ីឃ្យូវ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៨០ ។

សព្វថ្ងៃនេះគ្រួសារខាងឪពុកម្តាយនាងខ្ញុំនៅតែរស់នៅក្នុងភូមិហ្គោយ៉ូវ ក្នុងខេត្តតៃនីញ ប្រទេសវៀតណាម ។ ប្រសិនបើបងប្អូនណាមានដំណឹងអំពីឪពុកមានាងខ្ញុំ សូមមេត្តាទំនាក់ទំនងជាមួយមជ្ឈ-មណ្ឌលឯកសារកម្ពុជា (៨៥៥-២៣) ២១១ ៨៧៥ ឬប្រអប់សំបុត្រ ១១១០ ភ្នំពេញ កម្ពុជា ។

**ឡុង ដានី**



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 102, June 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.